# សូមថ្វាយព្រះរាជសព្ទសាធុការពរ បវរមហាប្រសើរ

## នៅក្នុងឱកាសដ៏មហានក្ខត្តឫក្ស នៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម

## ព្រះករុណាព្រះបាទសម្ដេច ព្រះបរមនាថ នរោត្ដម សីហមុនី

## ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

## គម្រប់ព្រះជន្ម ៦២ យាងចូល ៦៣ ព្រះវស្សា

## ( ១៤.០៥.១៩៥៣ - ១៤.០៥.២០១៥ )



ទូលព្រះបង្គំយើងខ្ញុំ សូមឧទ្ទិសបួងសួងគុណបុណ្យព្រះរតនត្រ័យ វត្ថុស័ក្ដិសិទ្ធិនានាក្នុងលោក ទេវតារក្សាព្រះមហាសេ្វតច្ឆត្រ និងព្រះវិញ្ញាណក្ខន្ធនៃអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីខ្មែរគ្រប់ព្រះអង្គ សូមជួយប្រោះព្រំ គាំពារថែរក្សាព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមមានព្រះរាជសុខភាពបរិបូរ ព្រះបញ្ញាញាណភ្លឺថ្លា ព្រះជន្មាយុយឺនយូរ ដើម្បីគង់ប្រថាប់ក្នុងព្រះសិរីរាជសម្បត្តិ ជានិមិត្តរូបដ៏ខ្ពង់ខ្ពស់បំផុតនៃ ឯករាជ្យ ឯកភាពជាតិ អធិបតេយ្យជាតិ បូរណភាពទឹកដី វឌ្ឍនភាព និងវិបុលភាព នៃព្រះរាជាណាចក្រកម្ពុជា និងជាម្លប់ដ៏ត្រជាក់នៃប្រជារាស្ត្រខ្មែរតរៀងទៅ ។

*សូមក្រាបបង្គំទូលថ្វាយដោយភក្ដីភាពតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត*

*ទស្សនាវដ្ដីប្រជាជន*

# សូមប្រសិទ្ធពរបវរមហាប្រសើរជូន



## សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
## ប្រធានកិត្តិយសគណបក្សប្រជាជនកម្ពុជា
## និងជាប្រធានក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជាជាទីគោរពដ៏ខ្ពង់ខ្ពស់ !

### ក្នុងឱកាសដ៏មហានក្ខត្តឫក្សនៃទិវាគម្រប់ជន្មាយុ ៨១ ឈានចូល ៨២ វស្សា របស់សម្តេច

យើងខ្ញុំសូមលំឱនកាយគោរព សម្តេចជាវីរកុលបុត្រខ្មែរដ៏ឆ្នើម និងជារដ្ឋបុរសដ៏ឧត្តុង្គឧត្តម ដែលបានលះបង់អស់កម្លាំងកាយ កម្លាំងចិត្តនិងបញ្ញាញាណដើម្បីរំដោះជាតិនិងដឹកនាំកសាងការពារមាតុភូមិកម្ពុជាសម្រេចបានជោគជ័យដ៏ធំធេងជាប្រវត្តិសាស្ត្រ តាំងពីដំណាក់កាលសង្គ្រោះជាតិ រហូតមកដល់ដំណាក់កាលសន្តិភាព ប្រជាធិបតេយ្យ និងអភិវឌ្ឍន៍នាពេលបច្ចុប្បន្ន ។

សូមឧទ្ទិសបួងសួងគុណបុណ្យ ព្រះរតនត្រ័យ ទេវតាឆ្នាំថ្មី និងវត្ថុស័ក្តិសិទ្ធិ ទាំងឡាយក្នុងលោក ព្រមទាំងតេជៈបារមី នៃវិញ្ញាណក្ខន្ធរបស់បុព្វវីរបុរសខ្មែរគ្រប់ៗជំនាន់ សូមតាមជួយប្រោះព្រំ គាំពារ ថែរក្សាសម្តេច និងលោកជំទាវ សូមបានប្រកបនូវពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ ជា រៀងដរាប ។

**គោរពជូនដោយក្តីកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត**
**ទស្សនាវដ្តីប្រជាជន**

វិចារណកថា
EDITORIAL

# កម្ពុជាកំពុងឈានទៅមុខយ៉ាងរឹងមាំលើមាគ៌ាអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច

# Cambodian's Steadfast Steps on the Path of Socio-economic Development

រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី ៥ នៃរដ្ឋសភា បាននិងកំពុងអនុវត្តយ៉ាងសកម្មប្រកបដោយការទទួលខុសត្រូវខ្ពស់បំផុតនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព ដែលជារបៀបវារៈគោលនយោបាយសង្គម សេដ្ឋកិច្ចដើម្បីធានាអនុវត្តដោយជោគជ័យនូវកម្មវិធីនយោបាយរបស់ខ្លួន ។ ក្នុងគោលដៅនេះ រាជ-រដ្ឋាភិបាលកំពុងបន្តអនុវត្តដោយឥតរាថយនូវកំណែទម្រង់សំខាន់ៗ ជាអាទិ៍ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ការកែទម្រង់រដ្ឋ បាលសាធារណៈ ការកែទម្រង់កងកម្លាំងប្រដាប់អាវុធ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈការកែទម្រង់ការគ្រប់គ្រងដីធ្លី ការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ លទ្ធ-ផលនៃកំណែទម្រង់បានជះឥទ្ធិពលវិជ្ជមានដល់អភិបាលកិច្ចល្អ ការពង្រឹងយុត្តិធម៌សង្គម ។

សមិទ្ធផលសេដ្ឋកិច្ច សង្គម ដែលសម្រេចបានក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះជាពិសេសឆ្នាំ២០១៣និងឆ្នាំ២០១៤បានបង្ហាញឲ្យឃើញថាកម្ពុជាកំពុងធ្វើដំណើរទៅមុខយ៉ាងស្វាហាប់លើមាគ៌ាអភិវឌ្ឍន៍ ជាមួយនឹងភាពរឹងមាំនៃខឿនសន្តិភាព ស្ថិរភាពនយោបាយ និងលទ្ធិប្រជាធិបតេយ្យ។ ឆ្នាំ ២០១៤ សេដ្ឋកិច្ចកម្ពុជាមានកំណើនក្នុងរង្វង់ ៧% ក្នុងនោះវិស័យឧស្សាហកម្មកើន ៩,៦% សេវាកម្មកើន ៧,៥% កសិកម្មកើន ២,៦% ។ ផលិតផលសរុបក្នុងស្រុកជាមធ្យមសម្រាប់មនុស្សម្នាក់បានកើនពី ៧៦០ ដុល្លារនៅឆ្នាំ២០០៨ដល់១១២១ដុល្លារនៅឆ្នាំ២០១៤ហើយនឹងកើនដល់ជាង១២០០ដុល្លារនៅឆ្នាំ២០១៥។ សន្តិសុខស្បៀងត្រូវបានធានាជាមួយការមានអង្ករប្រមាណ ៣ លានតោនសម្រាប់នាំចេញ។ ភ្ញៀវទេសចរមកទស្សនាកម្ពុជាមាន ៤,៥ លាននាក់ ដែលនាំមកនូវចំណូលជាង ៣ ពាន់លានដុល្លារ ។ រាជរដ្ឋាភិបាលបានចេញលិខិតអនុញ្ញាតសាងសង់១៩៦០គម្រោង ដែលមានទឹកប្រាក់វិនិយោគប្រមាណ ២៥០០ លានដុល្លារ ។ ការអភិវឌ្ឍ និងទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធរូបវន្តត្រូវបានជំរុញយ៉ាងខ្លាំងទទួលបានសមិទ្ធផលថ្មីៗជាបន្តបន្ទាប់ ។ លើមូលដ្ឋានការរីកចម្រើននេះ ភាពក្រីក្ររបស់ប្រជាជនត្រូវបានកាត់បន្ថយមកនៅក្រោម ១៨% ជីវភាពរបស់ប្រជាជនទូទៅ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ កម្មករ និយោជិតត្រូវបានកែលម្អលើកកម្ពស់មួយកម្រិតទៀត ។

ថ្មីៗនេះ ធនាគារពិភពលោកបានចាត់បញ្ចូលប្រទេសកម្ពុជានៅក្នុងក្រុមប្រទេសដែលមានកំណើនគួរឲ្យស្ញប់ស្ញែងដោយសម្រេចបានកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំជាមធ្យម៧,៧%ក្នុងរយៈពេល២ទសវត្សចុងក្រោយនិងបានធ្វើឲ្យកម្ពុជាក្លាយជាប្រទេសមានកំណើនសេដ្ឋកិច្ចលឿនបំផុតលំដាប់ទី ៦ នៅលើពិភពលោក។ ធនាគារអភិវឌ្ឍអាស៊ី(ADB)ក៏បានចេញផ្សាយរបាយការណ៍ពិសេសប្រចាំឆ្នាំកាលពីថ្ងៃទី ២៤ ខែមីនា ដែលបានលើកឡើងថា ផលិតផលក្នុងស្រុកសរុបរបស់កម្ពុជា GDP ត្រូវបានព្យាករណ៍ថានឹងមានការកើនឡើងពី ៧,០ % ក្នុងឆ្នាំ ២០១៤ រហូតដល់ ៧,៣ % ក្នុងឆ្នាំ ២០១៥ និងបន្តកើនឡើងដល់ ៧,៥ % នៅឆ្នាំក្រោយ។ សេដ្ឋកិច្ចកម្ពុជាបានឈានដល់ដំណាក់កាលនៃការអភិវឌ្ឍថ្មីមួយ គឺកំពុងក្លាយខ្លួនជា

The Royal Government of the fifth legislative term of the National Assembly has been implementing actively and with high responsibility the Rectangular Strategy - Phase III for growth, equity and efficiency - an agenda for socio-economic development - aimed at guaranteeing successful fulfilment of its political platform. It is in this objective, the Royal Government has continued its implementation of major reforms - the fight against corruption, legal and judicial reform, public administration reform, the reform of the armed forces, public financial management reform, land management reform, sustainable management of environmental and natural resources. Results of reforms have major positive impacts on good governance and enhancement of social justice.

Socio-economic achievements scored over that past years, mainly those from 2013 and 2014, have illustrated that Cambodia is making active advancement on the path of development on the basis of firm foundation of peace, political stability and democracy. In 2014, the Cambodian economy scored around 7% growth, in which industry marked 9.6%, service sector - 7.5% and agriculture - 2.6% growth respectively. The gross domestic product per capita has increased from 760 USD in 2008 to 1,121 USD in 2014. It will reach 1,200 USD in 2015. Food security has been guaranteed while the country has a surplus of three million tons of rice for export.

Cambodia noted 4.5 million tourist arrivals, which brings about over three billion US dollars for the country. The Royal Government issued permission for 1,960 construction projects with the total investment of 2.5 billion USD. Cambodia also makes further achievements in area of development and modernization of physical infrastructures. Based on this progress, poverty has been reduced to below 18% while the living condition of the people, the civil servants, the armed forces, workers and employees have improved to a certain degree.

Recently, the World Bank stated that Cambodia has joined the Olympians of growth as its economy has grown at a yearly average growth rate of 7.7 percent for two decades making it the sixth faster growing country in the world over that period. In its Development Outlook Report for 2015, the Asian Development Bank projects Cambodia's gross domestic product (GDP) to expand from 7% in 2014 to 7.3% in 2015 and will climb to 7.5% next year. The Cambodian economy is at its new stage, where the country will become a lower middle income country and is in a restructuring phase. In this framework, Cambodia must guarantee yearly inclusive and sustainable economic growth, which is the foundation for jobs creation and chances to earn decent income, while increasing speed to reduce poverty and improving people's living condition in general.

The Royal Government of Cambodia has set a clear goal for 2015-16 and coming years to strengthen its competitiveness in attracting investment, increasing productivity in all fields, especially agriculture, diversifying new strive in the economy, focussing deeper on quality and efficiency of the public services and continuing to mobilize further deeper and efficient reforms. Human resource development, especially technical

*ប្រទេសមានចំណូលមធ្យម(កម្រិតទាប) និងកំពុងស្ថិតក្នុងដំណើរផ្លាស់ប្តូរជារចនាសម្ព័ន្ធ។ នៅក្នុងក្របខណ្ឌនេះ កម្ពុជាត្រូវធានាឲ្យបានកំណើនសេដ្ឋកិច្ចជាមធ្យមប្រចាំឆ្នាំប្រកបដោយបរិយាប័ន្ននិងចីរភាពដែលជាមូលដ្ឋានសម្រាប់ការបង្កើតការងារ និងឱកាសរកប្រាក់ចំណូលសមរម្យ ព្រមទាំងការបង្កើនល្បឿនកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនទូទៅ ។*

*រាជរដ្ឋាភិបាលកម្ពុជាបានកំណត់គោលដៅច្បាស់លាស់ សម្រាប់ឆ្នាំ ២០១៥-២០១៦ និងបណ្តាឆ្នាំខាងមុខ គឺការពង្រឹងភាពប្រកួតប្រជែងក្នុងការទាក់ទាញវិនិយោគ ការបង្កើនផលិតភាពគ្រប់វិស័យ ជាពិសេសក្នុងវិស័យកសិកម្មការជំរុញធ្វើពិពិធកម្មសេដ្ឋកិច្ចក្នុងសន្ទុះថ្មីការបន្តផ្តោតកាន់តែស៊ីជម្រៅទៅលើការបង្កើនគុណភាព និងប្រសិទ្ធភាពនៃសេវាសាធារណៈ និងការបន្តចលនានៃការកែទម្រង់ឲ្យកាន់តែជ្រាលជ្រៅ និងមានប្រសិទ្ធភាព ។ ការអភិវឌ្ឍធនធានមនុស្ស ជាពិសេសការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈដល់យុវជន ការបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តការសម្រួលពាណិជ្ជកម្មការពង្រឹងអភិបាលកិច្ច និងសមត្ថភាពស្ថាប័នរដ្ឋ សុទ្ធតែជាការងារអាទិភាពដែលរាជរដ្ឋាភិបាលកម្ពុជាបានធ្វើ និងកំពុងធ្វើដោយសកម្មបំផុត ។ សន្តិភាព ស្ថិរភាពនយោបាយ និងសុខដុមនីយកម្មសង្គមនាពេលបច្ចុប្បន្ន កាន់តែបង្កលក្ខណៈងាយស្រួលឲ្យប្រជាជនកម្ពុជាទូទាំងប្រទេស ចូលរួមអនុវត្តទាំងអស់គ្នានូវកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ដោយឈរលើគោលការណ៍សាមគ្គីភាព ឯកភាពជាតិ និងតម្កល់ផលប្រយោជន៍ជាតិ និងប្រជាជនជាធំ ។ ព្រះរាជាណាចក្រកម្ពុជាបាននិងកំពុងពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសនិងអង្គការអន្តរជាតិនានាទាំងក្នុងក្របខណ្ឌទ្វេភាគី និងពហុភាគីប្រកបដោយផ្លែផ្កា សំដៅបន្តជំរុញការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ពង្រឹងជំហរនយោបាយរបស់រាជរដ្ឋាភិបាលព្រមទាំងរួមចំណែកពង្រឹងសន្តិភាពស្ថិរភាពកិច្ចសហប្រតិបត្តិការ និងវិបុលភាពនៅក្នុងតំបន់ និងពិភពលោក។កម្ពុជាបន្តពង្រឹងភាពជាដៃគូផ្នែកសេដ្ឋកិច្ច ជាមួយប្រទេសសមាជិកអាស៊ាន ប្រទេសក្នុងតំបន់អាស៊ីខាងកើត និងតំបន់ផ្សេងៗទៀត ដោយរក្សាសេដ្ឋកិច្ចឲ្យនៅតែមានលក្ខណៈបើកចំហនៅក្នុងទីផ្សារពិភពលោក និងខិតខំត្រៀមរៀបចំខ្លួនឲ្យបានល្អសម្រាប់សហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ ២០១៥ ។*

*ឆ្លងតាមបណ្តាសមិទ្ធផលដែលសម្រេចបានមកដល់ពេលនេះ បានឆ្លុះបញ្ចាំងឲ្យឃើញអំពីភាពត្រឹមត្រូវ នៃនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃរបស់សម្តេចតេជោ* ***ហ៊ុន សែន*** *ការចូលរួមពីកម្លាំងជាតិទាំងមូល និងពីសំណាក់ដៃគូអភិវឌ្ឍន៍នានា ក្នុងការគាំទ្រ និងអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។ ហើយតាមរយៈសមិទ្ធផលទាំងអស់នេះ រួមជាមួយកាលានុវត្តភាពរបស់កម្ពុជា បច្ចុប្បន្នបានផ្តល់សុទិដ្ឋិនិយមដ៏មុតមាំចំពោះអនាគតប្រកបដោយមោទនភាពនៃមាតុភូមិកម្ពុជា។ នៅក្នុងសារលិខិតជូនពរនាឱកាសបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិឆ្នាំមមែ សប្តស័ក ព.ស ២៥៥៩ សម្តេចតេជោ* ***ហ៊ុនសែន*** *បានបញ្ជាក់ថា រាជរដ្ឋាភិបាលនឹងបន្តថែរក្សាការពារសន្តិភាព ស្ថិរភាព សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈឲ្យកាន់តែរឹងមាំ ដើម្បីធានាបាននូវបរិស្ថានអនុគ្រោះសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ដោយបន្តអនុវត្តឥតរាថយនូវដំណើរការកែទម្រង់ស៊ីជម្រៅឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀត សំដៅជំរុញការលើកកម្ពស់អភិបាលកិច្ចល្អការលុបបំបាត់អំពើពុករលួយ ការផ្តល់សេវាសាធារណៈប្រកបដោយការជឿទុកចិត្ត ការពង្រឹងយុត្តិធម៌ និងសមធម៌សម្រាប់ប្រជាជនគ្រប់រូប ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចប្រកបដោយស្ថិរភាព ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាពដើម្បីកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ឆ្ពោះទៅរកអនាគតមួយដ៏រុងរឿងភ្លឺស្វាងស្របតាមឆន្ទៈ និងបំណងប្រាថ្នារបស់ប្រជាជាតិកម្ពុជាទាំងមូល ។*

*ជាមួយនឹងឆន្ទៈនយោបាយដ៏មុតស្រួច និងកម្លាំងសាមគ្គីរបស់ប្រជាជាតិយើង យើងពិតជាសម្រេចបាននូវគោលដៅសេដ្ឋកិច្ច សង្គម ក្នុងឆ្នាំ ២០១៥ នេះ ៕*

**ទស្សនាវដ្តីប្រជាជន**

and vocational training for youth population, development of physical infrastructures, trade facilitation, strengthening of good governance and capacity of state institutions are all prioritized areas that the Royal Government of Cambodia has been doing relentlessly. Peace, the current political stability and social harmony has brought about favourable conditions for the Cambodian people in the whole country to implement altogether the political platform of the Royal Government based on national solidarity and unity, and high national and people's interests.

The Kingdom of Cambodia has been expanding and strengthening fruitful cooperation with countries and international organizations bilaterally and multilaterally aimed at further developing socio-economic development, strengthening political stand of the Royal Government, while also contributing to the strengthening of peace, stability, cooperation and prosperity in the region and the world. Cambodia continues to bolster economic partnership with member countries of ASEAN as well as those in East Asia and other regions by keeping its economy open to the world markets and preparing well for the ASEAN Economic Community in 2015.

The achievements scored so far have clearly reflected the correct economic policy of the Royal Government under the wise and smart leadership of SamdechTecho Hun Sen, the participations of the whole national forces and development partners in supporting and implementing its political platform and Rectangular Strategy. These achievements, in addition to Cambodia's current opportunity, have ensured firm optimism for a proud future of the Cambodian motherland. In his seasonal greeting message during the traditional Khmer New Year, the Year of the Goat, marking the beginning of Buddhist era of 2559, SamdechTecho Hun Sen asserted that the Royal Government continues to firmly safeguard peace, stability, security and public order to ensure favourable environment for the sustainable development through continuing more in-depth and effective reforms to promote good governance, the eradication of corruption by providing public services with trust, enhancing justice and equity for every individual, while controlling the stability of macro-economy and the sustainability of natural resources for the economic growth and people's poverty reduction to ensure brilliant future in conformity to the will and aspiration of the whole people of Cambodia.

With such sharp-sighted political will and national solidarity force, we will realize the 2015 socio-economic objectives./.

*THE PRACHEACHUN MAGAZINE*

# កម្ពុជាបានចេញផុតពីភាពតានតឹងខាងនយោបាយហើយ

ស្ថានការណ៍នយោបាយនៅក្នុងប្រទេសកម្ពុជាបានឈានចេញផុតពីដំណាក់កាលតានតឹងមកកាន់ភាពធូរស្រាលហើយ បន្ទាប់ពីសមិទ្ធផលទាំងឡាយដែលជាផ្លែផ្កានៃកិច្ចព្រមព្រៀង ស្តីពីដំណោះស្រាយនយោបាយរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិនៅថ្ងៃទី ២២ ខែកក្កដា បានកើតជារូបរាងឡើង។ តាមសេចក្តីប្រកាសរួមគណបក្សទាំងពីរបានឯកភាពគ្នាដើម្បីកែទម្រង់ការបោះឆ្នោត និងពង្រឹងស្ថាប័នជាតិសំខាន់ៗជាពិសេសស្ថាប័នឯករាជ្យនានាឲ្យអាចបំពេញការងារបម្រើជាតិ និងប្រជាជន ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងនីតិរដ្ឋ។ ផ្អែកតាមស្មារតីនេះ ក្រុមការងារគណបក្សទាំងពីរបានជួបពិភាក្សាគ្នាជាច្រើនដង ដើម្បីតាក់តែងសេចក្តីព្រាងសេចក្តីស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងសេចក្តីព្រាងសេចក្តីស្នើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដែលការងារនេះចាប់ផ្តើមតាំងពីថ្ងៃទី០៨ខែធ្នូឆ្នាំ២០១៤ បានបញ្ចប់នៅថ្ងៃទី០៦ខែមីនា ឆ្នាំ២០១៥ និងផ្សព្វផ្សាយជាសាធារណៈក្នុងអង្គសិក្ខាសាលាមួយដោយមានការចូលរួមពីអង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ តំណាងគណបក្សនយោបាយនានានៅថ្ងៃទី ០៩ ខែមីនា ឆ្នាំ ២០១៥។ ច្បាប់ទាំងពីរនេះត្រូវបានសម័យប្រជុំវិសាមញ្ញនៃរដ្ឋសភានីតិកាលទី៥ អនុម័តនៅថ្ងៃទី១៩ខែមីនា ឆ្នាំ២០១៥។ នៅថ្ងៃទី ០៩ ខែមេសា រដ្ឋសភាបានបោះឆ្នោតផ្តល់សេចក្តីទុកចិត្តដល់ គ .ជ.ប ថ្មី ដែលមានចំនួន ៩ រូប ។ បន្ទាប់មក គ.ជ.ប ថ្មី បានចូលទៅធ្វើសច្ចាប្រណិធានក្នុងព្រះបរមរាជវាំងនៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៥។ នៅថ្ងៃទី១៣ ខែមេសា គ. ជ.ប ចាស់បានផ្ទេរតំណែងទៅ គ.ជ.ប ថ្មីជាផ្លូវការ។

ឆ្លងតាមច្បាប់ទាំងពីរ និង គ.ជ.បថ្មី ដែលបានបង្កើតឡើងនៅពេលនេះ បានបង្ហាញឲ្យឃើញច្បាស់ ពីការទទួលខុសត្រូវរបស់អ្នកនយោបាយកម្ពុជាដែលមានភាពចាស់ទុំ បង្កើតបាននូវវប្បធម៌សន្ទនារវាងខ្មែរគ្នាឯង ដោយពុំមានការលូកដៃចូលពីបរទេស គ្មានការគាបសង្កត់ ឬការគំរាមកំហែងណាមួយឡើយ។ គ.ជ.បថ្មីនឹងបន្តបំពេញតួនាទីប្រកបដោយការទទួលខុសត្រូវចំពោះមុខប្រវត្តិសាស្ត្រ និងប្រជាជាតិកម្ពុជា ថែរក្សាការពារទុកជាតំណតទៅជារៀងរហូតនូវលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ដោយប្រកាន់ខ្ជាប់នូវតួនាទីឯករាជ្យអព្យាក្រឹត្យ ក្នុងការបំពេញការងារទាំងអស់របស់ខ្លួន ដើម្បីការជឿទុកចិត្តសម្រាប់ទាំងអស់គ្នា ។

ការរៀបចំការបោះឆ្នោត គឺជាបេសកម្មនៃប្រវត្តិសាស្ត្រមួយដែលមានការលំបាកស្មុគស្មាញក្រៃលែង។ នៅលើពិភពលោកនេះ សូម្បីតែប្រទេសដែលប្រកាន់យករបបប្រជាធិបតេយ្យរាប់រយឆ្នាំមកហើយក៏ដោយ ក៏ការរៀបចំការបោះឆ្នោតមិនអាចប្រព្រឹត្តទៅបានដោយល្អឥតខ្ចោះ ១០០ % នោះបានដែរ។ហេតុនេះថ្វីបើយើងមានច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃ គ.ជ.ប យើងមាន គ.ជ.បថ្មី យើងមានច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រថ្មី ប៉ុន្តែចាំបាច់ណាស់ត្រូវទាមទារការចូលរួមសហការពីប្រជាជន និងភាគីពាក់ព័ន្ធទាំងអស់ ដើម្បីធ្វើឲ្យដំណើរការនេះប្រព្រឹត្តទៅត្រឹមត្រូវតាមច្បាប់ និងស្របតាមការគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ គ.ជ.ប ត្រូវអនុវត្តភារកិច្ចរបស់ខ្លួនយ៉ាងម៉ត់ចត់បំផុតប្រកបដោយសុចរិតភាព តម្លាភាព និងប្រសិទ្ធភាព សំដៅធានាឲ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ជាធរមាន បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោតដែលជាការចង់បានរបស់គ្រប់ភាគី។ លើមូលដ្ឋាននេះ អ្នកឈ្នះនិងទទួលបានកិត្តិយស ឯអ្នកចាញ់ក៏បានស្ងប់ចិត្ត ស្ថិរភាពនយោបាយ និងសុខដុមភាពក្នុងសង្គមកាន់បានពង្រឹង ហើយមុខមាត់របស់ជាតិ និងលិទ្ធិប្រជាធិបតេយ្យក៏កាន់តែបានលើកស្ទួយ ។

គួររំឭកថា គ.ជ.ប ដែលបានបង្កើតឡើងតាំងពីឆ្នាំ ១៩៩៨ រហូតមកដល់ឆ្នាំ២០១៥នេះ មានថេរវេលា ១៧ ឆ្នាំ ដោយបានបំពេញការងាររបស់ខ្លួនប្រកបដោយការទទួលខុសត្រូវបង្កើតបាននូវសមិទ្ធផលដ៏ធំធេង ។នៅក្នុងរយៈពេលនេះច្បាប់ស្តីពីការបោះឆ្នោត និងច្បាប់ពាក់ព័ន្ធមួយចំនួនទៀតត្រូវបានធ្វើវិសោធនកម្មជាបន្តបន្ទាប់ ដើម្បីឲ្យសមស្របទៅតាមសភាពការណ៍នយោបាយសេដ្ឋកិច្ចភូមិសាស្ត្រប្រជាសាស្ត្រដែលមានការវិវត្តន៍ឥតឈប់ឈរ សំដៅធ្វើយ៉ាងណាឲ្យការបោះឆ្នោតកាន់តែមានលក្ខណៈល្អប្រសើរឡើង ហើយសមាសភាព គ.ជ.ប ក៏ត្រូវបានកែសម្រួល និងផ្លាស់ប្តូរជាបន្តបន្ទាប់ដែរ ។ ពីឆ្នាំ ២០០២-២០០៦ សមាជិក គ.ជ.ប ត្រូវបានកែសម្រួលពី ១១ រូបមកត្រឹម៥រូបក្នុងនោះមានស្ត្រី ២ រូប ។ ពីឆ្នាំ ២០០៦-២០១២ សមាជិក គ.ជ.ប ត្រូវបានកែសម្រួលពី៥រូបទៅ៩រូបក្នុងនោះមានស្ត្រី២រូប។ ពីឆ្នាំ២០១២-២០១៥សមាជិកគ.ជ.ប មានចំនួន៩រូបក្នុងនោះស្ត្រី១រូប។ក្នុងរយៈពេល១៧ឆ្នាំនេះ ការបោះឆ្នោតត្រូវបានអនុវត្តយ៉ាងទៀងទាត់ចំនួន១២លើក ទាំងសកលនិងអសកល បានទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់ឃុំ សង្កាត់ ដោយទទួលបាននូវការវាយតម្លៃជាមូលដ្ឋានពីសាធារណមតិជាតិ និងអន្តរជាតិថា ការបោះឆ្នោតនីមួយៗប្រព្រឹត្តទៅដោយសេរី យុត្តិធម៌ និងគ្មានការគំរាមកំហែង ។

គ.ជ.បថ្មីដែលបានប្រសូតឡើងនាពេលនេះ នឹងបំពេញភារកិច្ចដ៏ឧត្តុង្គឧត្តមរបស់ខ្លួន ដោយឈរយ៉ាងរឹងមាំលើមូលដ្ឋានច្បាប់ ក្តាប់ជាប់បទពិសោធន៍ទាំងឡាយពីការបោះឆ្នោតមុន ហើយធ្វើការរួមគ្នាយ៉ាងស្មោះស្ម័គ្រដោយមិនលម្អៀងតាមនិន្នាការនយោបាយណាមួយ ដែលឆ្លើយតបទៅនឹងការជឿទុកចិត្តរបស់ប្រជាជាតិទាំងមូល គ្រប់គណបក្សនយោបាយ គ្រប់មជ្ឈដ្ឋានក្នុងសង្គម ក៏ដូចសហគមន៍អន្តរជាតិ ៕

# រដ្ឋសភា បោះឆ្នោតជ្រើសតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតថ្មី ដែលមាន ៩ រូប





*រដ្ឋសភា បោះឆ្នោតជ្រើសតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតថ្មី ដែលមាន ៩ រូប*

កាលពីព្រឹកថ្ងៃទី ០៩ ខែមេសា ឆ្នាំ ២០១៥ សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតថ្មី ហៅកាត់ថា គ.ជ.ប ចំនួន ០៩ រូប ដែលកើតចេញពីការព្រមព្រៀងគ្នា រវាងគណបក្សនយោបាយក្នុងរដ្ឋសភានីតិកាលទី ៥ ត្រូវបានរដ្ឋសភាបោះឆ្នោតផ្ដល់សេចក្ដីទុកចិត្តដោយសំឡេងគាំទ្រចំនួន ១១៣ សំឡេងនៃវត្តមានចំនួន ១១៧ រូប ។

ការបោះឆ្នោតជ្រើសតាំងនេះ បានធ្វើឡើងដឹកនាំដោយសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងមានវត្តមានសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** អនុប្រធានគណបក្សប្រជាជនកម្ពុជា និងឯកឧត្តម **សម រង្ស៊ី** ប្រធានគណបក្សសង្គ្រោះជាតិ និងជាប្រធានក្រុមសភាភាគតិច ។

ជាលទ្ធផលប្រធាន គ.ជ.ប ថ្មី គឺឯកឧត្តម **ស៊ិក ប៊ុនហុក** ចំណែកអនុប្រធាន គឺឯកឧត្តម **គួយ ប៊ុនរឿន** ។ ដោយឡែកសមាជិក សមាជិកាចំនួន០៧ រូបទៀតរួមមាន ឯកឧត្តម **មាន សទិ** ឯកឧត្តម **រ៉ុង ឈុន** ឯកឧត្តម **ឌុច សុន** ឯកឧត្តម **ហ៊ីង ធីឫទ្ធិ** ឯកឧត្តម **ឯម សូផាត** លោកជំទាវ **តែ ម៉ានីរ៉ុង** និងឯកឧត្តម **ហាង្ស ពុទ្ធា** ។ តាមច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.ប ដែលអនុម័តកាលពីពេលថ្មីៗនេះ គឺប្រធាន គ.ជ.ប មានឋានៈ និងបុព្វសិទ្ធិស្មើឧបនាយករដ្ឋមន្ត្រី អនុប្រធានមានឋានៈ និងបុព្វសិទ្ធិស្មើទេសរដ្ឋមន្ត្រី ។ ចំណែកសមាជិក ៧ រូបទៀតមានឋានៈ និងបុព្វសិទ្ធិស្មើរដ្ឋមន្ត្រី ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតថ្មី (គ.ជ.ប) ដែលត្រូវបោះឆ្នោតជ្រើសតាំងដោយរដ្ឋសភានេះ គឺជាសារ និងជាកាដូឆ្នាំថ្មីចំពោះប្រជាពលរដ្ឋកម្ពុជា ។ ក្រោយការបោះឆ្នោតជ្រើសតាំង គ.ជ.ប ថ្មី សម្ដេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានមានប្រសាសន៍ក្នុងកិច្ចសម្ភាសន៍រួមជាមួយឯកឧត្តម **សម រង្ស៊ី** ថា អ្វីដែលឯកឧត្តម **សម រង្ស៊ី** ហើយនិងសម្ដេចបង្កើតឡើងនូវវប្បធម៌សន្ទនាដោះស្រាយបញ្ហាពិតជាទទួលផលប្រយោជន៍ ។ ថ្ងៃនេះជាសក្ខីភាពជាក់លាក់បង្ហាញពីជោគជ័យនៃវប្បធម៌សន្ទនានោះឯង ហើយក៏កាន់តែបង្ហាញបញ្ជាក់ថា ខ្មែរមានលទ្ធភាពដោះស្រាយបញ្ហារបស់ខ្លួន ដោយមិនចាំបាច់ឱ្យមានការជ្រៀតជ្រែកពីសំណាក់ខាងក្រៅ ឬក៏ទៅពឹងពាក់ខាងក្រៅឱ្យដោះស្រាយបញ្ហារបស់ខ្លួនទេ ប្រសិនបើខ្មែរមានស្មារតីដូចដែលសម្ដេច និងឯកឧត្តម **សម រង្ស៊ី** បានធ្វើកន្លងទៅ ។

សម្ដេចតេជោមានប្រសាសន៍ថា ឥឡូវនេះយើងមានការជឿជាក់យ៉ាងដូច្នេះវប្បធម៌សន្ទនា និងការដោះស្រាយបញ្ហាទាំងឡាយគឺនឹងបន្តឆ្ពោះទៅមុខទៀត មិនត្រឹមតែមេដឹកនាំប៉ុណ្ណោះទេ ក៏ប៉ុន្តែនឹងពង្រីកទៅដល់មូលដ្ឋាន ពង្រីកទៅដល់ស្រទាប់អ្នកគាំទ្រ និងពង្រីកទៅដល់អ្នកដែលមានជំនឿនយោបាយខុសៗគ្នា និងជំនឿសាសនាខុសៗគ្នាថែមទៀតផង ។

សម្ដេចតេជោបានឱ្យដឹងថា នៅថ្ងៃទី ០៩ ខែមេសា ឆ្នាំ ២០១៥ នេះ ព្រះរាជក្រឹត្យស្ដីពីការបង្កើត គ.ជ.ប ថ្មី ត្រូវបានសម្ដេចចៅហ្វាវាំង **គង់ សំអុល** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំងនាំយកទៅកាន់ទីក្រុងប៉េកាំង ដើម្បីថ្វាយ**ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ឡាយព្រះហស្ដលេខាដោយផ្ទាល់ ។ បន្ទាប់ពី**ព្រះករុណា ព្រះមហាក្សត្រ** ឡាយព្រះហស្ដលេខារួចហើយនៅថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១៥ ប្រធាន អនុប្រធាន និងសមាជិក សមាជិកាទាំង ០៩ រូបនឹងចូលស្បថកាន់តំណែង ហើយនៅថ្ងៃចន្ទទី ១៣ ខែមេសា នឹងមានរៀបចំពិធីផ្ទេរតំណែងរវាង គ.ជ.ប ចាស់ និង គ.ជ.ប ថ្មី នៅឯទីស្នាក់ការកណ្ដាល គ.ជ.ប ។

គួរបញ្ជាក់ដែរថាកាលពីថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៤ ថ្នាក់ដឹកនាំកំពូលរបស់គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិបានព្រមព្រៀងគ្នាធ្វើការកែទម្រង់ការបោះឆ្នោត ដោយក្នុងនោះបានឯកភាពកំណត់សមាសភាពថ្នាក់ដឹកនាំ គ.ជ.ប ចំនួន ៩ រូប ដែលមកពីគណបក្សដឹកនាំរដ្ឋាភិបាល ៤ រូប គណបក្សមានអាសនៈក្នុងរដ្ឋសភាក្រៅរដ្ឋាភិបាល ៤ រូប និង ១ រូបទៀតជាបុគ្គលមកពីស្ថាប័នឯករាជ្យ ស្របតាមកិច្ចព្រមព្រៀងរបស់គណបក្សមានអាសនៈក្នុងរដ្ឋសភា ៕

# ស្ពានមេគង្គស្ទឹងត្រែង ផ្លូវជាតិលេខ ៩ និងស្ពានឥន្ទ្របាសា ជាសម្បត្តិមហាសាល របស់ប្រជាជនកម្ពុជា ត្រូវបានសម្ពោធដាក់ឲ្យប្រើប្រាស់ក្នុងខែមេសានេះ



*សម្តេចតេជោ **ហ៊ុន សែន** កាត់ខ្សែបូសម្ពោធដាក់ឲ្យប្រើប្រាស់ស្ពានមិត្តភាពកម្ពុជា ចិន ស្ទឹងត្រែង និងផ្លូវជាតិលេខ ៩*

នៅក្នុងខែមេសា ឆ្នាំ២០១៥ កន្លងទៅនេះសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានបំពេញការងារជាច្រើន ទាំងក្នុង និងក្រៅប្រទេសក្នុងនោះក៏មានការអញ្ជើញសម្ពោធសមិទ្ធិដែលមានតម្លៃមហាសាលមួយចំនួនផងដែរ ។

❋ថ្ងៃទី១ ខែមេសា ឆ្នាំ ២០១៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានអញ្ជើញសម្ពោធដាក់ឲ្យប្រើប្រាស់ស្ពានមិត្តភាពកម្ពុជា ចិន ស្ទឹងត្រែង និងផ្លូវជាតិលេខ ៩ ។

នាឱកាសសនោះ ប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានអះអាងថាការរីកចម្រើនរបស់កម្ពុជា ពិតជាមិនអាចកាត់ផ្តាច់ចេញពីការជួយឧបត្ថម្ភរបស់ដៃគូអភិវឌ្ឍន៍ ដែលក្នុងនោះប្រទេសចិនបានដើរតួនាទីស្នូលក្នុងការធ្វើឲ្យសេដ្ឋកិច្ចកម្ពុជាមានការរីកចម្រើន។ សម្តេចបានរំលឹកថា មិត្តចិនបានពង្រីកជំនួយជួយដល់កម្ពុជាកាន់តែមានទំហំធំ ពិសេសជំនួយឥតសំណងកម្ចីសម្បទាន និងទុនវិនិយោគ ដើម្បីការស្តារហេដ្ឋារចនាសម្ព័ន្ធនានា ដូចជាផ្លូវ ថ្នល់ ស្ពាន ប្រឡាយទឹក និងវារីអគ្គិសនី។ ជាក់ស្តែងទំនប់វារីអគ្គិស-នីសេសាន ២ នឹងត្រូវស្ថាបនាឲ្យរួចរាល់នៅឆ្នាំ ២០១៧ ដោយត្រូវធ្វើឲ្យបានត្រឹមត្រូវទាំងបរិស្ថាន និងការរស់នៅរបស់ប្រជាពលរដ្ឋនៅជុំវិញតំបន់នោះ ។

សម្តេចបញ្ជាក់ថា ជំនួយរបស់ចិនបានកើនឡើងជារៀងរាល់ឆ្នាំ។ នៅឆ្នាំ២០១៤ចិនបានបង្កើនជំនួយដល់កម្ពុជាចំនួន ៧០០ លានយន់ ស្មើនឹងប្រមាណ១១៥លានដុល្លារអាមេរិកហើយនៅឆ្នាំ២០១៥នេះចិនបានផ្តល់ជំនួយឥតសំណងដល់កម្ពុជាចំនួន ១.០០០ លានយន់ ស្មើនឹងប្រមាណ ១៦៥ លានដុល្លារ ប្រើប្រាស់សម្រាប់វិស័យកីឡា និងសុខាភិបាល និងបញ្ហាសង្គម ដែលក្នុងនោះ ចិនជួយកសាងមន្ទីរពេទ្យដ៏ធំមួយនៅខេត្តត្បូងឃ្មុំ និងពហុកីឡដ្ឋានដ៏ធំមួយសម្រាប់ការប្រកួតស៊ីហ្គេមនៅឆ្នាំ ២០២៣ ។

សម្តេចតេជោបានបន្តថា អ្វីដែលកម្ពុជាកំពុងប្រើប្រាស់សម្រាប់ស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធឡើងវិញនៅពេលនេះ មានជំនួយឥតសំណង ឥណទានគ្មានការប្រាក់ កម្ចីសម្បទាន និងការវិនិយោគឯកជនមកពីប្រទេសចិន ។ ប្រភពទុនទាំងបួននេះមានសារសំខាន់ណាស់សម្រាប់អភិវឌ្ឍន៍ព្រះរាជាណាចក្រកម្ពុជា ។ សម្តេចបានអរគុណប្រទេសចិនដែលបានខិតខំជួយតភ្ជាប់បណ្តាញផ្លូវក្នុងប្រទេសកម្ពុជា និងតភ្ជាប់ប្រទេសជិតខាងកម្ពុជា ។

ជាមួយនឹងការកកើតឡើងនូវសំណង់ជាប្រវត្តិសាស្ត្រនេះ សម្តេចតេ-ជោនាយករដ្ឋមន្ត្រីមានប្រសាសន៍ថា រាជរដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជាពិតជាមានមោទនភាពចំពោះសមិទ្ធផលជាប្រវត្តិសាស្ត្រនេះ ដោយសារតែសំណង់នេះវាបានកសាងហើយរួចរាល់ជាស្ថាពរនៅឆ្នាំ ២០១៥ ពោល គឺវាស្របគ្នាទៅនឹងការបង្កើតឡើងនូវសហគមន៍អាស៊ាននៅឆ្នាំ ២០១៥ ។ សម្តេចបន្តថា បន្ទាប់ពីសាងសង់រួចផ្លូវជាតិលេខ ៩ ពិសេសស្ពានមិត្តភាពកម្ពុជា ចិនស្ទឹងត្រែង នឹងបង្កលក្ខណៈងាយស្រួលបន្ថែមទៀតក្នុងការទំនាក់ទំនង និងការធ្វើដំណើររវាងខេត្តស្ទឹងត្រែង និងខេត្តព្រះវិហារ និងតភ្ជាប់ភូមិភាគខាងលិច និងខាងជើងជាមួយភូមិភាគឦសាន និងខាងកើតប្រទេសតភ្ជាប់ខេត្តរតនគិរី ខេត្តស្ទឹងត្រែង និងខេត្តព្រះវិហារ និងអាចបន្តឆ្ពោះទៅខេត្តសៀមរាប-អង្គរ ដែលជាតំបន់ទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រដ៏រុងរឿងរបស់កម្ពុជា ។

លោកជំទាវ **ពូ ចៀនគ័រ**( Bu Jianguo )ឯកអគ្គរដ្ឋទូតនៃសាធារណ-រដ្ឋប្រជាមានិតចិនប្រចាំកម្ពុជាមានប្រសាសន៍ថា ផ្លូវស្ពានដែលយើងកសាងនៅពេលនេះមានសារសំខាន់ខ្លាំងណាស់ក្នុងការធ្វើសមាហរណ-កម្មតំបន់នេះជាមួយនឹងតំបន់ដទៃទៀត ពិសេសជាមួយនឹងប្រទេសជិតខាង ក៏ដូចជាបណ្តាប្រទេសក្នុងតំបន់។ ប្រទេសចិននឹងបន្តជួយគាំទ្រដល់ប្រទេសកម្ពុជាតាមលទ្ធភាពដែលអាចធ្វើទៅបាន ពិសេសទៅលើការកសាងហេដ្ឋារចនាសម្ពន្ធ័រូបវ័ន្ត ដូចជាផ្លូវ ស្ពាន ថាមពលអគ្គិសនី ទូរគមនា-គមន៍ និងប្រពន្ធ័ធារាសាស្រ្ត ។

សូមបញ្ជាក់ថា ការដ្ឋានសាងសង់ផ្លូវលេខ ៩ ប្រវែងសរុប ១៤៣,៤១ គីឡូម៉ែត្រ ដោយបំបែកពីគីឡូម៉ែត្រលេខ ១៣០ នៃផ្លូវជាតិលេខ ៦២ ក្នុងភូមិស្ថាពរ សង្កាត់ប៉ាលហាល ក្រុងព្រះវិហារ ខេត្តព្រះវិហារ ទៅដល់គីឡូ-ម៉ែត្រលេខ ៤៥៨ នៃផ្លូវជាតិលេខ ៧ ភូមិរាជានុកូល សង្កាត់ស្ទឹងត្រែង ខេត្តស្ទឹងត្រែង ។ ផ្លូវនេះមានទទឹងសរុប ៩ ម៉ែត្រ ផ្ទៃនៃទ្រូងផ្លូវជាប្រភេទកម្រាលថ្ម ស្រោចកៅស៊ូពីរស្រទាប់ DBST មានទទឹង ៧ ម៉ែត្រ មានសាងសង់ស្ពាន ២៥ កន្លែង ប្រវែងសរុប៩៤៦ម៉ែត្រ និងស្ពានមិត្តភាពកម្ពុជាចិនស្ទឹងត្រែងឆ្លងទន្លេមេគង្គមានប្រវែងសរុប ១៧៣១ ម៉ែត្រ ទទឹងសរុប ១៣,៥០ ម៉ែត្រ មានគន្លងផ្លូវ ២ សម្រាប់រថយន្ត។ គន្លងនីមួយៗមានទទឹង



*ស្ពានមិត្តភាពកម្ពុជា ចិន ស្ទឹងត្រែង និងផ្លូវជាតិលេខ ៩ ដែលត្រូវបានសម្ពោធដាក់ឲ្យប្រើប្រាស់*



*សម្តេចតេជោ **ហ៊ុន សែន** កាត់ខ្សែបូសម្ពោធដាក់ឲ្យប្រើប្រាស់ស្ពាន ត្សឹបាសា(ស្ពានអ្នកលឿង)*

៣,៥០ ម៉ែត្រ។ គន្លងពីរសម្រាប់ទោចក្រយានយន្តគន្លងនីមួយៗមានទទឹង ១,១០ ម៉ែត្រ (និងរបារបង្កាន់ដៃស្ពានទទឹង០,២៥ម៉ែត្រសងខាង)។

សមិទ្ធិនេះចំណាយថវិកាសរុបប្រមាណ១១៦,៥ លានដុល្លារអាមេរិក ដែលជាថវិកាកម្ចីឥណទានសម្បទានពីរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន រួមជាមួយថវិកាបដិភាគរាជរដ្ឋាភិបាលកម្ពុជាមួយចំនួនបន្ថែមទៀតសម្រាប់ដោះស្រាយផលប៉ះពាល់ ។ ការដ្ឋាននេះចាប់ផ្តើមសាងសង់នៅថ្ងៃទី ១៥ ខែមេសា ឆ្នាំ២០១២ ។ រយៈពេលសាងសង់ ៤៥ ខែ។

❋ព្រឹកថ្ងៃទី ៥ ខែមេសាឆ្នាំ ២០១៥ សម្តេចតេជោ **ហ៊ុន សែន** បានអញ្ជើញចូលរួមសម្ពោធអគារផ្កាម្លិះគាំទ្រចិត្តសាស្ត្រសង្គមសាខាកាកបាទក្រហមកម្ពុជារាជធានីភ្នំពេញ និងពិធីរៀបចំអាហារជូនកុមារពិការភ្នែក គថ្លង់ ដែលជាទម្លាប់ មួយឆ្នាំ ២ ដងនៅសាលាកុមារពិការភ្នែក គ ថ្លង់ភ្នំពេញពេញថ្មីក្នុងខណ្ឌសែនសុខរាជធានីភ្នំពេញ។ នាពេលនោះសម្តេចបានថ្លែងទាក់ទងដល់ច្បាប់ស្តីពីការគ្រប់គ្រងអង្គការក្រៅរដ្ឋាភិបាល ។

សម្តេចបានមានប្រសាសន៍ថា នៅពេលខាងមុខនេះវាចាំបាច់ណាស់ដែលត្រូវធ្វើច្បាប់ស្តីពីការគ្រប់គ្រងអង្គការក្រៅរដ្ឋាភិបាល (NGO) បើទោះបីជាអ្នកវិភាគឯករាជ្យរបស់ NGO មួយបាននិយាយថាខ្លួនមិនឯកភាពក៏ដោយ។ សម្តេចបញ្ជាក់ថា លោកមិនឯកភាពក៏មិនមែនជារឿងរបស់លោកទេតែវាជារឿងរដ្ឋសភា របស់រាជរដ្ឋាភិបាលទេ។ ចង់ឯកភាពមិនឯកភាពចាំលោកឈ្នះឆ្នោតសិន ហើយលុបច្បាប់ហ្នឹងចោលទៅ ។ សម្តេចបន្តថានេះសិទ្ធិរបស់រាជរដ្ឋាភិបាល សិទ្ធិរបស់រដ្ឋសភាហើយសូមបញ្ជាក់ថាពេលវេលានៃការអនុម័តច្បាប់នេះគឺមិនហួសពីខែឧសភាទេ ព្រោះច្បាប់នេះបានដាក់ចូលគណៈរដ្ឋមន្ត្រីរួចហើយ ។ ពេលដាក់ចូលទៅរដ្ឋសភាចង់អ្នកណាគាំទ្រ ឬមិនគាំទ្រក៏ដោយ តែសំឡេងរបស់សមាជិកសភាដែលមានសិទ្ធិអនុម័ត៥០ភាគរយបូក១គឺគ្រប់គ្រាន់ដើម្បីអនុម័តហើយ។សម្តេចបញ្ជាក់ថា NGO យកល្អផ្តល់យោបល់ប្រសើរជាជាងទប់ស្កាត់មិនឱ្យច្បាប់នេះចេញ ។ សូមកុំខ្លាចបើយើងមានតម្លាភាពត្រូវហ៊ានដាក់លើតុនិយាយគ្នា។ សម្តេចបន្តថាឥឡូវខ្ញុំគ្រាន់តែសុំសួរថាមូលហេតុអ្វីបានអ្នកខ្លាចច្បាប់នេះ? ឬមានអាថ៌កំបាំងអីពីក្រោយខ្នង ។ យើងមិនមែនធ្វើច្បាប់ដើម្បីរាំងសកម្មភាព NGO ទេប៉ុន្តែយើងចង់ឱ្យអ្នកមានតម្លាភាពជាមួយនឹងប្រទេសមួយដែរ ។ បរទេសបញ្ជូនលុយមកជួយ NGO ជួយទៅធ្វើអ្វីសូមបញ្ចេញរបាយការណ៍មកឱ្យរាជរដ្ឋាភិបាលមានសិទ្ធិចុះពិនិត្យមើល។បើចាយមិនត្រូវខ្វង់តើវាយ៉ាងម៉េច? ។ NGO ចេះតែឱ្យខាងរាជរដ្ឋាភិបាលពិនិត្យគ្រប់សព្វ, សភាពិនិត្យសព្វគ្រប់ចុះខ្លួនឯង? ។

សម្តេចបន្តថា ប្រទេសណាក៏មានច្បាប់ដែរគ្រាន់តែអកុសលប្រទេសខ្មែរយើងឱ្យតែនិយាយដល់ត្រង់ហ្នឹងមិនមានតម្លាភាពទេ។ដូច្នេះត្រូវតែឱ្យច្បាស់។ តើប្រភពលុយបានមកពីណា?តាមសម្តេចដឹងខ្លះៗNGOខ្លះដែលស៊ីលុយបរទេសមុននឹងនិយាយត្រូវយកចូលទៅស្ថានទូតចំនួន២ថ្ងៃ។ ស្ថានទូតផ្តល់មតិទើបNGOមានសិទ្ធិនិយាយ។ បើដូច្នេះប្រទេសនេះត្រូវញ៉ាំញីដោយការបំពានអធិបតេយ្យ។

គួរបញ្ជាក់ថា បើយោងតាមរបាយការណ៍របស់ក្រសួងមហាផ្ទៃស្តីពីលទ្ធផលការងារឆ្នាំ២០១៤ឲ្យដឹងថា មកដល់បច្ចុប្បន្នសមាគមអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជីនៅក្រសួងមានចំនួនសរុប៤៣៧៨(សមាគម១៧០៦,អង្គការមិនមែនរដ្ឋាភិបាល២៦៧២)។ នៅក្នុងឆ្នាំ២០១៤នេះដែរក្រសួងមហាផ្ទៃ បានចុះបញ្ជីសមាគមអង្គការមិនមែនរដ្ឋាភិបាលចំនួន៥៣៩(សមាគម ១៧៧ និងអង្គការមិនមែនរដ្ឋាភិបាល ៣៦២)។

❋ព្រឹកថ្ងៃទី ៦ ខែមេសា សម្តេចតេជោ រួមជាមួយលោក **អាគីហ៊ីរ៉ូ នីស៊ីមូរ៉ា** អនុរដ្ឋមន្ត្រីក្រសួងដែនដីហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូន និងទេសចរណ៍ជប៉ុន បានអញ្ជើញសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវស្ពានត្សឹបាសា(ស្ពានអ្នកលឿន)ក្រោមការអបអរយ៉ាងក្រៃលែង ពីសំណាក់ប្រជាពលរដ្ឋកម្ពុជាទូទាំងប្រទេស ។

ថ្លែងក្នុងពិធីនេះ សម្តេចតេជោបានចាត់ទុកសំណង់ស្ពាននេះថា ជាសមិទ្ធផលជាទ្រព្យសម្បត្តិមហាសាលថ្មីមួយទៀតរបស់ប្រទេសនិងប្រជាជនកម្ពុជា ដែលនឹងរួមចំណែកដល់ការជំរុញកំណើនសេដ្ឋកិច្ចរបស់ប្រជាជនកម្ពុជា ។ សម្តេចក៏បានរំលឹកដែរថា ជប៉ុនមិនត្រឹមតែបានចូលរួមចំណែកក្នុងការតភ្ជាប់បណ្តាញគមនាគមន៍នៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែបានតភ្ជាប់បណ្តាញក្នុងក្របខ័ណ្ឌក្នុងមហាអនុតំបន់មេគង្គ និងក្នុងក្របខ័ណ្ឌអាស៊ានហាយវេផងដែរ ។ សម្តេចបញ្ជាក់ថា ស្ពានត្សឹបាសា គឺជាសមិទ្ធផលដ៏មហាសាល ដែលមិនត្រឹមតែបម្រើវិស័យដឹកជញ្ជូនសម្រាប់ព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះទេ តែអាចសម្រួលដល់ការតភ្ជាប់ក្នុងតំបន់ថែមទៀតផង ព្រោះស្ពាននេះស្ថិតលើគន្លងនៃផ្លូវហាយវេអាស៊ីទី ១ និងរបៀងសេដ្ឋកិច្ចខាងត្បូងនៃមហាអនុតំបន់មេគង្គដែលភ្ជាប់ពីទីក្រុងហូជីមិញ(ប្រទេសវៀតណាម) រាជធានីភ្នំពេញ និងទីក្រុងបាងកក (ប្រទេសថៃ)។ ស្ពាននេះនឹងរួមចំណែកយ៉ាងធំធេងក្នុងការលើកកម្ពស់កំណើនសេដ្ឋកិច្ចកម្ពុជា ពិសេសស្របពេលនឹងការធ្វើសមាហរណកម្មសេដ្ឋកិច្ចអាស៊ាននាចុងឆ្នាំ ២០១៥ ខាងមុខ ។

គួរបញ្ជាក់ថា ស្ពានត្សឹបាសា(ស្ពានអ្នកលឿង)តភ្ជាប់ផ្លូវជាតិលេខ ១ ត្រង់ព្រំប្រទល់នៃខេត្តកណ្តាល និងខេត្តព្រៃវែង ។ ស្ពាននេះបានសាងសង់លើគន្លងផ្លូវថ្មី ដោយចាប់ផ្តើមបែកចេញពីខាងឆ្វេងដៃត្រង់ចំណុចគីឡូម៉ែត្រលេខ ៥៨ ក្នុងភូមិអំពិលទឹក ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល និងភ្ជាប់ទៅផ្លូវជាតិលេខ១ត្រើយខាងកើតវិញត្រង់ចំណុចគីឡូម៉ែត្រលេខ ៦២ ក្នុងភូមិលេខមួយ ឃុំព្រែកខ្សាយ "ខ" ស្រុកពាមរក៍ ខេត្តព្រៃវែង ។ ស្ពាននេះកាត់តាមភូមិចំនួន ៥ នៃឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល ហើយឆ្លងទៅស្រុកពាមរក៍ ខេត្តព្រៃវែង ដោយកាត់តាមភូមិព្រែកខ្សាយនិងភូមិឧត្តម ក្នុងឃុំព្រែកខ្សាយ "ក" ហើយចុងបញ្ចប់តភ្ជាប់ទៅផ្លូវជាតិលេខ១វិញត្រង់ភូមិលេខ១ក្នុងឃុំព្រែកខ្សាយ "ខ" ។ប្រវែងសរុបរបស់ស្ពាន ៥៤០០ ម៉ែត្រ ដែលបង្គុំឡើងដោយកំណាត់ជាតួស្ពានប្រវែង ២២១៥ ម៉ែត្រ និងកំណាត់ជាផ្លូវតភ្ជាប់ក្បាលស្ពានប្រវែង ៣១៨៥ ម៉ែត្រ (ត្រើយខាងលិច

ប្រវែង ៨៤០ ម៉ែត្រ និងត្រើយខាងកើតទន្លេប្រវែង ២៣៤៥ ម៉ែត្រ )។ ទឹកប្រាក់សរុបសម្រាប់ការសាងសង់ចំនួន ១១,៩៤ ពាន់លានយ៉េន ឬប្រហាក់ប្រហែលនឹង ១២៧ លានដុល្លារអាមេរិក ។

គម្រោងសាងសង់ស្ពានអនុវត្តដោយក្រុមហ៊ុនសំណង់ ស៊ូមីតូម៉ុមីត-ស៊ុយ ( Sumitomo Mitsui Construction Co., Ltd ) និងត្រួតពិនិត្យបច្ចេក-ទេសដោយក្រុមហ៊ុន ចូដាយ សហការជាមួយក្រុមហ៊ុនអូរីយ៉ង់តាល់( Cho dai Co., Ltd and Oriental Consultant Co., Ltd ) របស់ប្រទេសជប៉ុន ។

✵រសៀលថ្ងៃទី៨ខែមេសាសម្ដេចតេជោបានអញ្ជើញចូលរួមបិទសន្និ-បាតបូកសរុបការងារកសិកម្មនៅវិទ្យាស្ថានជាតិអប់រំ ។ នាពេលនោះ សម្ដេចបានថ្លែងទាក់ទងទៅដល់ក្រុមហ៊ុនដែលទទួលបាននូវដីសម្បទានសេដ្ឋកិច្ចហើយមិនអនុវត្តបានត្រឹមត្រូវតាមគម្រោង ។

សម្ដេចតេជោមានប្រសាសន៍ថា បញ្ហាដីសម្បទានសេដ្ឋកិច្ច គឺត្រូវតែបន្តត្រួតពិនិត្យ និងដកហូតត្រឡប់មកវិញហើយការដកហូតត្រឡប់មកវិញនេះ មិនមែនគ្រាន់តែដកហូតអាជ្ញាប័ណ្ណដកហូតដីត្រឡប់មកវិញហើយចប់នោះទេ ត្រូវតែមានការទាមទារសំណងត្រឡប់មកវិញដូចការកាប់ព្រៃឈើនៅក្នុងផ្ទៃដីសម្បទានលក់ជាដើម។ បើមិនដូចនេះទេ ហាក់ដូចជារាជរដ្ឋាភិបាលចាញ់ប្រៀបក្រុមហ៊ុនឯកជនខ្លាំងពេក ព្រោះពេលដែលក្រុមហ៊ុនសុំវិនិយោគលើដីសម្បទាន ពួកគេរកតែដីដែលមានព្រៃឈើ និងដីដែលប្រជាជនកាប់រានហើយដើម្បីស្រួលពួកគេកាប់ព្រៃឈើលក់ និងយកដីប្រជាពលរដ្ឋដែលរានហើយ ដោយមិនបាច់ចំណាយលើការកាប់រានបន្តទៀត ។ ដូចនេះអាជ្ញាធរក៏ត្រូវត្រួតពិនិត្យលើបញ្ហានេះដែរ មិនត្រូវឲ្យក្រុមហ៊ុនរួចខ្លួនដោយស្រួលៗនោះទេ ។

គួររំលឹកថា កន្លងមកក្រសួងកសិកម្មបានដកហូតដីពីក្រុមហ៊ុនឯកជនចំនួន ៨ ក្រុមហ៊ុនត្រឡប់មកវិញ ដែលមានផ្ទៃដីប្រមាណ ១៧ ម៉ឺនហិកតា និងក្រសួងបរិស្ថានបានដកហូតដីសម្បទានសេដ្ឋកិច្ច ពីក្រុមហ៊ុនចំនួន ២៣ ដែលមានផ្ទៃដីជាង ១០ ម៉ឺនហិកតា តែក្រុមហ៊ុនដែលត្រូវបានដកហូតត្រឡប់មកវិញនោះពុំទទួលពិន័យឬការចាប់ឲ្យសងសំណងអ្វីឡើយ ។

ក្នុងឱកាសនោះដែរសម្ដេចតេជោក៏បានលើកឡើងពាក់ព័ន្ធបទល្មើស



*ស្ពាន ត្សឺបាសា( ស្ពានអ្នកលឿង )ដែលត្រូវបានសម្ពោធដាក់ឲ្យប្រើប្រាស់*

ព្រៃឈើ និងជលផលដែលបញ្ហានេះសម្ដេចបានស្ដីបន្ទោសទៅលើគណៈបញ្ជាការឯកភាពខេត្តទាំងអស់ដែលមានដែននេសាទ និងព្រៃឈើត្រូវយកភ្នែកមើលបទល្មើសព្រៃឈើ ដែលត្រូវបានគេដឹករាល់ថ្ងៃទាំងឡានៗ មានទាំងឡានតូចនិងឡានធំ។ព្រៃឈើឈើធំៗមិនមែនគ្រឿងញៀនទេ។ គ្រឿងញៀនទើបពិបាកនឹងឃើញ តែឈើដឹកទាំងឡានៗអស់លោកឆ្លើយដាក់គ្នាថាអត់ដឹង។ សម្ដេចបន្តថា អំណាចបានផ្ទេរទៅឲ្យថ្នាក់ក្រោមជាតិ គឺមានន័យថាអស់លោកមានសិទ្ធិអំណាចគ្រប់គ្រាន់ហើយ ដូចនេះមិនចាំ-បាច់រង់ចាំមានអនុសាសន៍របស់នាយករដ្ឋមន្ត្រីទើបធ្វើនោះទេ ។ សម្ដេចបានណែនាំមន្ត្រីឲ្យធ្វើការងារអ្វីតាមច្បាប់ដែលបានកំណត់ ។ សម្ដេចសង្កត់ធ្ងន់ថា សម្ដេចមិនចង់ឮពាក្យដែលលើកឡើងថាតាមអនុសាសន៍របស់នាយករដ្ឋមន្ត្រីទេ ។

រាល់ប្រសាសន៍ដ៏តម្លៃ ដែលសម្ដេចតេជោនាយករដ្ឋមន្ត្រីបានលើកឡើងខាងលើ បានឆ្លុះបញ្ចាំងច្បាស់នូវជំហរដ៏រឹងមាំប្រកបដោយការទទួលខុសត្រូវខ្ពស់បំផុតរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក្នុងការដឹកនាំអភិវឌ្ឍប្រទេសតាមមាគ៌ាប្រជាធិបតេយ្យ និងនីតិរដ្ឋ ៕





**សូមគោរពឯកឧត្ដម លោកជំទាវ និងប្រិយមិត្តអ្នកអានជាទីគោរព**

**សូមចូលមក Facebook Page : Pracheachun Magazine-ទស្សនាវដ្ដីប្រជាជន**

**ហើយចុច Like និង Share ដើម្បីទទួលបានព័ត៌មានសំខាន់ៗប្រចាំថ្ងៃ ព្រមទាំងផ្ដល់ទស្សនៈ ឬ មតិផ្សេងៗ**

# សម្តេចតេជោ ហ៊ុន សែន អញ្ជើញចូលរួមវេទិកាសេដ្ឋកិច្ចពិភពលោកស្តីពីអាស៊ីបូព៌ាលើកទី ២៤ កិច្ចប្រជុំកំពូលអាស៊ីអាហ្វ្រិក ពិធីរំលឹកខួបអនុស្សាវរីយ៍លើកទី ៦០ នៃសន្និសីទទីក្រុងបាន់ឌុង នៅប្រទេសឥណ្ឌូនេស៊ី នៃកិច្ចប្រជុំកំពូលអាស៊ានលើកទី ២៦ នៅប្រទេសម៉ាឡេស៊ី

❋នៅល្ងាចថ្ងៃទី២០ខែមេសានៅទីក្រុងហ្សាការតា ថ្នាក់ដឹកនាំទាំងអស់បានគោះជួងជានិមិត្តរូបនៃការប្រារព្ធពិធីបើកវេទិកាសេដ្ឋកិច្ចពិភពលោក ស្តីពីអាស៊ីបូព៌ាលើកទី២៤ ក្រោមប្រធានបទ "អាស៊ីបូព៌ា" នៅក្នុងបរិការណ៍សកលថ្មី ។ ចូលរួមក្នុងវេទិការនេះ ក្រៅពីឥស្សរជននយោបាយថ្នាក់ដឹកនាំប្រទេសក៏នៅមានអង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ធុរជនមកពីវិស័យឯកជនប្រមាណ ៥០០ នាក់ និងអ្នកសារព័ត៌មានជាង ២០០ នាក់ បានចូលរួម។ វេទិកានេះគឺជាវេទិកាសម្រាប់ផ្នែកឯកជន និងផ្នែកសាធារណៈ ដើម្បីកសាងនូវជំនឿទុកចិត្ត និងដើម្បីនាំអាស៊ីបូព៌ាមានអនាគតកាន់តែប្រសើរឡើង។ ឯកឧត្តមបណ្ឌិត **ហ្វីលីព រ៉ូសស្លឺរ** ប្រធានវេទិកាសេដ្ឋកិច្ចពិភពលោកមានប្រសាសន៍ថា ក្នុងរយៈពេល ៤៥ ឆ្នាំចុង ក្រោយនេះ អាស៊ីបូព៌ាមានការផ្លាស់ប្តូរយ៉ាងខ្លាំង តួយ៉ាងដូចជាប្រទេស ឥណ្ឌូនេស៊ី កំណើនសេដ្ឋកិច្ច៦% និងជំរុញឲ្យប្រទេសនេះមានការរីកចម្រើនសម្រាប់តំបន់ទាំងមូលផងដែរ។ ឯកឧត្តម **ចូកូ វីដូដូ** ប្រធានាធិបតីឥណ្ឌូនេស៊ីមានប្រសាសន៍ថា ការប្រឈមរបស់យើង គឺជាឱកាសនៃអ្នកទាំងអស់គ្នាដែលមានវត្តមាននៅទីនេះ និងនៅទីកន្លែងដទៃទៀតនៃពិភពលោក ។ ពិភពលោកកំពុងមានការផ្លាស់ប្តូរ។ ប្រទេសចិន និងជប៉ុន កំពុងមានការផ្លាស់ប្តូរ រីឯប្រទេសឥណ្ឌូនេស៊ីក៏កំពុងមានការផ្លាស់ប្តូរ។ ដើម្បីផ្លាស់ប្តូរទៅបាន គឺយើងត្រូវតែខិតខំជំរុញកំណើនសេដ្ឋកិច្ចរបស់ប្រទេសឥណ្ឌូនេស៊ីឲ្យកាន់តែមានការប្រកួតប្រជែង។ នៅក្នុងវេទិកាសេដ្ឋកិច្ចពិភពលោកនាពេលនេះ ក៏បានកំណត់អំពីរបៀបវារៈអាស៊ីដើម្បីអនាគតមួយ ដែលធានាបាននូវសន្តិសុខស្បៀង។ នៅព្រឹកថ្ងៃទី ២១ ខែមេសា នៅក្នុងវេទិកាដដែលនោះ ក្នុងសុន្ទរកថាគន្លឹះ សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាមានប្រសាសន៍សង្កត់ធ្ងន់ថា កម្ពុជាបានប្រែក្លាយខ្លួនពីប្រទេសមួយដែលខ្វះស្បៀង មកជាប្រទេសដែលមានអតិរេកស្បៀង ហើយអាចចូលរួមចំណែកក្នុងការធានាសន្តិសុខស្បៀងក្នុងតំបន់ និងពិភពលោក។ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ខ្ពស់ទៅលើ វិស័យកសិកម្ម និងបានដាក់ចេញនូវគោលនយោបាយ និងយុទ្ធ-សាស្ត្រជាបន្តបន្ទាប់ដើម្បីអភិវឌ្ឍវិស័យដ៏សំខាន់នេះ។ ជាលទ្ធផល កម្ពុជាផលិតបាន ស្រូវប្រមាណ ១០ លានតោន ក្នុង ១ ឆ្នាំ ដំឡូងមីប្រមាណ ១២ លានតោន ក្នុង១ឆ្នាំនិងពោតជាងកន្លះលានតោនក្នុង១ឆ្នាំ។ជារួមវិស័យកសិកម្មកម្ពុជាកំពុងរង់ចាំការវិនិយោគបន្ថែម ទាំងលើការពង្រីកផលិតកម្ម ក៏ដូចជាលើពិពិធកម្មផលិតផល និងជាពិសេសលើការកែច្នៃដើម្បីបង្កើនតម្លៃបន្ថែម ។

វេទិកាបានចាត់ទុកសន្តិសុខស្បៀង គឺជាបញ្ហាប្រឈមសកលដ៏សំខាន់មួយ ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងការគាំពារសុខភាពជាសកល កំណើនប្រកបដោយបរិយាប័ន្ន និងការកាត់បន្ថយភាពក្រីក្រ ដើម្បីធានាការអភិវឌ្ឍប្រកបដោយចីរភាពរបស់តំបន់ និងពិភពលោក ។ បច្ចុប្បន្ន ពិភពលោកកំពុងបន្តប្រឈមនឹងបញ្ហាកំណើនយ៉ាងឆាប់រហ័សនៃចំនួនប្រជាជន និងភាពមានកម្រិត នៃសមត្ថភាពចិញ្ចឹមរបស់ភពផែនដីរបស់យើង ។ ដូច្នេះ ក្នុងរយៈពេលវែងខាងមុខការខិតខំប្រឹងប្រែង ដើម្បីលើកកម្ពស់ផលិតភាពកសិកម្ម នៅក្នុងបណ្តាប្រទេសដែលមានសក្តានុពលកសិកម្មខ្ពស់ដូចជាកម្ពុជាមីយ៉ាន់ម៉ាថៃនិងវៀតណាមអាចនឹងចូលរួមវិភាគទានយ៉ាងសំខាន់ដល់ការធានាសន្តិសុខស្បៀង ក្នុងតំបន់ និងពិភពលោក តាមរយៈការបង្កើនភាពសម្បូរនៃស្បៀង និងការកាត់បន្ថយថ្លៃ ស្បៀងឱ្យថោកសមរម្យ។ យើងអាចដោះស្រាយបញ្ហាទាំងអស់នោះបានតាមរយៈការផ្លាស់ប្តូរបែបផែននៃការផលិតរបស់កសិករ ពីការផលិតកម្ម តាមបែបបើកទូលាយ ទៅជាផលិតកម្មតាមបែបស៊ីជម្រៅ ឬពីផលិតកម្ម តាមបែបវិបុលកម្មទៅជាផលិតកម្មតាមបែបប្រពលវប្បកម្មពោលគឺការ ផ្លាស់ប្តូរពីការពង្រីកផលិតកម្មតាមរយៈការពង្រីកផ្ទៃដីដាំដុះ ទៅជាការពង្រីកផលិតកម្មតាមរយៈការបង្កើនរដូវដាំដុះ និងការបង្កើនទិន្នផលកសិកម្មនៅលើផ្ទៃដីដែលមានស្រាប់។ នៅក្នុងបទអន្តរាគមន៍របស់វាគ្មិនចូលរួមក៏បានគូសបញ្ជាក់ពីកង្វល់ និងការរិះរកនូវវិធានការរួមចំពោះមុខ ក្នុងការដោះស្រាយលើប្រធានបទគន្លឹះស្តីពីការកំណត់របៀបវារៈអាស៊ី ដើម្បី អនាគតដែលធានាសន្តិសុខស្បៀង ។




*សម្តេចតេជោ **ហ៊ុន សែន** ថ្លែងសុន្ទរកថាគន្លឹះអំពីសន្តិសុខស្បៀង ក្នុងវេទិកាពិភពលោកនៅប្រទេសឥណ្ឌូនេស៊ី*

❋នៅថ្ងៃទី ២១ ខែមេសាដដែលឯកឧត្តម **ហ្វីលីព រ៉ូសស្លឺរ** ប្រធានវេទិកាសេដ្ឋកិច្ចពិភពលោកបានចូលជួបសំដែងការគួរសម និងពិភាក្សាការងារជាមួយសម្តេចតេជោ **ហ៊ុន សែន**។ ពេលនោះឯកឧត្តមបានមានប្រសាសន៍ថារូបលោកចង់ឃើញការរៀបចំវេទិកាសេដ្ឋកិច្ចពិភពលោកនេះទទួលបានជោគជ័យ ក្នុងពេលដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះនៅឆ្នាំ ២០១៦ ខាងមុខនេះ។ សម្តេចតេជោ **ហ៊ុន សែន** បានថ្លែងតបថាសម្តេច នឹងបន្តសហការជាមួយវេទិកាសេដ្ឋកិច្ចពិភពលោក ធ្វើយ៉ាងណាឲ្យវេទិកានេះទទួលបានជោគជ័យនៅក្នុងប្រទេសកម្ពុជានាឆ្នាំ ២០១៦។ សម្តេចតេ-ជោក៏ចង់ឲ្យមានការចូលរួមមិនត្រឹមតែពីប្រទេសឡាវ និងមីយ៉ាន់ម៉ានោះទេ ប៉ុន្តែគឺចង់ឲ្យមានការចូលរួមពីប្រទេសអេកម៉ិក និងមានការចូលរួមពីប្រទេសផ្សេងទៀតផងដែរ ។

❋នៅថ្ងៃទី២២ ខែមេសា សម្តេចតេជោ **ហ៊ុន សែន** បានទទួលជួបពិភាក្សាទ្វេភាគីជាមួយឯកឧត្តម Ibrahim Mahlah នាយករដ្ឋមន្ត្រីអេហ្ស៊ី។ប្រមុខដឹកនាំទាំង២ បានពិភាក្សាយ៉ាងយកចិត្តទុកដាក់ជុំវិញការបើកស្ថានឯកអគ្គរាជទូតរបស់ប្រទេសកម្ពុជានៅក្នុងទីក្រុងគែរ៉ូ ប្រទេសអេហ្ស៊ីប ដើម្បីឲ្យទំនាក់ទំនងការទូត នៃប្រទេសទាំង២កាន់តែរីកចម្រើនទៅមុខ។

ឯកឧត្តម **អ៊ី ប្រាហ៊ីម** មានប្រសាសន៍ថា កន្លងមកប្រទេសយើងទាំងពីរកម្ពុជាអេហ្ស៊ីប មានទំនាក់ទំនងជាមួយគ្នាល្អណាស់ ហើយចាប់ពីពេលនេះតទៅមុខគឺយើងរួមគ្នាធ្វើយ៉ាងណា ឱ្យទំនាក់ទំនងនៃប្រទេសទាំងពីរកាន់តែមានភាពល្អប្រសើរឡើងថែមទៀត ពិសេសធ្វើយ៉ាងណាឱ្យមានទំនាក់ទំនងល្អក្នុងបណ្តាប្រទេសអាស៊ានទាំងមូលផងដែរ។ សម្តេចតេជោនាយករដ្ឋមន្ត្រីមានប្រសាសន៍ថា សម្តេចនឹងខិតខំធ្វើយ៉ាងណាឱ្យទំនាក់ទំនង នៃប្រទេសទាំងពីរមានភាពល្អប្រសើរឡើង។ សម្តេច និងឯកឧត្តមនាយករដ្ឋមន្ត្រីគឺជាអ្នកដឹកនាំជំនាន់ក្រោយ ប៉ុន្តែថ្នាក់



*សម្តេចតេជោ **ហ៊ុន សែន** បានទទួលកិច្ចស្វាគមន៍យ៉ាងស្និទស្នាលកក់ក្តៅ ពីសំណាក់ ឯកឧត្តម **ចូកូ វិដូដូ** ប្រធានាធិបតីនៃប្រទេសឥណ្ឌូនេស៊ី*

ដឹកនាំជំនាន់មុនបានផ្សារភ្ជាប់នូវទំនាក់ទំនងកាលពីអតីតកាលដ៏ល្អ ដូចនេះយើងត្រូវតែរួមគ្នា និងប្តេជ្ញារួមគ្នាក្នុងការបង្កើនទំនាក់ទំនងកិច្ចសហប្រតិបត្តិការ នៃប្រទេសទាំងពីរឱ្យកាន់តែសកម្មថែមទៀត ពិសេសការរួមគ្នាបង្កើនកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ និងការកែប្រែនូវគោលជំហរមួយចំនួនទាក់ទិនទៅនឹងបញ្ហាអន្តរជាតិមួយចំនួន ពិសេស ការផ្លាស់ប្តូរនូវការគាំទ្រគ្នាទៅវិញទៅមក។ សម្តេចតេជោនាយករដ្ឋមន្ត្រីក៏បានវាយតម្លៃខ្ពស់ចំពោះសភាពការណ៍នៅប្រទេសអេហ្ស៊ីប ដែលបានវិលមករកប្រក្រតីភាពឡើងវិញ ។ សម្តេចតែងតែធ្វើការតាមដានចំពោះសភាពការណ៍នៅអេហ្ស៊ីប និងបណ្តាប្រទេសក្នុងតំបន់ ដោយសារតែមាននិស្សិតកម្ពុជាបានទៅសិក្សានៅទីនោះ និងដោយសារតែសភាពការណ៍បានវិលមករកប្រក្រតីភាពហើយនោះ សម្តេចផ្ទាល់មានការត្រេកអរខ្លាំងណាស់ ហើយនិស្សិតកម្ពុជាមួយចំនួនក៏បានវិលទៅសិក្សានៅប្រទេសអេហ្ស៊ីបវិញដែរ។ ជាការឆ្លើយតបទៅនឹងប្រសាសន៍របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ឯកឧត្តម **អ៊ី ប្រាហ៊ីម** មានប្រសាសន៍ថាពេលនេះអេហ្ស៊ីបមានប្រក្រតីភាពឡើងវិញហើយ គឺមិនដូចសភាពការណ៍ក្នុងបណ្តាប្រទេសជិតខាងខ្លួននោះទេ តាមរយៈនេះប្រទេសទាំងពីរនឹងបន្តបង្កើនកិច្ចសហប្រតិបត្តិការជាមួយគ្នាឱ្យកាន់តែប្រសើរឡើងថែមទៀត។

❋នៅថ្ងៃទី២២-២៣ខែមេសា កិច្ចប្រជុំកំពូលអាស៊ីអាហ្វ្រិកបានបើកឡើងក្រោមប្រធានបទ" កិច្ចសហប្រតិបត្តិការត្បូង-ត្បូង" ដោយមានការចូលរួមពី **ព្រះចៅស៊ុលតង់** ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល និងគណៈប្រតិភូមកពីជាង១២០ប្រទេសនៅទ្វីបអាស៊ី និងអាហ្វ្រិក ។

សុន្ទរកថាគន្លឹះថ្លែងក្នុងពិធីបើកកិច្ចប្រជុំកំពូលអាស៊ីអាហ្វ្រិកឯកឧត្តម **ចូកូ វីដូដូ** ប្រធានាធិបតីនៃសាធារណរដ្ឋឥណ្ឌូណេស៊ី និងជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលអាស៊ីអាហ្វ្រិក ឆ្នាំ២០១៥ បានមានប្រសាសន៍ថារយៈពេល៦០ឆ្នាំក្រោយមកអ្វីៗវាមានការប្រែប្រួលខ្លាំង បញ្ហាអាណានិគមបានត្រូវបញ្ចប់ ប៉ុន្តែភាពយុត្តិធម៌នៅក្នុងពិភពលោកនៅមិនទាន់បានបញ្ចប់នៅ ឡើយនោះទេ តួយ៉ាងដូចជាមានការកើតឡើងនូវអំពើហិង្សា បញ្ហាភាពក្រីក្រ និងបញ្ហាមិនស្មើភាពគ្នា ។ ឯកឧត្តមប្រធានាធិបតីមានប្រសាសន៍បន្តថាប្រជាជន ១ ២០០ លាននាក់នៃទ្វីបទាំងពីរកំពុងរស់នៅក្រោមភាពក្រីក្រ ប៉ុន្តែប្រទេសអ្នកមានគេអាចនិយាយថាពួកគេអាចប្រែក្លាយពិភពលោកបាន។ ផ្ទុយទៅវិញវាមិនពិតដូចនោះទេ ពិសេសទៅទៀតនោះអង្គការសហប្រជាជាតិមិនមានអំណាចទាល់តែសោះ ជាមួយគ្នានេះ ក្រុមប្រទេសមួយចំនួននៅតែមិនទទួលស្គាល់ពីសិទ្ធិសម្រេចរបស់អង្គការសហប្រជាជាតិ។ ឯកឧត្តមប្រធានាធិបតីមានប្រសាសន៍បន្តថា ដូច្នេះកិច្ចប្រជុំថ្ងៃនេះ ត្រូវតែជំរុញឱ្យមានការកែទម្រង់អង្គការសហប្រជាជាតិ ពិសេសទៅទៀតនោះ អង្គការកំពូលរបស់ពិភពលោកមួយនេះត្រូវតែលើកតម្កើងនូវភាពយុត្តិធម៌សម្រាប់ប្រទេសទាំងអស់។ ឯកឧត្តមប្រធានាធិបតីសង្កត់ធ្ងន់ថា ស្មារតីនៃសន្និសីទទីក្រុងបាន់ឌុង គឺការទាមទារនូវឯករាជ្យសម្រាប់ប្រទេសទាំងអស់ក្នុងទ្វីបអាស៊ី និងអាហ្វ្រិក ដូចនេះយើងទាំងអស់គ្នានៅជំពាក់ប្រទេសប៉ាឡេស្ទីន ដែលមិនទាន់ទទួលបានឯករាជ្យ និងក្លាយជាប្រទេសពេញសិទ្ធិរបស់អង្គការសហប្រជាជាតិ ពិសេសទៅទៀតប្រជាជនប៉ាឡេស្ទីនកំពុងរស់នៅដោយភាពភ័យខ្លាច។ តាមរយៈនេះយើងត្រូវតែខិតខំជំរុញ និងគាំទ្រដល់ប្រទេស និងប្រជាជនប៉ាឡេស្ទីនក្នុងការទទួលបានឯករាជ្យពេញលេញ ។ ឯកឧត្តមប្រធានាធិបតីមានប្រសាសន៍ថាបើទោះបីជាមានបញ្ហាអ្វីកើតឡើងក៏ពិតមែន ប៉ុន្តែពេលនេះយើងត្រូវតទាមទារឱ្យមានការកសាងនូវពិភពលោកមួយដ៏រឹងមាំ នៅក្នុងសេដ្ឋកិច្ចថ្មីធ្វើយ៉ាងណាមិនឱ្យប្រទេសអ្នកមានមួយចំនួន បន្តគ្រប់ដណ្តប់ពិភពលោកនោះទេ។ ឯកឧត្តមប្រធានាធិបតីថ្លែងបន្តថា រយៈពេល២ថ្ងៃនៃកិច្ចពិភាក្សារបស់ខ្លួនយើងនឹងធ្វើការផ្លាស់ប្តូរមតិគ្នាជុំវិញបញ្ហាប្រឈមនៃយុត្តិធម៌ ពិភពលោក និងភាពមិនស្មើគ្នា ហើយគំនិតថ្មីរបស់យើងគឺទី១វិបុលភាព ការកាត់បន្ថយភាពក្រីក្រ ការបង្កើតការងារជូនប្រជាពលរដ្ឋ ទី២យើងត្រូវតែពង្រឹងនូវសាមគ្គីភាពភាពរីកចម្រើន និងការអភិវឌ្ឍទៅមុខរួមគ្នា ពិសេសការតភ្ជាប់គ្នាទៅវិញទៅមក និងទី៣យើងត្រូវតែរួមគ្នាដោះស្រាយនូវបញ្ហាប្រឈម ចំពោះអស្ថិរភាពភាពជ្រុលនិយមទាំងក្នុង និងក្រៅ រួមទាំងបញ្ហាសិទ្ធិមនុស្ស ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ពិសេសយើងត្រូវធ្វើយ៉ាងណាឱ្យលំហសមុទ្ររបស់យើងមានសុវត្ថិភាព និងរួមគ្នាដោះស្រាយទំនាស់ដោយមិនប្រើប្រាស់កម្លាំងទ័ព ពោលគឺអនាគតរបស់យើងត្រូវតែនៅក្នុងដៃ និងក្នុងប្រទេស និងនៅក្នុងទ្វីបអាស៊ី និងអាហ្វ្រិក ។



*សម្តេចតេជោ **ហ៊ុន សែន** ក្នុងឱកាសជួបពិភាក្សាការងារជាមួយ ឯកឧត្តម **ស៊ី ជិនពីង** ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន*

❋នៅថ្ងៃទី២៣ ខែមេសា ក្នុងឱកាសស្នាក់នៅទីក្រុងហ្សាការតាសម្តេចតេជោ **ហ៊ុន សែន** បានជួបពិភាក្សាការងារជាមួយឯកឧត្តម **ស៊ីជីន ពីង** ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន។ ឯកឧត្តម **ស៊ី ជិនពីង** មានប្រសាសន៍ថា កាលពី៦០ឆ្នាំមុន ឯកឧត្តម **ជូ អេនឡាយ** នាយករដ្ឋមន្ត្រីចិនបានជួប **ព្រះករុណាព្រះមហាវីរក្សត្រ" ព្រះបរមរតន-កោដ្ឋ** "ក្នុងអង្គសន្និសីទទីក្រុងបាន់ឌុង ហើយពេលនេះឆ្នាំ២០១៥ ឯកឧត្តមបានជួបផ្ទាល់ជាមួយសម្តេចតេជោនាយករដ្ឋមន្ត្រីនៅក្នុងសន្និសីទដ៏មានសារសំខាន់ ដែលមានអត្ថន័យជាប្រវត្តិសាស្ត្រនេះ ហើយដែលនឹងនាំមកនូវផលប្រយោជន៍ជូនចំពោះប្រជាពលរដ្ឋ នៃប្រទេសទាំងពីរកម្ពុជា ចិន។ ឯកឧត្តមប្រធានាធិបតីក៏បានចាត់ទុកថា ការជួបគ្នានេះគឺជាការជួបគ្នាជាប្រវត្តិសាស្ត្រមួយនៃថ្នាក់ដឹកនាំប្រទេសទាំងពីរ ។ឯកឧត្តមមានប្រសាសន៍ថា ចិន និងកម្ពុជាអនុវត្តនូវយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ដែលយើងបានបង្កើតជាមួយគ្នាដើម្បីធ្វើឱ្យប្រទេសទាំងពីរមានការរីកចម្រើនលូតលាស់ និងមានវាសនាដូចគ្នា។ សម្តេចតេជោនាយករដ្ឋមន្ត្រីមានប្រសាសន៍ឯកភាពចំពោះប្រសាសន៍ លើកឡើង




*កិច្ចប្រជុំកំពូលអាស៊ី អាហ្វ្រិក នៅប្រទេសឥណ្ឌូនេស៊ី*




*ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាលនៃប្រទេសអាស៊ានទាំង១០ ក្នុងឱកាសបើកកិច្ចប្រជុំកំពូលអាស៊ានលើកទី២៦ នៅប្រទេសម៉ាឡេស៊ី*

របស់ឯកឧត្តមប្រធានាធិបតី និងបានចាត់ទុកថាជំនួបគ្នានេះមានន័យជាប្រវត្តិសាស្ត្រសម្រាប់ថ្នាក់ដឹកនាំទាំងពីរ។ សម្តេចតេជោបន្តថា កាលពីជំនាន់មុនថ្នាក់ដឹកនាំរបស់ប្រទេសយើងទាំងពីរគឺឯកឧត្តម **ជូ អេនឡាយ** និង **ព្រះករុណាព្រះបរមរតនកោដ្ឋ** បានបង្កើតនូវទំនាក់ទំនងមិត្តភាពដ៏ល្អ។ តាមរយៈនេះយើងជាថ្នាក់ដឹកនាំជំនាន់ក្រោយគប្បីត្រូវតែបន្តពូនជ្រំ នូវទំនាក់ទំនងដ៏ល្អនោះថែមទៀត សម្រាប់កូនចៅជំនាន់ក្រោយបន្តទៅអនាគតយូរអង្វែង។

ក្នុងជំនួបពិភាក្សាគ្នានោះដែរ សម្តេចតេជោនាយករដ្ឋមន្ត្រីមានប្រសាសន៍ស្នើដល់ឯកឧត្តមប្រធានាធិបតីចិនបន្តជួយដល់កម្ពុជាលើវិស័យយោធាពិសេសលើការហ្វឹកហ្វឺនរួមគ្នាក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ ប្រតិបត្តិការជួយសង្គ្រោះ ដោយសារតែនៅចុងឆ្នាំ២០១៥នេះ នាវាកងទ័ពជើងទឹកចិននឹងធ្វើទស្សនកិច្ចនៅកំពង់ផែព្រះសីហនុ។ ជាមួយគ្នានេះ សម្តេចតេជោនាយករដ្ឋមន្ត្រីបានលើកនូវសំណូមពរមួយចំនួនរួមមានទី១ ស្នើដល់ភាគីចិនរក្សានូវអត្រាការប្រាក់លើកម្ចីប្រាក់យ័នក្នុងស្ថានភាពដដែល។ ទី២ ស្នើដល់ភាគីចិនបង្កើនកូតានាំអង្ករចូលទៅកាន់ប្រទេសចិនដោយសារតែកន្លងមកភាគីទាំងពីរបានឯកភាពនាំអង្ករចេញពីកម្ពុជា ទៅកាន់ប្រទេសចិនចំនួន១០ម៉ឺនតោន និងទី៣ បង្កើនកិច្ចសហប្រតិបត្តិការ ពង្រីកការតភ្ជាប់នៅកម្ពុជាទាំងផ្លូវដែក ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស ការតភ្ជាប់បណ្តាញអគ្គិសនីធារាសាស្ត្រ តាមរយៈការប្រើប្រាស់ផែនការផ្លូវសូត្រ ដែលជានយោបាយរបស់ចិន។ ជាការឆ្លើយតបឯកឧត្តមប្រធានាធិបតីចិនមានប្រសាសន៍ថាចិនស្ម័គ្រចិត្តក្នុងការជំរុញកិច្ចសហប្រតិបត្តិការ នៃការតភ្ជាប់ស្របតាមគោលនយោបាយរបស់ចិន។ តាមរយៈនេះ ឯកឧត្តមបានស្នើឱ្យមានការជំរុញនូវភាពរីកលូតលាស់នៃតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុផងដែរ។ ទាក់ទិនទៅនឹងការស្នើឱ្យមានការបង្កើនកូតានាំអង្ករចេញ ឯកឧត្តមប្រធានាធិបតីមានប្រសាសន៍ថា ភាគីចិននឹងយកចិត្តទុកដាក់ពិចារណាលើបញ្ហានោះយ៉ាងសកម្មបំផុត ដើម្បីទទួលអង្ករ និងទំនិញផ្សេងៗពីកម្ពុជា។ ភាគីចិននឹងបន្តជួយជំរុញនូវរាល់កិច្ចព្រមព្រៀង និងអនុស្សរណៈដែលបានចុះហត្ថលេខារួចហើយ ដើម្បីជំរុញនូវការអនុវត្តគម្រោង ដែលបានព្រមព្រៀងគ្នានោះ។ ឯកឧត្តមក៏បានឯកភាពជាមួយសម្តេចតេជោ ចំពោះការបង្កើតឱ្យមានការហ្វឹកហ្វឺនរួមគ្នានៃប្រទេសទាំងពីរ ក្នុងករណីគ្រប់គ្រងគ្រោះមហន្តរាយ និងប្រតិបត្តិការជួយសង្គ្រោះ ហើយចិននឹងបន្តគាំទ្រដល់កម្ពុជា ក្នុងការកសាងនូវហេដ្ឋារចនាសម្ព័ន្ធឱ្យមានការរីកចម្រើនថែមទៀត និងបានផ្តល់នូវសេចក្តីសង្ឃឹមថានឹងរៀបចំនូវគម្រោងជាមួយគ្នា។ ក្នុងជំនួបពិភាក្សាគ្នានោះដែរ ឯកឧត្តម **ស៊ី ជិនពីង** បានស្នើដល់សម្តេចតេជោនាយករដ្ឋមន្ត្រី ក្នុងការបង្កើនកិច្ចសហប្រតិបត្តិការលើវិស័យវប្បធម៌ ទេសចរណ៍ និងសង្គម។ ជាមួយគ្នានេះ ចិននឹងទទួលយកយុវជនកម្ពុជាចំនួន ១០០ នាក់ទៅបំពេញទស្សនកិច្ចក្នុងប្រទេសចិនក្នុងឆ្នាំ២០១៥រួមទាំងផ្តល់នូវអាហារូបករណ៍ជូនដល់និស្សិតកម្ពុជាផងដែរ។

ពាក់ព័ន្ធទៅនឹងបំណងរបស់ប្រទេសចិន ក្នុងការបង្កើតឡើងនូវវេទិកាមេគង្គ-ចិនសម្តេចតេជោនាយករដ្ឋមន្ត្រីមានប្រសាសន៍សម្តែងនូវការពេញចិត្ត និងបាន លើកទឹកចិត្តក្នុងការបង្កើតឱ្យមាននូវវេទិកាមេគង្គ-ចិន នៅពេលខាងមុខ ដោយសារតែកន្លងមក យើងមានវេទិកាមេគង្គ-សាធារណរដ្ឋកូរ៉េ មេគង្គ-អាមេរិក មេគង្គ-គង្គារ។ សម្តេចតេជោមានប្រសាសន៍សង្កត់ធ្ងន់ថា បើយើងមានមេគង្គ-ចិនមួយទៀតនោះ នោះយើងនឹងបំពេញបន្ថែមឱ្យគ្នា ក្នុងការជួយអភិវឌ្ឍបណ្តាប្រទេសនៅតាមដងទន្លេមេគង្គទាំងមូលផងដែរ ។

✵នៅព្រឹកថ្ងៃ២៤ មេសា ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល និងគណៈប្រតិភូទាំងអស់នៃបណ្តាប្រទេសក្នុងទ្វីបអាស៊ី និងអាហ្វ្រិក ដែលបានអញ្ជើញចូលរួមព្រឹត្តិការណ៍នៃការប្រារព្ធខួបអនុស្សាវរីយ៍លើកទី៦០នៃសន្និសីទទីក្រុងបាន់ឌុង បានធ្វើដំណើរដោយជើងតាមរុក្ខវិថីអាស៊ីអាហ្វ្រិក ក្នុងទីក្រុង បាន់ឌុង ជាទីក្រុងដែលមានវ័យចំណាស់ជាងគេរបស់សាធារណរដ្ឋឥណ្ឌូនេស៊ី។ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាក៏បានអញ្ជើញចូលរួមពិធីជាប្រវត្តិសាស្ត្រនេះដែរ។ នៅក្នុងឱកាសនៃការប្រារព្ធខួបអនុស្សាវរីយ៍លើកទី៦០នៃសន្និសីទទីក្រុងបាន់ឌុងនេះ បណ្តាមេដឹកនាំទាំងអស់បានឯកភាពគ្នាក្នុងការជំរុញកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌រវាងប្រទេសនៅទ្វីបអាស៊ី និងអាហ្វ្រិក ពិសេសប្រឆាំងនឹងអាណានិគមនិយមចាស់ថ្មី ។ នៅក្នុងសេចក្តីប្រកាសរបស់សន្និសីទទីក្រុងបាន់ឌុងនេះដែរបណ្តាមេដឹកនាំទាំងអស់ បានធ្វើការគូសបញ្ជាក់នូវភាពជាដៃគូយុទ្ធសាស្ត្រថ្មីអាស៊ីអាហ្វ្រិកជាស្ពានផ្សារភ្ជាប់រវាងប្រទេសអាស៊ី និងអាហ្វ្រិក ដោយផ្អែកលើមូលដ្ឋានកិច្ចសហប្រតិបត្តិការទូលំទូលាយ ប្រកបដោយចីរភាព ភាពជាដៃគូស្មើភាព គោរពគ្នាទៅវិញទៅមក និងរួមគ្នាដោះស្រាយបញ្ហាប្រឈម។ គាំទ្រអង្គការសហប្រជាជាតិ វេទិកាតំបន់ និងពហុភាគីផ្សេងៗទៀត ដើម្បីបំពេញការងារឲ្យកាន់តែមានប្រសិទ្ធភាពក្នុងការពង្រឹងសន្តិភាព និងវិបុលភាពនៅអាស៊ីអាហ្វ្រិក និងនៅក្នុងតំបន់ផ្សេងទៀត ។ ប្តេជ្ញាបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការជំរុញឱ្យមានការរីកចម្រើនក្នុងវិស័យផ្លាស់ប្តូរពាណិជ្ជកម្ម និងវិនិយោគទុន តាមរយៈកិច្ចសហប្រតិបត្តិការអន្តរតំបន់ ការធ្វើឱ្យប្រសើរឡើងនូវការតភ្ជាប់ក្នុងតំបន់ រវាងតំបន់ និងក្រៅតំបន់ និងការធ្វើឱ្យកាន់តែរស់រវើកនៃវិស័យកសិកម្ម សន្តិសុខស្បៀង កិច្ចសហប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធ និងសន្តិសុខថាមពល។ លើកទឹកចិត្តឱ្យមានការផ្សារភ្ជាប់រវាងប្រជាជន និងប្រជាជន តាមរយៈការពង្រឹងទំនាក់ទំនងរវាងធុរជន ស្ត្រី និងយុវជន។ ជាមួយនឹងការធ្វើឱ្យរីកចម្រើននូវភាពជាដៃគូ បណ្តាមេដឹកនាំទាំងអស់បានអំពាវនាវឱ្យមានការចូលរួមយ៉ាងសកម្មពីដៃគូអភិវឌ្ឍន៍ក្នុងការផ្តល់នូវការគាំទ្រ និងការចែករំលែកនូវបទពិសោធន៍ និងការផ្ទេរបច្ចេកវិទ្យា ដើម្បីធ្វើឱ្យកាន់តែល្អប្រសើរនូវកិច្ចសហប្រតិបត្តិការត្បូង-ត្បូង ដោយឈរលើមូលដ្ឋានគោលការណ៍មានផលប្រយោជន៍ទៅវិញទៅមក គ្មានលក្ខខណ្ឌស្មើភាពគោរពអធិបតេយ្យ និងការមិន



*សម្តេចតេជោ **ហ៊ុន សែន** ទទួលកិច្ចស្វាគមន៍ដ៏កក់ក្តៅពីសំណាក់ ឯកឧត្តម **ណាជិប រ៉ាហ្សាក់** នាយករដ្ឋមន្ត្រីនៃប្រទេសម៉ាឡេស៊ី*

ជ្រៀតចូលបញ្ហាផ្ទៃក្នុងផងគ្នា។ ជាមួយគ្នានេះមេដឹកនាំទាំងអស់ក៏បានធ្វើការអំពាវនាវចំពោះបណ្តារដ្ឋមន្ត្រី និងមន្ត្រីនៃក្រុមប្រទេសអាស៊ីអាហ្វ្រិកបំពេញការងារឱ្យកាន់តែសកម្មដើម្បីធ្វើឱ្យសម្រេច នូវកិច្ចសហប្រតិបត្តិការក្នុងវិស័យ ដែលកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់បានផ្តល់អនុសាសន៍នៅទីក្រុងហ្សាការតាកាលពីឆ្នាំ២០០៩ក្នុងនោះរួមមានការប្រឆាំងភេរវកម្មការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្ម ឆ្លងដែនសន្តិសុខស្បៀង សន្តិសុខថាមពល សហគ្រិនតូច និងមធ្យមទេសចរណ៍បណ្តាសាកលវិទ្យាល័យអភិវឌ្ឍន៍អាស៊ីអាហ្វ្រិក សមភាពយេនឌ័រ និងការលើកកម្ពស់ស្ត្រី។ ជាមួយគ្នានេះក្នុងភាពជាដៃគូយុទ្ធសាស្ត្រនាពេលអនាគតបណ្តាមេដឹកនាំទាំងអស់បានឯកភាពគ្នាក្នុងការពិចារណា បង្កើតបណ្តាញមជ្ឈមណ្ឌលរក្សាសន្តិភាព នៅក្នុងតំបន់ទាំងពីរ ដើម្បី សម្រួលកិច្ចសហប្រតិបត្តិការក្នុងការកសាងសមត្ថភាព តាមរយៈការចែករំលែកបទពិសោធន៍មេរៀន ដែលទទួលបានការអនុវត្តដ៏ល្អ និងកម្មវិធី បណ្តុះបណ្តាល, ភាពចាំបាច់ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងវិស័យកសិកម្ម ដែលជាផ្នែកមួយនៃរបៀបវារៈអនាគត ដើម្បីធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង, ផ្តល់សារៈសំខាន់លើកិច្ចសហប្រតិបត្តិការក្នុងការជំរុញសេដ្ឋកិច្ច, ការពង្រឹងភាពជាដៃគូរវាងផ្នែកសាធារណៈ និងឯកជន, ប្តេជ្ញា ពង្រឹងឱ្យកាន់តែសកម្មខ្លាំងក្លាថែមទៀត នូវកិច្ចសហប្រតិបត្តិការរវាងតំបន់ទាំងពីរ នៅក្នុងការអភិវឌ្ឍការបង្កើនការតភ្ជាប់, ជំរុញការផ្លាស់ប្តូរ ពាណិជ្ជកម្មវិនិយោគ ការអភិវឌ្ឍឧស្សាហកម្ម និងកិច្ចសហប្រតិបត្តិការនាវាចរណ៍។

❋ចាប់ពីថ្ងៃទី២៦-២៧ ខែមេសា ឆ្នាំ២០១៥ សម្តេចតេជោ **ហ៊ុន សែន** បានបន្តអញ្ជើញចូលរួមកិច្ចប្រជុំអាស៊ាន លើកទី២៦នៅប្រទេសម៉ាឡេស៊ី។ នៅល្ងាចថ្ងៃទី២៥ ខែមេសា ក្នុងពេលអញ្ជើញទៅដល់ប្រទេសម៉ាឡេស៊ី សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម សម រង្ស៊ី ប្រធានក្រុមភាគតិចក្នុងរដ្ឋសភាបានជួបសំណេះសំណាលជាមួយបងប្អូនប្រជាពលករ កម្មករ កម្មការិនី និងនិស្សិតកម្ពុជាចំនួន២៩០ នាក់ ដែលកំពុងស្នាក់នៅបំពេញការងារ និងសិក្សានៅម៉ាឡេស៊ី។ សម្តេចតេជោ **ហ៊ុន សែន** បានថ្លែងថាលទ្ធផលនៃការបង្កើតឡើងនូវវប្បធម៌សន្ទនា គឺជាជំហានថ្មីមួយទៀតដែលជនជាតិកម្ពុជាខ្លួនឯងផ្ទាល់ជាអ្នកបង្កើតឡើង បន្ទាប់ពីការដាក់ចេញនូវនយោបាយឈ្នះឈ្នះ។ នេះគឺជាបទពិសោធន៍ថ្មីមួយទៀតរបស់កម្ពុជា ដើម្បីឲ្យអន្តរជាតិមើលឃើញ ហើយក៏មិនមានប្រទេសណាមួយអាចធ្វើបានដូចជាយើងនេះទេ។

នៅរសៀលថ្ងៃទី២៦ ខែមេសា វេទិកាភាពជាអ្នកដឹកនាំអាស៊ានលើកទី១២បានបើកឡើងក្រោមប្រធានបទអាស៊ានឆ្ពោះទៅមុខ សហគមន៍តែមួយចក្ខុវិស័យតែមួយប្រជាជនតែមួយបានប្រារព្ធបើកជាផ្លូវការនៅទីក្រុងកូឡាឡាំពួរ។ នៅក្នុងសុន្ទរ




*សម្តេចតេជោ **ហ៊ុន សែន** ចូលរួមវេទិកាភាពជាអ្នកដឹកនាំអាស៊ានលើកទី១២*



*សម្តេចតេជោ **ហ៊ុន សែន** និងឯកឧត្តម សម រង្ស៊ី ក្នុងពិធីសំណេះសំណាលជាមួយកម្មករ កម្មការិនី និងនិស្សិតកម្ពុជា ដែលធ្វើការ និងសិក្សានៅប្រទេសម៉ាឡេស៊ី*

កថាគន្លឹះក្នុងវេទិកាដ៏មានសារៈសំខាន់នេះ បណ្តាមេដឹកនាំនៃប្រទេសអាស៊ានបានចាត់ទុកថា វេទិកានេះពិតជាមានសារៈសំខាន់ខាងនយោបាយក្នុងការបង្កើនល្បឿន និងទំនុកចិត្តសម្រាប់អ្នកបន្តវេនក្នុងបុព្វហេតុឆ្ពោះទៅអនាគត តាមទិសស្លោកសហគមន៍តែមួយចក្ខុវិស័យតែមួយប្រជាជនតែមួយ ដែលយើងបានលើកយកមកពិភាក្សាយ៉ាងលម្អិតលម្អន់ក្នុងវេទិកាភាពជាអ្នកដឹកនាំអាស៊ានលីកទី១២នេះ។ សុន្ទរកថាគន្លឹះរបស់សម្តេចតេជោ**ហ៊ុនសែន**បានបញ្ជាក់អំពីចំណុចអាទិភាពមួយចំនួនដែល អាស៊ានត្រូវបន្តយកចិត្តទុកដាក់នៅក្នុងក្របខ័ណ្ឌ នៃចក្ខុវិស័យក្រោយឆ្នាំ២០១៥ ក្នុងគោលដៅនៃការធ្វើសមាហរណកម្មអាស៊ានឱ្យកាន់តែស៊ីជម្រៅ និងការជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងសមធម៌។ ចំណុចអាទិភាពទាំងនោះគឺទី១ ការបន្តពង្រឹងការសម្របសម្រួលពាណិជ្ជកម្មប្រកបដោយប្រសិទ្ធភាពដែលជាកត្តាចាំបាច់សម្រាប់ការបង្កើតទីផ្សារ និងមូលដ្ឋានផលិតកម្មរឹងមាំក៏ដូច ជាសម្រាប់ការពង្រឹងភាពប្រកួតប្រជែងក្នុងតំបន់ជាពិសេសតាមរយៈការលុបបំបាត់នូវរបាំងពន្ធគយ និងរបាំងមិនមែនពន្ធគយទី២ ការជំរុញអនុវត្តឱ្យបានឆាប់រហ័សនូវសេរីភាវូបនីយកម្ម និងការសម្រួលលំហូរមូលធនឆ្លងដែនស្របតាមកិច្ចព្រមព្រៀងវិនិយោគអាស៊ាន ដើម្បីធានាបរិយាកាសវិនិយោគក្នុងតំបន់ឱ្យមានភាពល្អប្រសើរជាពិសេសការបន្តធ្វើសេរីភាវូបនីយកម្មសេវាកម្ម ដើម្បីអភិវឌ្ឍវិស័យសេវាកម្មរបស់តំបន់ឱ្យមានភាពរឹងមាំទី៣ ការពន្លឿនការតភ្ជាប់ព្រមទាំងការសម្រួលបន្ថែមទៀតដល់ការដឹកជញ្ជូន និងការកែលម្អបណ្តាញឡូជីស្ទីកដើម្បីធ្វើសមាហរណកម្មឱ្យកាន់តែជិតស្និទ្ធរវាងសេដ្ឋកិច្ច និងខ្សែចង្វាក់ផលិតកម្មនៅក្នុងតំបន់អា-

តនៅទំព័រទី ២៤

# សកម្មភាពសមាជិករដ្ឋសភា_ព្រឹទ្ធសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស



ក្នុងខែមេសាឆ្នាំ២០១៥នេះឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឯកឧត្តម **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ឯកឧត្តម **គោស៊ុំ សារឿត** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ បានអញ្ជើញបើកការដ្ឋានសាងសង់អគាររដ្ឋបាល និងអគារសាលប្រជុំ សម្រាប់ស្រុកក្រុងចំនួន ៣៤ នៃខេត្ត ១៨ ក្រោមកម្ចីឥណទានពីធនាគារអភិវឌ្ឍន៍អាស៊ី។ពិធីបើកជានិមិត្តរូបនេះធ្វើឡើងនៅសាលាស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។

*ថ្ងៃទី២៣ខែមេសា ឆ្នាំ២០១៥ នៅវត្តគគីរធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ឯកឧត្តម **តេព ងន** អនុប្រធានទី២ព្រឹទ្ធសភា សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា បានអញ្ជើញជាអធិបតីភាពក្នុងវេទិកាស្តីពីការលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការពង្រឹងតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សាឃុំក្នុងការអភិវឌ្ឍមូលដ្ឋានដោយធានាសមភាពយេនឌ័រ ។ ពិធីនេះបានការអញ្ជើញចូលរួម ពីឯកឧត្តម លោកជំទាវនៃក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ និងដោយមានការអញ្ជើញចូលរួមពីសមាជិកសមាជិកាព្រឹទ្ធសភា-រដ្ឋសភាថ្នាក់ដឹកនាំនៃអគ្គលេខា ធិការដ្ឋានព្រឹទ្ធសភា សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ និងប្រជាពលរដ្ឋក្នុងស្រុក កៀនស្វាយ និងស្រុកលើកដែក ខេត្តកណ្តាល ។*





ថ្ងៃទី ៩ ខែមេសាឯកឧត្តម **វងសូត** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច បានអញ្ជើញផ្តល់អំណោយរបស់រាជរដ្ឋាភិបាលកម្ពុជាជូនដល់ប្រជាពលរដ្ឋដែលជួបការខ្វះខាតជនចាស់ជរា និងនិវត្តន៍ជនចំនួន ២០០ គ្រួសារ រស់នៅឃុំជាច ស្រុកកំចាយមារ ខេត្តព្រៃវែង។

*ក្នុងខែមេសានេះដែរ គណៈប្រតិភូអន្តរក្រសួង រួមមានឯកឧត្តម **អ៊ិត សំហេង** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជារដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឯកឧត្តម **ព្រំសុខា** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានអញ្ជើញទៅពិនិត្យដំណើរ-ការការងារនៃគណៈកម្មាធិការផ្តល់ភាពស្របច្បាប់ជូនដល់ពលករកម្ពុជាដែលកំពុងបំពេញការងារនៅខេត្តសាមុតប្រកាន ប្រទេសថៃ ។*



ថ្ងៃទី ២៤ ខែមេសា ឯកឧត្តម **លឹម គានហោ** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម បានអញ្ជើញចុះពិនិត្យ ការអនុវត្តគម្រោងអភិវឌ្ឍប្រពន្ធ័ធារាសាស្រ្តវ៉ៃកូជំហានទីមួយក្នុងខេត្តព្រៃវែង ដែលជាគម្រោងនាំទឹកទន្លេមេគង្គពីខេត្តកំពង់ចាមមកខេត្តព្រៃវែង និងទៅខេត្តស្វាយរៀង ។



# សកម្មភាពសមាជិករដ្ឋសភា_ព្រឹទ្ធសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស



*ថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១៥ ឯកឧត្តម **ខូយ ឃុនហួរ** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈអភិបាលខេត្តកំពត និងលោកជំទាវ **អ៊ុន សុគន្ធា** សមាជិកាគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា អ្នកតំណាងរាស្ត្រមណ្ឌលកំពត បានអញ្ជើញចុះសួរសុខទុក្ខ ព្រមទាំងនាំយកអំណោយមួយចំនួនចែកជូនដល់ក្រុមគ្រួសារ និងយោធិនពិការនៅមណ្ឌលអភិវឌ្ឍន៍ **ប៊ុនរ៉ានី ហ៊ុន សែន** ៣១៧ កោះស្លា ខេត្តកំពត ។*



ថ្ងៃទី២១មេសា ឆ្នាំ២០១៥ ឯកឧត្តម **ឡាយ វណ្ណៈ** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈអភិបាលខេត្តតាកែវ បានអញ្ជើញចុះពិនិត្យដីមានទំនាស់រវាងរដ្ឋបាលព្រៃឈើ និងប្រជា-ពលរដ្ឋចំនួន ៤ គ្រួសារ ស្ថិតនៅក្នុងភូមិទំនប់ សង្កាត់រកាក្រៅ ក្រុងដូនកែវ ខេត្តតាកែវ និងបានប្រគល់ដីដែលមានទំនាស់ប្រហែល ៣ ហិកតានោះជូនដល់ប្រជាជនវិញ ។



*ថ្ងៃទី ០៥ ខែមេសា ឆ្នាំ២០១៥ ក្នុងឱកាសពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ ដែលនឹងមកដល់នាពេលខាងមុខនេះ ឯកឧត្តម **ម៉ម ប៊ុននាង** អនុប្រធានគណៈកម្មការទី ១០ នៃព្រឹទ្ធសភា ព្រមទាំងជាសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគ ៣ (ខេត្តកណ្ដាល) បានអញ្ជើញជួបសំណេះសំណាលជាមួយ ថ្នាក់ដឹកនាំស្រុក ឃុំ ភូមិ និងនិវត្តជនចំនួន ២៦២ នាក់ នៅសាលាស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ។*



ថ្ងៃទី ៤ ខែមេសា ឆ្នាំ ២០១៥ ឯកឧត្តម **ហ៊ុន ម៉ាណែត** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា បានអញ្ជើញចូលរួមបើកការដ្ឋានសាងសង់ហេដ្ឋារចនាសម្ព័ន្ធ នៅបរិវេណមណ្ឌលអភិវឌ្ឍន៍សហគមន៍ស៊ីម៉ាក់មរតកតេជោ ស្ថិតក្នុងស្រុកគាស់ក្រឡ ខេត្តបាត់ដំបង ។




ថ្ងៃទី៥ខែមេសា ឆ្នាំ ២០១៥ ឯកឧត្តម **នឹម ច័ន្ទតារា** តំណាងរាស្ត្រមណ្ឌលកំពត បានអញ្ជើញជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋដែលមានបញ្ហាទំនាស់ដីធ្លីនៅភូមិអូរ ឃុំត្រពាំងរាំង ស្រុកជុំគីរី ខេត្តកំពត ដើម្បីស្វែងយល់ និងរួមចំណែកជួយដោះស្រាយ ។

# សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស




ក្នុងឱកាសបំពេញទស្សនកិច្ចសិក្សា នៅសាធារណរដ្ឋប្រជាមានិតចិន នាល្ងាចថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១៥ ឯកឧត្តម **កែ ប៊ុនខៀង** ប្រធាន ឯកឧត្តម **ហ៊ុន ម៉ាណែត** អនុប្រធាន ក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាល និងសមាជិក សមាជិកា សរុបចំនួន ៣៥ រូប បានទទួលព្រះរាជានុញ្ញាតចូលក្រាបបង្គំគាល់សម្ដែងការគួរសម និងទូលពីសកម្មភាពរបស់គណៈប្រតិភូដល់ព្រះករុណាព្រះបាទ**សម្ដេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង **សម្ដេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ** ដែលទ្រង់កំពុងគង់ប្រថាប់នៅព្រះរាជដំណាក់នារដ្ឋធានីប៉េកាំងនៃសាធារណរដ្ឋប្រជាមានិតចិន។




*នាល្ងាចថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១៥ គណៈប្រតិភូក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាល ដឹកនាំដោយឯកឧត្តម **កែ ប៊ុនខៀង** និងឯកឧត្តម **ហ៊ុន ម៉ាណែត** និងសមាជិក សមាជិកាទាំង ៣៥ រូប បានចូលជួបសម្ដែងការគួរសមជាមួយឯកឧត្តម Lui Hongcai អនុរដ្ឋមន្ត្រីក្រសួងទំនាក់ទំនងអន្តរជាតិនៃ គណៈកម្មាធិការមជ្ឈឹមបក្សកុម្មុយនីស្តចិន នៅសណ្ឋាគារ Wanshou ។ ក្នុងឱកាសសំដែងការគួរសមនេះ ឯកឧត្តម Lui Hongcai បានលើកសរសើរអំពីចំណងទាក់ទងរវាងសាធារណរដ្ឋប្រជាមានិតុចិន និងព្រះរាជាណាចក្រកម្ពុជា ដែលមានតាំងពីយូរលង់ និងកាន់តែបានពង្រឹងក្លាយជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយនាបច្ចុប្បន្ន ដោយសារថ្នាក់ដឹកនាំបច្ចុប្បន្នរបស់ប្រទេសទាំង ២ និងគណបក្ស គឺគណបក្សប្រជាជនកម្ពុជា និងបក្សកុម្មុយនីស្តចិន ឯកឧត្តមបានឯកភាពនូវសំណើមួយចំនួនរបស់គណៈប្រតិភូកម្ពុជា និងរៀបចំរាយការណ៍ជូនថ្នាក់ដឹកនាំបក្សសម្រេច។ បន្ទាប់ពីបញ្ចប់ជំនួបពិភាក្សា ឯកឧត្តម Lui Hongcai បានរៀបចំអាហារសាមគ្គីជូនគណៈប្រភិភូ នៅសណ្ឋាគារ Wanshou ។*



នាថ្ងៃទី ៩ ខែមេសា ឆ្នាំ ២០១៥ ក្រុមការងាររៀបចំអង្គការចាត់តាំងយុវជនគណបក្សនៅក្រៅប្រទេស ផ្នែកសហរដ្ឋអាមេរិក បានជួបពិភាក្សាការងារជាមួយ លោក **ចាន់ ស៊ីថុន** ប្រធានសាខាបក្ស និងលោក **យូ គឹមសុន** ដែលជាសមាជិកសាខាគណបក្សនៅទីក្រុងស្តុកតុង រដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក ដោយមានការចូលរួមពីឯកឧត្តម **កែ ប៊ុនខៀង** ប្រធាន និងឯកឧត្តម **ហ៊ុន ម៉ាណែត** អនុប្រធានក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាល និងជាប្រធានក្រុមការងាររៀបចំអង្គការចាត់តាំងយុវជនគណបក្សនៅក្រៅប្រទេស ។




*នាថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០១៥ នាស្នាក់ការគណបក្សខេត្តកំពង់ស្ពឺ បានរៀបចំពិធីបិទវគ្គបណ្ដុះបណ្ដាលវាគ្មិនសកម្មជនយុវជនគណបក្សខេត្តកំពង់ស្ពឺ ចំនួន ៤៧ រូប មកពីគ្រប់ស្រុក-ក្រុងក្នុងខេត្តកំពង់ស្ពឺ ដែលបានឆ្លងកាត់វគ្គបណ្ដុះបណ្ដាលរយៈពេលខ្លីចំនួន ៦ ខែ គឺពីថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០១៤ ដល់ ថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០១៥ ក្រោមអធិបតីភាពឯកឧត្តម **សត្យា វុធ** សមាជិកគណៈកម្មាធិការកណ្ដាល ប្រធានគណៈប្រចាំការ និងជាប្រធានក្រុមការងារយុវជនគណបក្សខេត្ត ។*

# សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស



នៅរសៀលថ្ងៃទី ៥ ខែមេសា ឆ្នាំ ២០១៥ ឯកឧត្តម **ជាម ច័ន្ទសោភ័ណ** សមាជិកក្រុមការងារយុវជនគណបក្សថ្នាក់កណ្តាល ប្រធានក្រុមការងារយុវជនគណបក្សខេត្ត ជាប្រធានក្រុមការងារចុះជួយសង្កាត់ព្រែកព្រះស្តេច ក្រុងបាត់ដំបង និងសមាជិក សមាជិកា បាននាំយកអំណោយមួយចំនួនចែកជូនប្រជាពលរដ្ឋ ៨០ គ្រួសារ ដែលមានជីវភាពក្រីក្រ ដោយក្នុងនោះមួយគ្រួសារទទួលបានអង្ករមួយបាវ ទឹកត្រីមួយយួ ទឹកស៊ីអ៊ីវមួយយួ និងត្រីខ៥កំប៉ុង។



*នាថ្ងៃទី ១២ ខែមេសា ឆ្នាំ ២០១៥ ក្រុមការងារយុវជនគណបក្សខេត្តបន្ទាយមានជ័យ បានប្រារព្ធពិធីប្រកាសសមាសភាពក្រុមការងារយុវជនគណបក្សស្រុក សកម្មជនយុវជនឃុំ និងភូមិ របស់ស្រុកអូជ្រៅ ក្រោមអធិបតីភាពឯកឧត្តម **អ៊ុំ រាត្រី** អនុប្រធានក្រុមការងារយុវជនគណបក្សខេត្ត និងឯកឧត្តម **ឡាយ គឹមលី** សមាជិកគណៈកម្មាធិការកណ្តាល និងសមាជិកក្រុមការងារយុវជនគណបក្សថ្នាក់កណ្តាល ។*



នាថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០១៥ ឯកឧត្តម **ង៉ោ សុវណ្ណ** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាអនុប្រធានក្រុមការងារចុះជួយខេត្តស្វាយរៀង រួមជាមួយក្រុមការងារ បានដឹកនាំសកម្មជនយុវជនគណបក្ស សាងសង់របងលួសព័ទ្ធជុំវិញទីស្នាក់ការបក្សឃុំគោកព្រីង ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។



*ដោយមានការ ផ្តួចផ្តើមពី ឯកឧត្តម ប្រធានគណបក្សខេត្ត និងឯកឧត្តមប្រធានក្រុម ការងារចុះជួយ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ នៅល្ងាចថ្ងៃទី ២១ ខែមេសា ឆ្នាំ ២០១៥ ឯកឧត្តម **ផ្លុង ពេជ្រ** ប្រធានស្តីទីក្រុមការងារចុះជួយឃុំជាំក្សាន្ត ប្រធាន អនុប្រធាន សមាជិកក្រុមសកម្មជនយុវជនគណបក្សឃុំជាំក្សាន្ត បានធ្វើពិធីប្រគល់ផ្ទះជូនលោកយាយ **ឡឹក ហង្ស** ជាចាស់ជរាគ្មានទីពឹងផ្ទះទំហំ ៤ម៉ x ៦ម៉ ធ្វើពីឈើប្រក់ស័ង្កសី នៅភូមិជាំក្សាន្ត ឃុំជាំក្សាន្ត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ។*

# វិស័យកសិកម្មនៅកម្ពុជាឆ្នាំ ២០១៤ បង្ហាញពីវឌ្ឍនភាពដ៏រឹងមាំ




*ការប្រែប្រួលជាវិជ្ជមានក្នុងផ្នែកជាច្រើននៃវិស័យកសិកម្មនៅឆ្នាំ២០១៤កន្លងទៅ បានចូលរួមចំណែកប្រមាណ២៨,៧%នៃផលិតផលក្នុងស្រុកសរុប*

សន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានប្រារព្ធកាលពីដើមខែមេសាឆ្នាំ២០១៥កន្លងទៅនេះ បានបង្ហាញអំពីការប្រែប្រួលជាវិជ្ជមានក្នុងផ្នែកជាច្រើននៃវិស័យនេះ ពោលនៅក្នុងឆ្នាំ២០១៤កន្លងទៅវិស័យកសិកម្មបានចូលរួមចំណែកប្រមាណ២៨,៧%នៃផលិតផលក្នុងស្រុកសរុប ជាមួយនឹងវិស័យឧស្សាហកម្ម២៥,៥% និងវិស័យសេវាកម្ម៤០,៥%។ វិស័យកសិកម្មបានស្រូបយក៤៨,៧% នៃកម្លាំងពលកម្មសរុបក្នុងឆ្នាំ២០១៣។ ដោយឡែកក្នុងកំណើនវិស័យកសិកម្មផ្នែកដំណាំបានចូលរួមចំណែកជាងពាក់កណ្តាលពោលគឺកើនដល់៥៩,៤%,ផលិតកម្មនេសាទ២២,២%,ផលិតកម្មសត្វ១១,៣% និងអាជីវកម្មព្រៃឈើមាន ៧,០% ។

នៅឆ្នាំ ២០១៤ ការងារបង្កបង្កើនផលស្រូវសម្រេចបានលើផ្ទៃដីចំនួន ៣,០៥៥លានហិកតាគឺកើនឡើង ០,១% ក្នុងនោះផ្ទៃដីប្រមូលផលមានចំនួន ៣,០២៨ លានហិកតា កើនឡើង២% បើធៀបទៅនឹងឆ្នាំ២០១៣ ។ ផលិតផលស្រូវសរុបទទួលបានចំនួន៩,៣២៤លានតោន ដោយថយចុះប្រមាណ ០,៧% ធៀបនឹងឆ្នាំ២០១៣ ដោយសារគ្រោះរាំងស្ងួតនាដើមរដូវ និងទឹកជំនន់ពាក់កណ្តាលរដូវវស្សា ។ ផ្ទៃដីជិត ២ សែនហិកតា បានទទួលរងផលប៉ះពាល់ ហើយផ្ទៃដីជាង ២៧ ពាន់ហិកតា ទៀតទទួលរងការខូចខាតទាំងស្រុង ។

ជាទូទៅ ស្រូវវស្សាដុះលូតលាស់មិនបានល្អដូចធម្មតាទេ ដែលនេះជាកត្តាចម្បងមួយធ្វើឱ្យទិន្នផលស្រូវគិតជាមធ្យមធ្លាក់ចុះពី ៣,១៦៣ តោនក្នុងមួយហិកតា កាលពីឆ្នាំ ២០១៣ មកនៅត្រឹម ៣,០៧៩ តោនក្នុងមួយហិកតានៅឆ្នាំ ២០១៤ ។

ឆ្នាំ ២០១៤ ផ្ទៃដីស្រូវវស្សាអនុវត្តបានចំនួន ២,៥៦៤ លានហិកតា គឺថយចុះប្រមាណជាង ៣ ពាន់ហិកតា (ត្រូវជា០,១២%) ធៀបនឹងឆ្នាំ ២០១៣ ។ ប៉ុន្តែផ្ទៃដីប្រមូលផលមានចំនួន ២,៥៣៧ លានហិកតា លើសឆ្នាំមុនជាង ៥២ ពាន់ហិកតា ដោយទទួលបានទិន្នផលជាមធ្យម២,៨២៥ តោនក្នុងមួយហិកតា ។ ដូច្នេះ ផលិតផលស្រូវវស្សាមានចំនួន ៧,១៤៣ លានតោន តិចជាងឆ្នាំមុនជាង ១២៧ ពាន់តោន ។

ផ្ទៃដីស្រូវប្រាំងអនុវត្តបានចំនួនជាង ៤៩០ ពាន់ហិកតា កើនឡើងជាង ៧ ពាន់ហិកតា បើធៀបទៅនឹងឆ្នាំ ២០១៣ ដោយទទួលបានបរិមាណផលស្រូវជាង ២,១៨ លានតោន លើសឆ្នាំមុនចំនួន ៦២ ពាន់តោន។ ទិន្នផលស្រូវប្រាំងជាមធ្យមទទួលបាន ៤,៤៤៣ តោនក្នុងមួយហិកតា ដែលឆ្នាំមុនសម្រេចបានតែ ៤,៣៨៣ តោនក្នុងមួយហិកតាប៉ុណ្ណោះ ។

តុល្យភាពស្បៀងឆ្នាំ ២០១៤ បានបង្ហាញថា ផលិតផលស្រូវមានអតិរេកចំនួនជាង ៤,៧ លានតោន គឺថយចុះ ២,៤៨% ធៀបនឹងឆ្នាំ២០១៣ គិតជាអង្ករមានបរិមាណ ៣,០១ លានតោន ។ ទោះជាយ៉ាងនេះក្តី អតិរេកអង្ករជាង ៣ លានតោននេះ គឺជាមោទនភាពមួយសម្រាប់វិស័យកសិកម្មកម្ពុជាដែលស្ថិតក្នុងស្ថានភាពនៃការប្រែប្រួលអាកាសធាតុ ជាពិសេសគ្រោះរាំងស្ងួត និងទឹកជំនន់ តែនៅតែធានាបានបរិមាណអង្ករគ្រប់គ្រាន់ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ។

ក្រៅពីដំណាំស្រូវ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មបានដាំដុះនៅលើផ្ទៃដីជាង ៩៥០ ពាន់ហិកតា ដែលមានបរិមាណសរុប ១៤,៧២ លានតោន គឺកើនឡើងប្រមាណ ៣៩,៧% ធៀបនឹងឆ្នាំមុន ។

ក្នុងឆ្នាំ២០១៤នេះដែរ ការនាំចេញទំនិញកសិផលទៅកាន់ទីផ្សារក្នុងតំបន់ និងពិភពលោកមានចំនួន ៤៧ មុខ ដែលមានបរិមាណសរុប ៣,៤៤ លានតោន ។ ដោយឡែក ការនាំចេញអង្ករបានកើនពីជាង ៣៧៨ ពាន់តោន ក្នុងឆ្នាំ២០១៣ ដល់ជាង ៣៨៧ ពាន់តោន ក្នុងឆ្នាំ២០១៤ ។ អង្ករផ្ការំដួលគឺជាអង្ករដែលមានទីផ្សារធំទូលាយនិងមានរសជាតិឆ្ងាញ់ជាងគេបំផុតដែលបានជាប់ចំណាត់ថ្នាក់លេខ១លើពិភពលោក ក្នុងរយៈពេល ៣ ឆ្នាំជាប់ៗគ្នា ចាប់តាំងពីឆ្នាំ២០១២ រហូតមកដល់ឆ្នាំ២០១៤នេះ ។ ដោយមើលឃើញសក្តានុពលនៃពូជស្រូវប្រភេទនេះ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ តាមរយៈវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍកសិកម្ម (CARDI) បានស្រាវជ្រាវ និងបំប្លែងពីពូជស្រូវផ្ការំដួលសម្រាប់ដាំដុះរយៈពេលមធ្យម ហើយប្រកាន់រដូវឱ្យទៅជាពូជស្រូវផ្ការំដួលសម្រាប់រយៈពេលខ្លី ហើយមិនប្រកាន់រដូវវិញ ដែលមានឈ្មោះថា ពូជផ្ការំដួលប្រាំង ។

ដោយឡែក នៅក្នុងត្រីមាសទី ១ ឆ្នាំ ២០១ ៥នេះ អង្ករកម្ពុជាបាននាំចេញជាផ្លូវការទៅកាន់ ៥៩ ប្រទេស ដែលក្នុងនោះភាគច្រើនជាប្រទេសស្ថិតក្នុងសហភាពអឺរ៉ុប ក្នុងបរិមាណជាង ១៤៩ ពាន់តោន គឺកើនឡើងប្រមាណ ៧៧% បើប្រៀបធៀបរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដែលសម្រេចបានតែជាង ៨៤ ពាន់ តោនប៉ុណ្ណោះ។ ការនាំចេញទំនិញកសិផលទៅកាន់សាធារណរដ្ឋប្រជាមានិតចិន នឹងត្រូវពង្រីកបន្ថែមទៀតនៅពេល



*ការនាំចេញអង្កររបស់កម្ពុជា កំពុងមានសន្ទុះកើនឡើង*





*ផលិតកម្មកៅស៊ូធម្មជាតិកម្ពុជា មានការរីកចម្រើនគួរឲ្យកត់សម្គាល់ដោយមានសន្ទុះកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ*

ខាងមុខនេះ ព្រោះថា ក្រៅពីអង្ករ និងដំឡូងមី ភាគីទាំងពីរបានព្រមព្រៀងគ្នាក្នុងការនាំចេញពោតរួចហើយ ហើយកំពុងពិនិត្យការនាំចេញកញ្ចុងអង្ករ សណ្ដែកសៀង ផ្លែស្វាយ និងផ្លែចេកថែមទៀត ។ ទន្ទឹមនេះ ក្រសួងកសិកម្មក៏កំពុងរៀបចំពិធីសារ ស្ដីពីការនាំចេញផ្លែស្វាយទៅកាន់សាធារណរដ្ឋកូរ៉េផងដែរ ។

ចំពោះការងារស្រាវជ្រាវ ផ្សព្វផ្សាយ និងអភិវឌ្ឍកសិកម្មវិញកសិករដាំដុះស្រូវនៅទូទាំងប្រទេស ដែលទទួលបានពូជស្រូវសុទ្ធល្អ បានអបអរសាទរចំពោះការបញ្ចេញពូជស្រូវថ្មីៗចំនួនពីរមុខទៀតគឺពូជផ្ការំដួលប្រាំង និងពូជខា ១៤ បន្ថែមលើពូជដំណើបសៀមង្គល ដែលបានបញ្ចេញនាឆ្នាំកន្លងទៅ ។ ជាមួយនេះ ក៏មានការបញ្ចេញពូជពោតដំណើបស៊ីអឹម១ (CM1: Cambodian maize)ថ្មីទៀតដែលអាចដាំដុះបាននៅតំបន់ចម្ការនិងស្រែទំនាប បន្ទាប់ពីប្រមូលផលស្រូវវស្សារួចភ្លាម ហើយនៅពេលខាងមុខនេះនឹងត្រូវផ្សព្វផ្សាយ ឱ្យបានទូលំទូលាយដល់ប្រជាកសិករនៅទូទាំងប្រទេស ។

ចំពោះការអភិវឌ្ឍសហគមន៍កសិកម្មវិញ ក៏ត្រូវបានយកចិត្តទុកដាក់លើកកម្ពស់ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការអភិវឌ្ឍកសិកម្មប្រមូលផ្ដុំ ក្នុងភាពជាដៃគូជាមួយផ្នែកឯកជននានាដែរ តាមរយៈការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា សំដៅប្រែក្លាយឱ្យទៅជាសហគ្រាសកសិកម្មជនបទ ដោយទទួលបាននូវបច្ចេកទេស ឥណទាន និងធានាបានស្ថិរភាពនៃការផ្គត់ផ្គង់កសិផលទៅកាន់ទីផ្សារ ។ រហូតមកដល់ពេលនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានធ្វើការចុះបញ្ជីសហគមន៍កសិកម្មបានចំនួន ៥៥៥ សហគមន៍នៅទូទាំងប្រទេស ។

សមិទ្ធផលថ្មីមួយទៀតដែលទើបសម្រេចបានហើយដែលនឹងប្រកាសឱ្យដំណើរការនាពេលដ៏ខ្លីខាងមុខ នោះគឺគោលនយោបាយផ្សព្វផ្សាយកសិកម្មកម្ពុជា ក្នុងគោលបំណងបញ្ជ្រាបការយល់ដឹងអំពីបច្ចេកវិទ្យាថ្មីៗដល់ប្រជាកសិករឱ្យកាន់តែទូលំទូលាយ តាមរយៈអ្នកផ្ដល់សេវាផ្សព្វផ្សាយកសិកម្មទាំងអស់ ទាំងនៅក្នុងវិស័យសាធារណៈ ក៏ដូចនៅក្នុងវិស័យឯកជន នៃដៃគូអភិវឌ្ឍន៍។

ផលិតកម្មកៅស៊ូធម្មជាតិក៏មានការរីកចម្រើនគួរឲ្យកត់សម្គាល់ដោយមានសន្ទុះកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ។ ក្នុងឆ្នាំ ២០១៤ ផ្ទៃដីដាំដុះកៅស៊ូបានកើនឡើងដល់ជាង៣៥៧ ពាន់ហិកតា គឺកើនឡើងប្រមាណ ៩,២% បើប្រៀបធៀបនឹងឆ្នាំ ២០១៣ ក្នុងនោះផ្ទៃដីចម្ការកៅស៊ូគ្រួសារមានសមាមាត្រ៤០%,ផ្ទៃដីចម្ការកៅស៊ូសម្បទានសេដ្ឋកិច្ចមាន៤៥%និងផ្ទៃដីចម្ការកៅស៊ូកសិឧស្សាហកម្ម (អតីតចម្ការកៅស៊ូរដ្ឋ)មានសមាមាត្រ ១៥% ។ ផ្ទៃដីចៀរជ័រអនុវត្តបានចំនួនជាង ៩០ ពាន់ហិកតា ដោយទទួលបានផលិតផលជ័រកៅស៊ូជិត ១០០ ពាន់តោន ។ ការនាំចេញកៅស៊ូនៅឆ្នាំ ២០១៤ សម្រេចបានជាង ១០០ ពាន់តោន គឺកើនឡើង ១៦,៣៨% ធៀបទៅនឹងឆ្នាំ ២០១៣ ។

ក្នុងឆ្នាំ២០១៤តម្លៃកៅស៊ូគិតជាមធ្យមប្រហែល១.៥៣៩ដុល្លារអាមេរិកក្នុងមួយតោន បើធៀបនឹងឆ្នាំ២០១៣តម្លៃកៅស៊ូជាមធ្យមមានតម្លៃជាង ២.២០០ ដុល្លារក្នុងមួយតោន ។

ទោះបីជាតម្លៃកៅស៊ូមាននិន្នាការធ្លាក់ចុះក៏ពិតមែន តែក្រោមកិច្ចសហការជាមួយសមាគមបណ្ដាប្រទេសផលិតកៅស៊ូធម្មជាតិ ដែលមានប្រទេស ចំនួន ១១ ជាសមាជិករួមទាំងកម្ពុជាផង ក្រសួងរំពឹងថាតម្លៃកៅស៊ូអាចនឹង កើនឡើងវិញ តាមរយៈការដាក់ចេញនូវវិធានការនានា ដើម្បីធ្វើឱ្យតម្លៃកៅស៊ូមានស្ថិរភាពឡើងវិញ និងមាននិរន្តរភាពសម្រាប់ជាផលប្រយោជន៍ ដល់អ្នកដាំកៅស៊ូ ។

ដោយឡែកការចិញ្ចឹមសត្វ ជលផល និងព្រៃឈើវិញបានបង្ហាញថា ឆ្នាំ២០១៤កន្លងទៅមានវឌ្ឍនភាពការងារផលិតកម្ម និងបសុព្យាបាល ក្នុងរយៈពេលចុងក្រោយនេះ។ ប្រការនេះអាស្រ័យដោយសារការរីកចម្រើននៃផលិតកម្មសត្វរបស់វិស័យឯកជនកាន់តែមានទំហំធំឡើង ក៏ដូចជាការយល់ដឹងរបស់ប្រជាកសិករអំពីបច្ចេកទេសចិញ្ចឹម ការជ្រើសរើស និងការបង្កាត់ពូជ ការរីកចម្រើននៃបច្ចេកវិទ្យាថ្មីៗ ការកើនឡើងនៃការវិនិយោគផលិតចំណីសត្វ ការកាត់បន្ថយការផ្ទុះជំងឺ និងការឆ្លងរាលដាលនៃជំងឺសត្វ ការជំរុញ និងការលើកទឹកចិត្តរបស់រាជរដ្ឋាភិបាលក្នុងផ្នែកចិញ្ចឹមសត្វ និងសេវាសុខភាពសត្វ ។ ជាមួយគ្នានេះ សេចក្ដីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ការចិញ្ចឹមសត្វសម្រាប់រយៈពេល១០ឆ្នាំ កំពុងដំណើរការរៀបចំយ៉ាងយកចិត្តទុកដាក់ និងអនុម័តនៅក្នុងពេលឆាប់ៗខាងមុខនេះ ។ រីឯសេចក្ដីព្រាងច្បាប់ស្ដីពីសុខភាពសត្វ និងផលិតកម្មសត្វ ក៏ត្រូវបានពិនិត្យកែ



*អាជីវកម្មនេសាទត្រីនៅកម្ពុជា កំពុងកើនឡើង*

សម្រួលរួចរាល់ជាស្ថាពរនិងត្រៀមសុំការអនុម័តពីគណៈរដ្ឋមន្ត្រី ដើម្បីបញ្ជូនទៅស្ថាប័ននីតិប្បញ្ញត្តិតាមនីតិវិធី ។

នៅក្នុងឆ្នាំ ២០១៤ នេះ ផ្នែកជលផលបានខិតខំសម្រេចការងារជាច្រើន រួមមាន ការបោះបង្គោល ការសាងសង់ទីស្នាក់ការការពារកន្លែងអភិរក្ស ការយាមល្បាត ការអភិរក្សផ្កាថ្ម ការដាំព្រៃលិចទឹកនិងព្រៃកោងកាង ការរៀបចំអន្លង់ត្រីមេពូជ ការអភិរក្សផ្សោតមេគង្គ ក្រពើ ត្រី សេះសមុទ្រ កន្ធាយក្បាលកង្កែប អណ្តើកសរសៃ ត្រីនាគ...។ល។ទន្ទឹមនេះ គោលការណ៍នៃការកំណត់ឧបករណ៍នេសាទគ្រួសារ ក៏ត្រូវបានកែសម្រួលផងដែរ ដែលធ្វើឱ្យប្រជាជនទូទៅ ជាពិសេសអ្នកប្រកបរបរនេសាទជាលក្ខណៈគ្រួសារអាចធ្វើអាជីវកម្មបានទូលំទូលាយ និងអាចចាប់ត្រីបានច្រើនជាងមុន ។

សហគមន៍នេសាទ ដែលមានភារកិច្ចស្វ័យការពារធនធានជលផល និងអនុវត្តការនេសាទដែលគ្មានបទល្មើស ត្រូវបានបង្កើតឡើងមានចំនួន ៥១៦ ក្នុងនោះសហគមន៍នេសាទទឹកសាបមានចំនួន ៤៧៧ និងសហគមន៍នេសាទសមុទ្រមានចំនួន ៣៩ ។ ការអភិវឌ្ឍវារីវប្បកម្មទឹកសាប និងសមុទ្រអនុវត្តបានប្រមាណ១២០ ពាន់តោន ស្មើនឹង១២០%នៃផែនការ ។

ដោយឡែក ចំពោះសកម្មភាពការងាររបស់រដ្ឋបាលព្រៃឈើ ក្នុងរយៈកាលកន្លងមកសម្រេចបាននូវភារកិច្ចជាច្រើនរួមមាន ការបង្កើត និងការពង្រឹងសហគមន៍ព្រៃឈើ ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ការអនុវត្តវិធានការម៉ឺងម៉ាត់ក្នុងការគ្រប់គ្រង និងការទប់ស្កាត់បទល្មើសព្រៃឈើ ការពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងព្រៃបម្រុងទុក ការបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានពន្ធុរុក្ខជាតិ និងសត្វព្រៃ ការបោះបង្គោលព្រំប្រទល់ព្រៃបម្រុងទុកអចិន្ត្រៃយ៍ ការបណ្តុះកូនឈើនៅតាមស្ថានីយផ្សព្វផ្សាយ និងការដាំកូនឈើនៅតំបន់ស្តារព្រៃឈើឡើងវិញ ។

ចំពោះការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច បន្ទាប់ពីមានបទបញ្ជាលេខ ០១ បប.ចុះថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០១២ របស់រាជរដ្ឋាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានផ្តោតការយកចិត្តទុកដាក់ទៅលើការធ្វើបច្ចុប្បន្នកម្មសម្បទានដីសេដ្ឋកិច្ច និងកំពុងផ្តល់យោបល់ជូនគណៈកម្មការអន្តរក្រសួង តាមលំដាប់លំដោយជាបន្តបន្ទាប់ ដើម្បីពិនិត្យ និងសម្រេច ។ ក្រសួងសម្រេចដកហូតដីសម្បទានសេដ្ឋកិច្ចបានចំនួនជាង ១៧ ម៉ឺនហិកតាពីបណ្តាក្រុមហ៊ុនដែលមិនបានគោរពតាមកិច្ចសន្យា និងបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាល ។

ទន្ទឹមនឹងលទ្ធផលខាងលើនេះ ទិសដៅការងារអនុវត្តបន្ត សម្រាប់ឆ្នាំ ២០១៥-២០១៦ ដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី ៣ និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨ ដែលនឹងត្រូវប្រកាសផ្សព្វផ្សាយនាពេលឆាប់ៗខាងមុខ ។

ផ្អែកលើផែនការយុទ្ធសាស្រ្ត ៥ ឆ្នាំរបស់ខ្លួន ដែលជាផែនទីបង្ហាញផ្លូវ ក្រសួងបានដាក់ចេញនូវទិសដៅការងារសំខាន់ៗមួយចំនួន នៅក្នុងឆ្នាំ ២០១៥ នេះ។ ក្នុងនោះគឺរិះរកវិធីសាស្រ្តនិងវិធានការចាំបាច់នានា ដើម្បីបង្កើនប្រសិទ្ធភាពសេដ្ឋកិច្ច ក្នុងការធ្វើប្រពលវប្បកម្មដំណាំ ជាពិសេសដំណាំស្រូវ ដោយខិតខំកាត់បន្ថយថ្លៃដើមផលិត បង្កើនទិន្នផល បង្កើនខ្សែចង្វាក់តម្លៃសំដៅធានាប្រាក់ចំណូលខ្ពស់ និងពង្រឹងសមត្ថភាពបន្សាំជាមួយហានិភ័យនៃគ្រោះធម្មជាតិ ចាប់តាំងពីការផលិត ការប្រមូលផល ការធ្វើសម្ងួត ការកែច្នៃ ការដឹកជញ្ជូននិងការធ្វើពាណិជ្ជកម្ម ។

ពិនិត្យ និងធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្រ្តសម្រាប់ការអភិវឌ្ឍកៅស៊ូធម្មជាតិនៅកម្ពុជាឱ្យស្របនឹងបរិបទនៃសកលភាវូបនីយកម្ម និងជំរុញការចងក្រងសហគមន៍អ្នកដាំកៅស៊ូគ្រួសារបន្ថែមទៀត ។ តាមដានជាប់ជាប្រចាំអំពីនិន្នាការនៃទីផ្សារ និងតម្លៃកៅស៊ូធម្មជាតិ និងរៀបចំចងក្រងស្ថិតិកៅស៊ូឱ្យបានច្បាស់លាស់ ។



*ដំណាំដំឡូងមីជាដំណាំឧស្សាហកម្មរបស់ប្រជាកសិករកម្ពុជា*

ខិតខំរៀបចំចងក្រងច្បាប់ស្តីពីភូតគាមអនាម័យ ច្បាប់ស្តីពីការគ្រប់គ្រងដីកសិកម្ម និងលិខិតបទដ្ឋានគតិយុត្តស្ថិតក្រោមច្បាប់ស្តីពីសហគមន៍កសិកម្ម ។ ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ដើម្បីធានាការផ្គត់ផ្គង់ទីផ្សារប្រកបដោយស្ថិរភាព និងនិរន្តភាព ។

បន្តជំរុញការចិញ្ចឹមសត្វតាមគ្រប់រូបភាព ឱ្យបានខ្លាំងក្លាថែមទៀត ដើម្បីធានាការផ្គត់ផ្គង់សាច់នៅក្នុងស្រុក កាត់បន្ថយការនាំចូល និងឈានទៅដល់ការនាំចេញទៅបរទេស ។ បន្តពង្រឹងការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វ ស្តង់ដារអនាម័យ នៅតាមកសិដ្ឋានចិញ្ចឹមសត្វ កន្លែងប្រមូលផ្តុំសត្វ និងសត្តឃាតដ្ឋានដើម្បីការពារសុខភាពសាធារណៈ។ទន្ទឹមនឹងនេះត្រូវខិតខំកសាងលិខិតបទដ្ឋានគតិយុត្តបន្ថែមទៀត ដូចជា ប្រកាសស្តីពីការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វជាដើម ។

ជំរុញការអភិវឌ្ឍវារីវប្បកម្មទឹកសាប និងសមុទ្រ ឱ្យកាន់តែមានប្រសិទ្ធភាព ដើម្បីបង្កើនផលត្រីសម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងស្រុកបម្រើការនាំចេញ កាត់បន្ថយការពឹងផ្អែកតែលើប្រភពត្រីធម្មជាតិ និងកាត់បន្ថយការនាំចូលជលផលពីខាងក្រៅ ។

ត្រូវបន្តអនុវត្តការកែទម្រង់លើការគ្រប់គ្រងដីធ្លី និងព្រៃឈើ ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ប្រកបដោយស្មារតីទទួលខុសត្រូវ ។ សហការឱ្យបានល្អប្រសើរជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីជំរុញការដាំឈើ ការដាំព្រៃលិចទឹក ការបោះបង្គោលព្រំប្រទល់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។

បន្តត្រួតពិនិត្យការអនុវត្តកិច្ចសន្យាស្តីពីសម្បទានដីសេដ្ឋកិច្ច និងបន្តកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ។

គ្រប់អង្គភាពទាំងអស់ និងមន្ទីរកសិកម្មរាជធានី-ខេត្តត្រូវជំរុញការអនុវត្តផែនការថវិកា តាមកម្មវិធីប្រកបដោយប្រសិទ្ធភាពខ្ពស់ ដោយអនុលោមតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ២០១៥ និងកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ។ យកចិត្តទុកដាក់ទទួលខុសត្រូវខ្ពស់ក្នុងការប្រមូលចំណូលហើយបង់ចូលថវិកាជាតិ និងការស្វះស្វែងកៀរគររកប្រភពថវិកាពីដៃគូអភិវឌ្ឍន៍នានាសម្រាប់វិស័យកសិកម្ម ដើម្បីជួយទ្រទ្រង់ដល់ការប្រើប្រាស់ថវិកាជាតិដែលនៅមានកម្រិតនៅឡើយ។

ជំរុញការយកចិត្តទុកដាក់រៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្តិ ផែនការយុទ្ធសាស្រ្ត ស្តង់ដារ និងគោលការណ៍ ព្រមទាំងពង្រឹងសមត្ថភាពធនធានមនុស្ស និងការងារយេនឌ័រ សមត្ថភាពស្ថាប័ននិងរចនាសម្ព័ន្ធចាត់តាំងនៅក្នុងអង្គភាពក្រោមឱវាទ ។ ត្រៀមលក្ខណៈសម្បត្តិលើគ្រប់ការងារដែលពាក់ព័ន្ធដល់វិស័យកសិកម្ម សម្រាប់ធ្វើសមាហរណកម្មទៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាននៅចុងឆ្នាំ ២០១៥ ៕

# សមិទ្ធផលវិស័យសុខាភិបាលឆ្នាំ ២០១៤ និងទិសដៅឆ្នាំ ២០១៥



*អគារថ្មីនៃមន្ទីរពេទ្យកាល់ម៉ែត រាជធានីភ្នំពេញ*

ក្នុងឆ្នាំ ២០១៤ កន្លងទៅនេះក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានទទួលពានរង្វាន់ជំណោះស្រាយឆ្នាំ ២០១៤ ពីក្រុមប្រឹក្សាអ្នកដឹកនាំពិភពលោក ដើម្បីសុខភាពបន្តពូជ( Global Leaders Council For Repductive Health ) ដែលមានទីស្នាក់ការនៅទីក្រុងវ៉ាស៊ីងតោនសហរដ្ឋអាមេរិកក្នុងការទទួលស្គាល់ស្នាដៃនិងជោគជ័យរបស់កម្ពុជាសម្រាប់ការកាត់បន្ថយបានយ៉ាងឆាប់រហ័សនូវអត្រាមរណភាពរបស់មាតា និងការពន្លឿនការផ្ដល់សេវាសុខភាពបន្តពូជជាសកល ក្នុងព្រះរាជាណាចក្រកម្ពុជា ។ លទ្ធផលនេះ ជាផ្នែកមួយនៃជោគជ័យរបស់កម្ពុជាក្នុងវិស័យសុខាភិបាល។

យោងតាមរបាយការណ៍សមិទ្ធផលសុខាភិបាលឆ្នាំ ២០១៤ ទិសដៅការងារឆ្នាំ២០១៥ដែលបានបង្ហាញនៅក្នុងសន្និបាតសុខាភិបាលលើកទី៣៦នាខែមីនាឆ្នាំ២០១៥កន្លងទៅនេះបានបញ្ជាក់ថា ទូទាំងប្រទេសមានគ្រឹះស្ថានសាធារណរដ្ឋបាលចំនួន ៧ ដែលក្នុងនោះមាន៖ មន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត មន្ទីរពេទ្យព្រះកុសមៈ មន្ទីរពេទ្យកុមារជាតិ សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល( ដោយរាប់បញ្ចូលទាំងសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រ )វិទ្យាស្ថានសុខភាពសាធារណៈ មជ្ឈមណ្ឌលជាតិពិសោធន៍វេជ្ជសាស្ត្រ និងមន្ទីរពេទ្យព្រះអង្គឌួង។ ដោយឡែកមន្ទីរពេទ្យកាល់ម៉ែតបានក្លាយខ្លួនពីគ្រឹះស្ថានសាធារណៈរដ្ឋបាល ទៅជាគ្រឹះស្ថានសាធារណៈសុខាភិបាលដែលមានឋានៈស្មើអគ្គនាយកដ្ឋាន។ ទន្ទឹមនេះដែរ ក៏មានទីភ្នាក់ងារប្រតិបត្តិការពិសេសចំនួន៣៦អង្គភាព៖រួមមានមន្ទីរពេទ្យខេត្ត និងស្រុកប្រតិបត្តិដែលគ្រប់ដណ្ដប់មន្ទីរពេទ្យបង្អែក និង មណ្ឌលសុខភាព ដែលស្ថិតនៅក្នុងតំបន់ទទួលខុសត្រូវរបស់ស្រុកប្រតិបត្តិទាំងអស់នោះ។ ក្រសួងក៏មានផែនការបង្កើតទីភ្នាក់ងារប្រតិបត្តិការពិសេស៤ទៀតនៅក្នុងឆ្នាំ ២០១៥ នេះ។ គិតត្រឹមដំណាច់ខែធ្នូឆ្នាំ ២០១៤ មូលដ្ឋានសុខាភិបាលសាធារណៈរួមមានមណ្ឌលសុខភាពចំនួន ១ ១០៥ និងប៉ុស្ដិ៍សុខភាព ១០៦ និងមន្ទីរពេទ្យ ១០៥ ក្នុងនោះមានមន្ទីរពេទ្យជាតិចំនួន ៨ និងមន្ទីរពេទ្យបង្អែកចំនួន ៩៧ ។

គួរកត់សម្គាល់ថា ចំនួនមណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែកបានកើនឡើងជារៀងរាល់ឆ្នាំ។ក្នុងឆ្នាំ២០១៤ស្រុកប្រតិបត្តិកើនចំនួន៧,មន្ទីរពេទ្យបង្អែកកើន១១ និងមណ្ឌលសុខភាពកើនចំនួន១៧។

បម្រើឲ្យវិស័យសុខាភិបាលសាធារណៈនេះដែរ គិតត្រឹមថ្ងៃទី ១ ខែមករាឆ្នាំ២០១៥ មន្ត្រី បុគ្គលិក សុខាភិបាលមានចំនួន ២០ ៩៧៤ នាក់ ក្នុងនោះរួមមាន វេជ្ជបណ្ឌិត ២ ៣៤៧ នាក់( វេជ្ជបណ្ឌិតឯកទេស ៣៧៧ នាក់ )គ្រូពេទ្យមធ្យម ៩០៦ នាក់ ទន្តបណ្ឌិត ២៤៣ នាក់ ឱសថការី ៥២៦ នាក់ គិលានុប្បដ្ឋាក-យិកាមធ្យម ៥ ៧០០នាក់ គិលានុប្បដ្ឋាកយិកាបឋម ៣ ២៩៩ នាក់ ឆ្មបមធ្យម ២ ៩៦៣ នាក់ ឆ្មបបឋម ២ ៣២៧ នាក់ និងអ្នកបច្ចេកទេសមន្ទីរពិសោធន៍មធ្យម ៤៨៤ នាក់ ។

គួររំឭកថា ចំនួនបុគ្គលិកសុខាភិបាលសរុបនៅឆ្នាំ ២០១៤ កើនលើសឆ្នាំ២០១៣ចំនួន៣០៦នាក់។ ដោយឡែកឆ្មបមធ្យមកើនឡើងពី ២ ៧៣៤ នាក់នៅឆ្នាំ២០១៣នាក់ ទៅ ២ ៩៦៣ នាក់ នៅឆ្នាំ ២០១៤ ។ ឆ្មបបឋមមានការថយចុះពី ២ ៣៣២ នាក់ នៅឆ្នាំ ២០១៣ មកនៅត្រឹម ២ ៣២៧ នាក់ នៅឆ្នាំ ២០១៤ ប៉ុន្តែគិលានុប្បដ្ឋាក-យិកាមធ្យមកើនឡើងពី៣ ៣៨៧ នាក់នៅឆ្នាំ២០១៣ទៅ ៣ ២៩៩ នាក់ក្នុងរយៈពេលដូចគ្នា។

ក្នុងឆ្នាំ ២០១៤ នេះដែរ ប្រជាពលរដ្ឋគ្រប់វ័យដែលបានមកពិនិត្យពិគ្រោះជំងឺនៅមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកទូទាំងប្រទេសមានចំនួន ៩ ៨៧៣ ៥៣៧ ករណី( ទាបជាងឆ្នាំ២០១៣ដែលមាន១០ ១៨៧ ៧៩០ ករណី )ក្នុងនោះករណីថ្មីមានចំនួន ៨ ៩៥១ ៦៧៧ ករណី។ បើគិតជាចំនួនលើកនៃការពិគ្រោះជំងឺ ករណីថ្មីរបស់ប្រជាពលរដ្ឋម្នាក់ក្នុងឆ្នាំ ២០១៤ គឺ ០,៥៩ លើក។ ជាការគួរឲ្យកត់សម្គាល់មណ្ឌលសុខភាពទូទាំងប្រទេសទទួលពិគ្រោះជំងឺករណីថ្មីរហូតដល់ ៨៥,៦% នៃការពិគ្រោះជំងឺករណីថ្មីសរុប ខណៈដែល ១៤,៤% ទៀតត្រូវបានធ្វើឡើងនៅមន្ទីរពេទ្យជាតិនិងមន្ទីរពេទ្យបង្អែកទាំងអស់។

ជាការកត់សម្គាល់មួយទៀត និន្នាការនៃការពិគ្រោះជំងឺករណីថ្មីលើប្រជាជនម្នាក់ក្នុងមួយឆ្នាំនៅមូលដ្ឋានសុខាភិបាលសាធារណៈ បានស្ទុះងើបឡើងពី ០,៤៥ នៅឆ្នាំ ២០០៨ ទៅ ០,៦៤ នៅឆ្នាំ ២០១០ ។ ប៉ុន្តែចាប់ផ្ដើមធ្លាក់ចុះមកវិញជាបន្តបន្ទាប់ពីឆ្នាំ ២០១១ មកនៅត្រឹម ០,៥៩ នៅឆ្នាំ ២០១៤ ពោលគឺថយចុះចំនួន ០,០១% ក្នុងរយៈ ៣ ឆ្នាំចុងក្រោយ។

តាមអនុសាសន៍របស់អង្គការសុខភាពពិភពលោក ជាទូទៅចំនួនលើកនៃការពិគ្រោះជំងឺករណីថ្មីក្នុងប្រជាជនម្នាក់ក្នុង ១ ឆ្នាំគឺ ១ លើកសម្រាប់ប្រទេសកំពុងអភិវឌ្ឍតួយ៉ាងដូចជាប្រទេសកម្ពុជាជាដើម។

ជាការគួរកត់សម្គាល់មួយទៀត ចំនួនលើកនៃការពិគ្រោះជំងឺថ្មីក្នុងប្រជាជនម្នាក់ក្នុង១ឆ្នាំមានគម្លាតគ្នាយ៉ាងខ្លាំងរវាងខេត្តមួយទៅខេត្តមួយពីខ្ពស់បំផុត០,៩៧នៅខេត្តសៀមរាប មកទាបបំផុត០,២១ នៅរាជធានីភ្នំពេញ ។

របាយការណ៍បានបង្ហាញទៀតថា ក្នុងឆ្នាំ២០១៤អ្នកជំងឺគ្រប់វ័យទាំង ២ ភេទដែលត្រូវដាក់ឲ្យសម្រាកព្យាបាលជំងឺនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ និងបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យទូទាំងប្រទេសមានចំនួន ៦១០ ៤៦៣ នាក់( ដោយមិនរាប់បញ្ចូលអ្នកជំងឺរបេង )។ បើគិតជាចំនួនថ្ងៃសរុបព្យាបាលចំនួន ២ ៧២៦ ៩០៥ ថ្ងៃ ឬចំនួនថ្ងៃសម្រាកព្យាបាលមធ្យមចំនួន ៤,៥ ថ្ងៃ( ៤ថ្ងៃកន្លះ )។ ដោយឡែកអ្នកជំងឺដែលបានចេញពីមន្ទីរពេទ្យដោយគ្មានការអនុញ្ញាតចំនួន ៣ ៤៨៥ នាក់។ការធ្លាក់ចុះនៃចំនួនអ្នកជំងឺសម្រាកព្យាបាលរវាងឆ្នាំ២០១១និងឆ្នាំ២០១៤ មាននិន្នាការស្របគ្នាទៅនឹងការធ្លាក់ចុះនៃចំនួនករណីថ្មី នៃការពិគ្រោះជំងឺនៅក្នុងរយៈពេលដូចគ្នានេះ។ ប៉ុន្តែប្រការដែលគួរឲ្យកត់សម្គាល់គឺនៅឆ្នាំ២០១៤នេះ ករណីវះកាត់ធំសរុបចំនួន ៧៧ ៣៧៥ ករណី និងវះកាត់តូច ៤០ ១២៦ ករណី ។

ដោយឡែកក្នុងឆ្នាំ២០១៤នេះដែរមានអ្នកជំងឺចំនួន ៥ ៨៦២នាក់បានស្លាប់ក្នុងចំណោមអ្នកជំងឺសម្រាកពេទ្យសរុប ៥៧១ ៨៣០ នាក់ និងអ្នកជំងឺរបេង ៦២ នាក់ អ្នកបានស្លាប់ស្មើនឹង១,៥៦% នៃអ្នកជំងឺរបេង ៧ ២២៥ នាក់ដែលបានសម្រាកព្យាបាល ហើយបើគិតជាចំនួនថ្ងៃសម្រាកព្យាបាលសរុបចំនួន ៣៥១ ៨៥៧ ថ្ងៃ។

អត្រាស្លាប់ជាមធ្យមនៅក្នុងមន្ទីរពេទ្យមានកម្រិតទាប គឺ ០,៩៧%។ ការថយចុះនៃអត្រាស្លាប់នៅមន្ទីរពេទ្យ ជាសូចនាករមួយដែលវាស់អំពីគុណភាពនៃសេវាពិនិត្យព្យាបាល និងថែទាំជំងឺនៅមន្ទីរពេទ្យ។

ទន្ទឹមនេះដែរ អត្រាមធ្យមនៃការប្រើប្រាស់គ្រែនៅមន្ទីរពេទ្យសាធារណៈទូទាំងប្រទេសក្នុងឆ្នាំ២០១៤បានឡើងខ្ពស់រហូតដល់៩៥,២០%។ ចំនួនគ្រែសរុបនៃមន្ទីរពេទ្យទូទាំងប្រទេសមានចំនួន ១២ ២៤៩គ្រែ ដោយរាប់បញ្ចូលទាំងគ្រែសម្រាប់អ្នកជំងឺរបេងចំនួន ២ ៣៥២ គ្រែ។

ដើម្បីជួយដល់ជនក្រីក្របច្ចុប្បន្នមូលនិធិសមធម៌កំពុងត្រូវបានអនុវត្ត



មន្ទីរពេទ្យកុមារជាតិ ក្នុងរាជធានីភ្នំពេញ



មន្ទីរពេទ្យរ៉ូយ៉ាល់ភ្នំពេញ ក្នុងរាជធានីភ្នំពេញ

នៅក្នុង៦១ស្រុកប្រតិបត្តិក្នុងចំណោមស្រុកប្រតិបត្តិសរុបចំនួន៨៨នៃ២៥ រាជធានី ខេត្ត ក្នុងនោះមណ្ឌលសុខភាព ៦០២ ឬស្មើនឹង ៥៤% នៃចំនួនមណ្ឌលសុខភាពសរុប១១០៥មន្ទីរពេទ្យបង្អែកចំនួន៦៣(៦៣%នៃចំនួនមន្ទីរពេទ្យបង្អែកសរុបចំនួន៩៩)និងមន្ទីរពេទ្យជាតិ។ នៅឆ្នាំ ២០១៤ កម្មវិធីមូលនិធិសមធម៌កំពុងគ្របដណ្ដប់ដល់ប្រជាជនក្រីក្រប្រមាណ ២,៦ លាននាក់(តាមការកំណត់អត្តសញ្ញាណក្រីក្រមុន និងនៅពេលទៅប្រើប្រាស់សេវា) ។

ក្នុងពេលដូចគ្នានេះដែរ សេវាសុខាភិបាលឯកជនគ្រប់ប្រភេទដែលកំពុងផ្ដល់សេវាសុខភាពត្រូវបានកត់សម្គាល់ឃើញថា មានចំនួនលើសមូលដ្ឋានសុខាភិបាលសាធារណៈទូទាំងប្រទេសជាង៤ដង(ទាំងស្វែងរកកម្រៃនិងមិនរកកម្រៃ)។គិតត្រឹមថ្ងៃ៣១ខែធ្នូឆ្នាំ២០១៤ សរុបចំនួនសេវាសុខាភិបាលឯកជនមានចំនួន ៥ ៧៥៧ កន្លែងចាប់ពីមន្ទីរពេទ្យរហូតដល់បន្ទប់ថែទាំជំងឺ និងចាប់ពីឱសថស្ថានទៅឱសថស្ថានរង ក និង ខ ចំនួន ១ ៩១៩ កន្លែង ។

ទន្ទឹមនេះ ក្រសួងសុខាភិបាលបាននិងកំពុងយកចិត្តទុកដាក់លើការគ្រប់គ្រងវិស័យសេវាឯកជនក្នុងនេះរួមមាន ជំរុញសកម្មភាព របស់គណៈកម្មការអន្តរក្រសួងទូទាំង ២៥ រាជធានី ខេត្តក្នុងការចុះត្រួតពិនិត្យកន្លែងផ្ដល់សេវាឯកជន វិធានការណែនាំ និងរៀបចំឲ្យអ្នកផ្ដល់សេវាចុះកិច្ចសន្យាកែប្រែលើការអនុវត្តមិនសមស្របតាមលក្ខណៈច្បាប់ និងលក្ខណៈបច្ចេកទេស ។

ជាទិសដៅការងារសម្រាប់ឆ្នាំ ២០១៥ នេះ ទាក់ទងទៅនឹងការពង្រឹងប្រព័ន្ធសុខាភិបាល ក្រសួងបានដាក់ចេញនូវសកម្មភាពអាទិភាពមួយចំនួនដែលក្នុងនោះមាន៖ ជំរុញការធ្វើបច្ចុប្បន្នភាពផែនការគ្របដណ្ដប់សុខាភិបាលទៀងទាត់។ ពង្រីកយន្តការផ្ដល់សេវាសុខាភិបាលសាធារណៈដូចជា ទីភ្នាក់ងារប្រតិបត្តិការពិសេសនិងគ្រឹះស្ថានសាធារណៈរដ្ឋបាល ។ លើកកម្ពស់ប្រព័ន្ធផ្គត់ផ្គង់ឱសថបរិក្ខារទាន់ពេលវេលា បរិមាណគ្រប់គ្រាន់ គុណភាពល្អ និងប្រើប្រាស់មានប្រសិទ្ធភាព។ លើកកម្ពស់ការប្រើប្រាស់ឱសថបូរាណនៅមូលដ្ឋានសុខាភិបាល។ លើកកម្ពស់សមត្ថភាពសេវាមន្ទីរពិសោធន៍ ដោយរាប់បញ្ចូលទាំងសេវាធនាគារឈាមធានាបរិមាណឈាមផ្គត់ផ្គង់គ្រប់គ្រាន់ និងសុវត្ថិភាពនៃការប្រើប្រាស់ឈាម ។ អភិវឌ្ឍប្រព័ន្ធទទួលស្គាល់គុណភាពទាំងវិស័យសុខាភិបាលសាធារណៈ និងឯកជន។អនុវត្តការបង្ការ និងការត្រួតពិនិត្យការចម្លងរោគនៅមូលដ្ឋានសុខាភិបាលសាធារណៈ និងឯកជន ។ លើកកម្ពស់ការគ្រប់គ្រងកាកសំណល់វេជ្ជសាស្ត្រនៅគ្រប់មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក។លើកកម្ពស់ការគ្រប់គ្រង និងការថែទាំបរិក្ខាវេជ្ជសាស្ត្រ និងការថែទាំអគារ ។

ក្នុងឆ្នាំ ២០១៥ នេះដែរ ក្រសួងក៏មានផែនការសាងសង់មណ្ឌលសុខភាព ប៉ុស្តិ៍សុខភាព បន្ទប់រង់ចាំ ការសម្រាលនៅតាមមណ្ឌលសុខភាពនិងសាងសង់បន្ថែមអគារមន្ទីរពេទ្យ។ បង្កើនការផ្គត់ផ្គង់ថាមពលអគ្គិសនីនិងទឹកស្អាតនៅមូលដ្ឋានសុខាភិបាល ពិសេសសនៅតំបន់ជនបទដាច់ស្រយាល។ ផ្គត់ផ្គង់ឧបករណ៍ពេទ្យស្តង់ដារសម្រាប់សំណុំសកម្មភាពអប្បបរមានៃមណ្ឌលសុខភាពនិងសំណុំសកម្មភាពបង្គ្រប់នៃមន្ទីរពេទ្យបង្អែក។ បង្កើនការវិនិយោគលើឧបករណ៍វេជ្ជសាស្ត្រទំនើប និងបច្ចេកវិទ្យាវេជ្ជសាស្ត្រខ្ពស់ ។ ផ្គត់ផ្គង់មធ្យោបាយបញ្ជូនជំងឺតាមរថយន្តគិលានសង្គ្រោះសម្រាប់ការបញ្ជូនជំងឺបន្ទាន់។ ធ្វើបច្ចុប្បន្នភាពផែនការរយៈពេលមធ្យម ដូចជាផែនការប្រតិបត្តិប្រចាំឆ្នាំ ផែនការយុទ្ធសាស្ត្រថវិកា កម្មវិធីវិនិយោគ ផែនការចំណាយរយៈពេលមធ្យម ផែនការលទ្ធកម្ម ។ តម្រៀបតម្រង់មូលនិធិជំនួយដើម្បីគាំទ្រដល់អាទិភាពវិស័យសុខាភិបាល ។ ពង្រីកការគ្របដណ្ដប់នៃកម្មវិធីមូលនិធិសមធម៌ និងយន្តការហិរញ្ញប្បទានគាំពាប្រជាជនក្រីក្រ និងអភិវឌ្ឍន៍វិធីសាស្ត្រទូទាត់ចំណាយសេវាដល់អ្នកផ្គត់ផ្គង់សេវាសុខភាព។ អភិវឌ្ឍន៍សមត្ថភាពស្ថាប័នសម្រាប់ការគាំពារសុខភាពសង្គមដោយធ្វើសុខដុមនីយកម្ម និងសមាហរណកម្មយន្តការហិរញ្ញប្បទានសុខាភិបាលផ្សេងៗ។ បង្កើនជំនាញបច្ចេកទេស និងសមត្ថភាពធនធានមនុស្សសុខាភិបាលតាមរយៈការបណ្ដុះបណ្ដាលមានលក្ខណៈមូលដ្ឋាន និងក្រោយមូលដ្ឋាន និងហាត់ការនៅនឹងកន្លែង។ ពង្រឹងក្របខណ្ឌវិជ្ជាជីវៈក្រមសីលធម៌ និងគុណភាពការងារ ដោយអភិវឌ្ឍ និងអនុវត្តប្រព័ន្ធទទួលស្គាល់វិជ្ជាជីវៈសម្រាប់វិស័យសាធារណៈ និងឯកជននិងពង្រឹងការអនុវត្តលក្ខន្តិកៈមន្ត្រីរាជការសុខាភិបាល ។ បែងចែកនិងថែរក្សាទុកបុគ្គលិកដោយផ្ដល់អាទិភាពដល់បុគ្គលិកដែលចាំបាច់សម្រាប់អាទិភាពក្នុងវិស័យសុខាភិបាល ពិសេសការពង្រីកបុគ្គលិកទៅកាន់តំបន់ជនបទ ។ លើកកម្ពស់ការផ្គត់ផ្គង់ការផ្ដល់ប្រាក់ឧបត្ថម្ភនៅតាមមូលដ្ឋានសុខាភិបាលមានប្រភពពីការបង់ថ្លៃសេវាមូលនិធិសមធម៌ និងយន្តការហិរញ្ញប្បទានដទៃទៀត។បង្កើនការចូលរួមពីសេវាសុខាភិបាលឯកជនក្នុងរាយការណ៍តាមប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាលលើគេហទំព័រ និងអភិវឌ្ឍន៍បទបញ្ញត្តិសម្រាប់ការចូលរួមពីសេវាសុខភាពឯកជន នៅក្នុងប្រព័ន្ធរបាយការណ៍ព័ត៌មានសុខាភិបាល។អភិវឌ្ឍន៍ផែនការយុទ្ធសាស្ត្រសុខាភិបាល២០១៦-២០២០។ ពង្រឹងប្រព័ន្ធចុះបញ្ជីការឱសថសម័យ និងបូរាណ បរិក្ខានិងគ្រឿងសម្អាង និងការត្រួតពិនិត្យតាមដានដើម្បីរក្សាសុវត្ថិភាពឱសថ និងលុបបំបាត់ឱសថក្លែងក្លាយអន់គុណភាព និងគ្មានប្រភពផលិតច្បាស់លាស់។ លើកកម្ពស់ការចូលរួមរបស់សហគមន៍ និងវិស័យឯកជនក្នុងការអភិវឌ្ឍវិស័យសុខាភិបាល ៕



មណ្ឌលសុខភាពព្រៃប្រស់ ក្នុងខេត្តកំពង់ធំ

# ព្រៃកទ័ល នឹងក្លាយជាតំបន់គំរូ ផ្នែកអភិរក្សបរិស្ថាន និង ទេសចរណ៍ធម្មជាតិប្រកបដោយភាពទាក់ទាញ



*ឯកឧត្តម **សាយ សំអាល់** មានប្រសាសន៍ក្នុងកិច្ចប្រជុំ ក្នុងខេត្តសៀមរាប ស្ដីអំពីបញ្ហាបរិស្ថាន*



*ហ្វូងសត្វស្លាបស្មើរផុតពូជលើពិភពលោក មាននៅតំបន់ព្រៃកទ័ល*

ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់ ក្នុងបុព្វហេតុអភិវឌ្ឍប្រទេសជាតិ រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី ៥ ដឹកនាំដោយសម្ដេចតេជោ **ហ៊ុន សែន** បាននិងកំពុងជំរុញការអនុវត្តកម្មវិធីកំណែទម្រង់ស៊ីជម្រៅយ៉ាងសកម្មលើវិស័យជាច្រើន ក្នុងនោះកំណែទម្រង់វិស័យបរិស្ថានមានតួនាទីដ៏សំខាន់មួយ ក្នុងការរួមចំណែកដល់ការជំរុញដំណើរការអភិវឌ្ឍសង្គម សេដ្ឋកិច្ចរបស់កម្ពុជា ។

សកម្មភាពនៃកំណែទម្រង់វិស័យបរិស្ថាន បានសម្រេចលទ្ធផលល្អប្រសើរជាច្រើន ដែលបានបង្កើនការជឿទុកចិត្តចំពោះការខិតខំរបស់ក្រសួងបរិស្ថាន ចាប់តាំងពីការបង្កើតរាជរដ្ឋាភិបាលកម្ពុជានីតិកាលទី ៥ មក ។ បច្ចុប្បន្នក្រសួងបរិស្ថានបាន និងកំពុងបន្តអនុវត្តកំណែទម្រង់នេះ សំដៅធ្វើឲ្យការគ្រប់គ្រងបរិស្ថាននៅក្នុងប្រទេសកម្ពុជា មានភាពកាន់តែប្រសើរឡើង ឆ្លើយតបទៅនឹងសំណូមពរនៃការអភិវឌ្ឍផង និងសំណូមពរនៃការលើកកម្ពស់បរិស្ថានរស់នៅរបស់ប្រជាជនផង ។

ដើម្បីសម្រេចគោលបំណងនេះ ក្រសួងបរិស្ថាន បានរៀបចំពង្រឹងសមត្ថភាពស្ថាប័ន តាមរយៈការកែសម្រួលមុខងាររចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួង ការកែសម្រួលរបៀបរបបការងារ កិច្ចការគ្រប់គ្រងបុគ្គលិករដ្ឋបាល និងហិរញ្ញវត្ថុ សំដៅធ្វើទំនើបកម្មស្ថាប័ន ឲ្យកាន់តែមានប្រសិទ្ធភាពការងារ ដើម្បីសម្រេចគោលដៅអាទិភាពចំនួនបីរបស់ក្រសួងគឺ : កិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប។ ជាក់ស្ដែងនៅក្នុងកិច្ចខិតខំប្រឹងប្រែងសម្រេចគោលដៅជាអទិភាពទាំង ៣ នេះរាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងបរិស្ថានបានចាប់ផ្ដើមធ្វើការកែសម្រួលការគ្រប់គ្រងតំបន់ព្រៃកទ័លឡើងវិញ ដើម្បីប្រែក្លាយជាគំរូនៃតំបន់ទេសចរណ៍ធម្មជាតិមួយប្រកបដោយភាពទាក់ទាញ ។

ថ្លែងក្នុងសិក្ខាសាលាអំពីការធ្វើបច្ចុប្បន្នភាព ផែនការគ្រប់គ្រងតំបន់ស្នូលព្រៃកទ័ល ឯកឧត្ដម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថានបានមានប្រសាសន៍ថា រាជរដ្ឋាភិបាលនឹងអភិរក្សព្រៃកទ័លឱ្យទៅជាតំបន់ដែលមានសក្ដានុពលផ្នែកទេសចរណ៍ធម្មជាតិដ៏សំខាន់បំផុត ក្នុងការទាក់ទាញភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ ។ ឯកឧត្ដមបញ្ជាក់ថា រាជរដ្ឋាភិបាលនឹងបង្កើតផែនការគ្រប់គ្រងថ្មីរយៈពេល ៥ ឆ្នាំ គឺចាប់ពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៩ ដែលនឹងមានសមាសភាពចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ក្នុងនោះមានក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អង្គការសង្គមស៊ីវិល និងអាជ្ញាធរដែនដី ។ ផែនការថ្មីនេះនឹងទទួលបានការគាំទ្រថវិកា និងបច្ចេកទេសពីរាជរដ្ឋាភិបាល និងដៃគូអន្តរជាតិ ដែលផ្ដោតសំខាន់លើកម្មវិធីជាច្រើនតាមរយៈការថែរក្សាតំបន់ស្នូល ការអភិរក្ស និងគ្រប់គ្រងធនធានធម្មជាតិ ការសិក្សាស្រាវជ្រាវ ការអភិវឌ្ឍអេកូទេសចរណ៍ ការបង្កើត និងពង្រឹងសហគមន៍តំបន់ការពារធម្មជាតិ ។





ឯកឧត្តម **សាយ សំអាល់** បានបន្តថា តំបន់ស្នូលព្រែកទ័លជាបន្ទាយពងកូនរបស់សត្វស្លាបធំជាងគេបំផុត ដែលនៅសល់ចុងក្រោយក្នុងតំបន់អាស៊ីអាគ្នេយ៍ដែលត្រូវបានការពារ និងអភិរក្ស មិនតែប៉ុណ្ណោះ ថែមទាំងមានប្រព៍ពណីវប្បធម៌ភូមិអណ្តែកទឹករួមផ្សំជាមួយព្រៃលិចទឹកដ៏ល្អ និងលំហទឹកបឹងទន្លេសាបដ៏ធំល្វឹងល្វើយ ដែលបង្កើតបានជាទេសភាពល្អប្លែកតែមួយគត់នៅក្នុងតំបន់ ហើយបានទាក់ទាញភ្ញៀវទេសចរជាតិ អន្តរ-ជាតិជាច្រើននាក់ទៅទស្សនាកម្សាន្តនៅទីនោះ។ ឯកឧត្តមបន្តទៀតថា ភាពស្រស់ស្អាតរបស់តំបន់ព្រែកទ័ល បានធ្វើឱ្យតំបន់នេះក្លាយជាតំបន់ទេសចរណ៍ទី ២ គឺឱ្យភ្ញៀវទេសចរមកទស្សនាតំបន់សៀមរាបអង្គរ ក៏បន្តមកតំបន់ព្រែកទ័លទៀត ។

ប្រធានអង្គការអភិរក្សសត្វព្រៃប្រចាំកម្ពុជាបានបញ្ជាក់ថា ផែនការគ្រប់គ្រងតំបន់ព្រែកទ័លរយៈពេល ៥ ឆ្នាំនេះ មិនត្រឹមតែការពារបាននូវធនធាន និងទាក់ទាញភ្ញៀវទេសចរប៉ុណ្ណោះទេ ប៉ុន្តែគឺអាចការពារបរិស្ថានទាំងខាងក្នុង និងជុំវិញតំបន់នោះផងដែរ តាមរយៈការគ្រប់គ្រងសំណល់រឹងរាវកុំឱ្យហូរចូលទៅក្នុងទឹកនាំឱ្យបំពុលដល់បរិស្ថាន។ ព្រែកទ័ល គឺជាក្តីសង្ឃឹមចុងក្រោយនៃការអភិរក្សសត្វស្លាបជិតផុតពូជជាច្រើន នៅក្នុងតំបន់ដែលទាមទារឱ្យមានយន្តការការពារ និងអភិរក្សឱ្យបានកាន់តែប្រសើរជាងមុន ។ តាមរយៈកិច្ចសហការរួមគ្នារវាងមន្ត្រីក្រសួងកសិកម្ម និងអង្គការអភិរក្សសត្វព្រៃចាប់តាំងពីឆ្នាំ ១៩៩០ មក បានទប់ស្កាត់ការកាប់ដុតរានព្រៃធ្វើកសិកម្ម រួមជាមួយនឹងព្រៃលិចទឹក ការប្រមាញ់ និងការនេសាទខុសច្បាប់ ដែលមកទល់បច្ចុប្បន្ននេះបានធ្វើឱ្យចំនួនសត្វស្លាបកម្រមានការកើនឡើងជាបន្តបន្ទាប់ ហើយត្រូវបានគេទទួលស្គាល់ថាជាគម្រោងអភិរក្សដ៏ជោគជ័យ ដែលនឹងក្លាយជាគំរូសម្រាប់យកទៅអភិរក្សនៅតំបន់ផ្សេងៗទៀត ។

តំបន់ព្រែកទ័លលាតសន្ធឹងនៅទិសនិរតីនៃបឹងទន្លេសាប មានទីតាំងនៅក្នុងឃុំកោះជីវាំង ស្រុកឯកភ្នំ ខេត្តបាត់ដំបង ដោយមានផ្ទៃក្រឡាជាង



២១ ហិកតា ។ តំបន់នេះមានរុក្ខជាតិជាព្រៃលិចទឹកមានធនធានជីវៈចម្រុះ និងសត្វស្លាបរាប់ម៉ឺនក្បាលរហូតដល់ជាង ២១០ ប្រភេទ ក្នុងនោះ ១២ ប្រភេទ គឺជាប្រភេទជិតផុតពូជ កំពុងរងគ្រោះនៅលើពិភពលោក ។

ព្រែកទ័លជាប្រភពធនធានអេកូទេសចរណ៍ដ៏សំខាន់ជាសកល ដែលផ្តល់ផាសុខភាព ដោយមានភ្ញៀវទេសចរទៅទស្សនាមានការកើនឡើងដល់ជាង ៧ សែននាក់ក្នុងមួយឆ្នាំ ។ តាមរយៈការអភិរក្ស និងអភិវឌ្ឍន៍ក្នុងតំបន់នេះ បានផ្តល់នូវការងារដល់សហគមន៍មូលដ្ឋាន ដូចជាបម្រើការងារជាមន្ត្រីឧទ្យានុរក្ស និងការផ្តល់សេវាកម្មទេសចរណ៍ ធ្វើឱ្យមានប្រាក់ចំណូលសម្រាប់ក្រុមគ្រួសារជារៀងរាល់ថ្ងៃ ។

លើមូលដ្ឋានគោលនយោបាយដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល ដែលត្រូវបានអនុវត្តដោយក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេ-សាទ និងបណ្តាស្ថាប័នផ្សេងទៀត ព្រមទាំងការចូលរួមពីសំណាក់ប្រជា-ពលរដ្ឋ និងដៃគូអភិវឌ្ឍន៍ផ្សេងៗទៀត គម្រោងរៀបចំតំបន់ព្រែកទ័លជាតំបន់គំរូផ្នែកអភិរក្សបរិស្ថាន និងទេសចរណ៍ធម្មជាតិប្រកបដោយភាពទាក់ទាញនឹងសម្រេចបានជោគជ័យនៅពេលខាងមុខនេះ ៕

តមកពីទំព័រទី ១៣

ស៊ានទៅនឹងទីផ្សារពិភពលោកទី៤ ការជំរុញការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម និងការលើកកម្ពស់សហគ្រិនភាព និងភាពច្នៃប្រឌិតថែមទៀតដើម្បីបង្កើនកាលានុវត្តភាពការងារ និងទេពកោសល្យសហគ្រិនដែលជាកម្លាំងចលករប្រកបដោយជវភាពដ៏ចាំបាច់សម្រាប់លើស្ទួយកំណើនសេដ្ឋកិច្ច និងសមធម៌ក្នុងតំបន់ទី៥ ការពង្រឹងសមាហរណកម្មទីផ្សារហិរញ្ញវត្ថុដែលនឹងផ្តល់ នូវអត្ថប្រយោជន៍ដ៏ច្រើនដល់អាស៊ានដូចជាការបង្កើនវិសាលភាពនិងចលនាសាច់ប្រាក់ក្នុងទីផ្សារ ទុនការបង្កើនសមត្ថភាពក្នុងការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ និងការគ្រប់គ្រងរចនាសម្ព័ន្ធទុនបង្វិលរបស់ក្រុមហ៊ុនបានល្អជាដើមទី៦ ការពង្រឹងកិច្ចការពារបរិស្ថានការគ្រប់គ្រងធនធានធម្មជាតិ និងការកាត់បន្ថយផលប៉ះពាល់នៃគ្រោះធម្មជាតិ និងទី៧ ការពន្លឿននូវការកាត់បន្ថយវិសមភាពចំណូលក្នុងស្រុក ដោយធានាការបែងចែកផ្លែផ្កានៃកំណើនប្រកបដោយសមធម៌តាមរយៈការពង្រឹងវិស័យអប់រំ ការផ្ទេរបច្ចេកវិទ្យា និងចំណេះដឹងថ្មីៗរវាងប្រទេសជាសមាជិកទាំងអស់ និងការលើកកម្ពស់សមភាពយេនឌ័រ ដើម្បីធានាឱ្យបាននូវភាពស្មើគ្នារវាងបុរស និងស្ត្រីដែលជាចលករដ៏សំខាន់មួយដែរនៅក្នុងការអភិវឌ្ឍនោះ។

*នៅព្រឹកថ្ងៃទី២៧ ខែមេសា កិច្ចប្រជុំកំពូលអាស៊ានលើកទី២៦បានប្រារព្ធឡើងជាផ្លូវការនៅសាលសន្និសីទទីក្រុងគូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី។ ថ្លែងសុន្ទរ-កថាបើកកិច្ចប្រជុំកំពូលអាស៊ានលើកទី២៦ ឯកឧត្តម **ណាជីប រ៉ាហ្សាក់** នាយករដ្ឋមន្ត្រីម៉ាឡេស៊ី និងជាប្រធានកិច្ចប្រជុំកំពូលអាស៊ានលើកទី២៦ មានប្រសាសន៍ថា ឆ្នាំ២០១៥ នេះគឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសម្រាប់អាស៊ាន ជាមួយនឹងទស្សនៈក្នុងការបង្កើតសហគមន៍អាស៊ាន ដែលនឹងលេចចេញជារូបរាងឡើងនៅក្នុងខែធ្នូខាងមុខ។ តាមរយៈការបង្កើតឡើងនូវសហគមន៍តែមួយនោះវានឹងក្លាយជាមូលដ្ឋានក្នុងការពង្រឹងការឯកភាពរបស់អាស៊ានបន្ថែមទៀត និងពង្រឹងសមាហរណកម្មសម្រាប់រយៈពេល១០ឆ្នាំទៅមុខទៀត។

ឯកឧត្តមនាយករដ្ឋមន្ត្រីមានប្រសាសន៍បញ្ជាក់បន្ថែមថា បណ្តាមេដឹកនាំទាំងអស់ត្រូវតែខិតខំស្វែងរកមធ្យោបាយ ដើម្បីធ្វើឱ្យអាស៊ានមានភាពស្អិតល្មួតបន្ថែមទៀតខាងផ្នែកនយោបាយ។ វិនិយោគិននៅលើពិភពលោកចាប់អារម្មណ៍ខ្លាំងទៅលើតែប្រទេសចិន និងឥណ្ឌាតែអាស៊ានត្រូវតែខិតខំប្រជែងដើម្បីតំណែងនោះនៅក្នុងតំបន់។ ជាមួយនឹងការប្រជែងលើផ្នែកសេដ្ឋកិច្ចយើងបន្តខិតខំ និងយកចិត្តទុកដាក់ទាំងអស់គ្នា ក្នុងការប្រយុទ្ធប្រឆាំងទៅនឹងការបម្រែបម្រួលអាកាសធាតុការប្រយុទ្ធប្រឆាំងទៅនឹងអំពើភេរវកម្ម ក្រុមជ្រុលនិយម រួមទាំងបញ្ហាផ្សេងៗទៀតដែលយើងទាំងអស់គ្នាបន្តយកចិត្តទុកដាក់ដូចគ្នា៕

# ព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំ ២០១៥ នៅខេត្តសៀមរាប ទទួលបានជោគជ័យលើសពីការរំពឹងទុក



*សម្ដេចតេជោ **ហ៊ុន សែន** និង**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** អញ្ជើញជាអធិបតីក្នុងពិធីបើកព្រឹត្តិការណ៍ អង្គរសង្ក្រាន្តឆ្នាំ២០១៥ នៅក្រុងសៀមរាបអង្គរ*

សហភាពសហព័ន្ធយុវជនកម្ពុជាបានរៀបចំ ព្រឹត្តិការណ៍អង្គរសង្ក្រាន្ត ដើម្បីអបអរឆ្នាំថ្មីប្រពៃណីជាតិឆ្នាំមមែ សប្ដស័កដែលប្រារព្ធនៅក្នុងក្រុងអង្គរ ខេត្តសៀមរាប (ថ្ងៃទី១៤-១៦ខែមេសាឆ្នាំ២០១៥) ទទួលបានជោគជ័យលើសពីការរំពឹងទុក។ លើកនេះក៏ជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៃវប្បធម៌និងនយោបាយខ្មែរដែលពុំធ្លាប់មានពីមុនមកផងដែរ។ ប្រមុខរាជរដ្ឋាភិបាលកម្ពុជាសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងឯកឧត្តម សម រង្ស៊ី ប្រធានគណបក្សនៅក្រៅរដ្ឋាភិបាលបានអង្គុយលើវេទិការួមគ្នា ដើម្បីបើកព្រឹត្តិការណ៍អង្គរសង្ក្រាន្ត ដែលបង្ហាញឲ្យឃើញពីសាមគ្គីភាពនៃគ្រួសារខ្មែរ និងអ្នកនយោបាយខ្មែរ ខ្មែររួបរួមគ្នាគឺខ្មែរខ្លាំង។ តាមរយៈព្រឹត្តការណ៍នេះកម្ពុជាក៏ទទួលបាននូវកំណត់ត្រាពិភពលោកចំនួនពីរផងដែរ។

កម្មវិធីបើកអង្គរសង្ក្រាន្ត បានប្រារព្ធជាផ្លូវការនៅព្រឹកថ្ងៃទី១៤មេសានាបរិវេណ ប្រាង្គប្រាសាទអង្គរធំនៃខេត្តសៀមរាប។

សម្ដេចតេជោ បានថ្លែងប្រាប់ភ្ញៀវអន្តរជាតិដែលចូលរួមថា.ប្រទេសយើងខ្ញុំ បានដើរដល់ដំណាក់កាលមួយថ្មីនោះគឺវត្តមានរបស់លោក សម រង្ស៊ី និង លោកជំទាវនៅក្នុងវេទិកានៅថ្ងៃនេះ។ វប្បធម៌ សន្ទនាមួយបានចាប់ផ្ដើមនៅលើទឹកដីកម្ពុជា ជំនួសឱ្យវប្បធម៌នៃការប្រទូស្តរាយនិងការកាប់សម្លាប់គ្នា ។

សម្ដេចតេជោបានបន្តថា ខ្ញុំបានធ្វើកិច្ចការងារនេះដោយអំណត់ជាមួយនឹងសមភាគីរបស់ខ្ញុំ គឺឯកឧត្តម សម រង្ស៊ី ។ មួយរយៈចុងក្រោយនេះខ្ញុំបានជួបដៃគូដ៏ល្អមួយគឺឯកឧត្តម សម រង្ស៊ី ខ្ញុំបាននិយាយនៅក្នុងការចរចាអំពីបញ្ហាពាក់ព័ន្ធជាមួយថា យើងត្រូវបង្កើនការសន្ទនាឱ្យបានច្រើនបំផុតបើអាចធ្វើទៅបាន ។ ឯកឧត្តម សម រង្ស៊ី បានទទួលយកហើយយើងបានក្លាយទៅជាសហស្ថាបនិកនៃវប្បធម៌សន្ទនា ដែលយើងទទួលភារកិច្ចបន្តនិង ដឹកនាំការងារនេះដោយផ្ទាល់របស់យើង ។

នៅក្នុងឱកាសនោះសម្ដេចតេជោ បានធ្វើការកត់សម្គាល់ថាព្រឹត្តិការណ៍អង្គរសង្ក្រាន្តនឹងរំលេចឡើងនូវចំណុចលេចធ្លោមួយចំនួនគឺ ទី១-ការជួបជុំមហាគ្រួសារខ្មែរដើម្បីអបអរសាទរពិធីបុណ្យឆ្នាំនេះ គឺមានអត្ថន័យធំធេងទាំងនយោបាយ ទាំងវប្បធម៌ និង បញ្ហាដទៃទៀត ក្នុងនោះមានចរិតបង្រួបបង្រួមជាតិ និងឯកភាពជាតិរបស់យើង ។ ទី២-គឺរំឭកនិងធ្វើឱ្យរស់រវើកបេតិកភណ្ឌអរូបីនៅលើទីតាំង វប្បធម៌បេតិកភណ្ឌរូបិយ ។ ទី៣- ជាព្រឹត្តិការណ៍មួយដើម្បីរឹតចំណងសាមគ្គីភាពរវាងប្រជាជាតិខ្មែរ និងប្រជាជាតិនៅលើសកលលោក ។ ទី៤-ផ្ដល់ឱកាសឱ្យយុវជនប្រជាពលរដ្ឋភ្ញៀវទេសចរស្វែងយល់ពីភាពរុងរឿង ភាពល្បីល្បាញភាពសម្បូរបែបនៃវប្បធម៌អរិយធម៌ ទំនៀមទម្លាប់ប្រពៃណីសាសនា និងបន្តថែរក្សាកេរមរតកទាំងនេះ ឱ្យបានគង់វង្សព្រមទាំង ពង្រីកកិត្យានុភាពលើឆាកអន្តរជាតិ។ អង្គរសង្ក្រាន្តជាឱកាសមួយ ដើម្បីឱ្យកម្ពុជាបង្ហាញខ្លួនថាជាព្រះរាជាណាចក្រ នៃ វប្បធម៌។ ទី៥-ប្រមូលគំនិតរួបរួមកម្លាំងសាមគ្គីភាព ជាគ្រួសារខ្មែរ តែមួយក្នុងមោទនភាពខ្មែរជាធ្លុងមួយ និងបណ្ដុះស្មារតីអភិរក្ស អភិវឌ្ឍវប្បធម៌ បាវចនាជាតិព្រលឹង និងអត្តសញ្ញាណជាតិខ្មែរ ក្នុងបរិបទនៃសមាហរណកម្មអាស៊ាន ដែលរួមគិត រួមធ្វើ រួមទទួលខុសត្រូវក្នុងសម័យកាល សកលភាវូបនីយកម្មជំនាន់ទំនើប ។ ទី៦-ព្រឹត្តិការណ៍នេះ បង្ហាញនូវវប្បធម៌ និងសិល្បៈនៃការចែករំលែកការរាប់អានគ្នាជួយយកអាសាគ្នា និងភាព ទន់ភ្លន់របស់ប្រជាពលរដ្ឋខ្មែរ ។ ទី៧-ផ្ដល់ឱកាសឱ្យ ពាណិជ្ជករ អាជីវករចូលរួមក្នុងការតាំងបង្ហាញនូវម្ហូបអាហារ និងផលិតផលរបស់ខ្លួនជាពិសេសផលិតផលសិប្បកម្ម និងឧបករណ៍បរិក្ខារ ដែលបង្ហាញពីអត្តសញ្ញាណវប្បធម៌ក្នុងតំបន់ ។ ទី៨-បណ្ដុះគំនិតច្នៃ ប្រឌិតរបស់យុវជន និងបង្កើននូវភាពនៃការដឹកនាំ ប្រកបដោយការទទួលខុសត្រូវតាមរយៈការត្រៀមរៀបចំ និងការអនុវត្តកម្មវិធីនីមួយៗ និងទី៩-ជំរុញ ទេសចរណ៍ដែលជាប្រភពចំណូលរបស់ប្រជាជនយើង ។

សម្ដេតេជោ**ហ៊ុនសែន**មានប្រសាសន៍ថាឆ្នាំនេះជាឆ្នាំដ៏ពិសេស ដែលខ្ញុំសុខចិត្តលុប ចោលកម្មវិធីទស្សនកិច្ចទៅសាធារណរដ្ឋកូរ៉េ ដើម្បីយកឱកាសនេះរួមរស់ជាមួយប្រជាពលរដ្ឋកម្ពុជារបស់យើង នៅក្នុងពិធីបុណ្យចូលឆ្នាំជាពិសេស គឺមកចូលរួមក្នុងព្រឹត្តិការណ៍អង្គរសង្ក្រាន្តនៅក្នុងឆ្នាំទី ៣ដែលជាឆ្នាំពិសេសសម្រាប់យើងទាំងខាងនយោបាយ សេដ្ឋកិច្ច វប្បធម៌ និងសង្គម ។

សម្ដេចបន្តថាវាជារឿងមួយគួរឱ្យមានមោទនភាពសម្រាប់យើងទាំងអស់គ្នា ដែលអង្គរសង្ក្រាន្តឆ្នាំ ២០១៣-២០១៤ បានប្រព្រឹត្តទៅយ៉ាងល្អដែលជាការផ្ដួចផ្ដើម និងអនុវត្តដោយផ្ទាល់ពីសំណាក់សហភាពសហព័ន្ធយុវជនកម្ពុជាដោយមានការគាំទ្រពីគ្រប់ផ្នែកដែលចង់ចូលរួម នៅក្នុងសកម្មភាពគាំទ្រដល់វិស័យវប្បធម៌នៅក្នុងតំបន់នេះ ហើយគឺជាជំនួបរវាងវប្បធម៌អរូបិយដែលត្រូវជួបជាមួយវប្បធម៌រូបិយ ។ ខ្ញុំសូមយកឱកាសនេះដើម្បីសង្កត់ធ្ងន់ ទៅលើបញ្ហាមួយចំនួនដែលក្នុងនោះកាលពីថ្ងៃទី ១៣ ខែមេសា ឆ្នាំ ២០១៥ យើងបានទៅក្នុង Guinness World Record ដោយបានបំបែកឯកទគ្គកម្មពិភពលោករួចស្រេចទៅហើយចំពោះនំអន្សមយក្សរបស់យើង។ នំអន្សមយក្សនេះ



*ឯកឧត្តម **ហ៊ុន ម៉ានី** លើកបង្ហាញលិខិតបញ្ជាក់ពីគណៈកម្មការGuiness World Record ដែលជាការបញ្ជាក់អំពីកម្ពុជាទទួលការបំបែកឯកទគ្គកម្មពិភពលោកនៃការរាំចង្វាក់ ម៉ាឌីហ្សុន*



*ឯកឧត្តម **ឃឹម ប៊ុនសុខ** ទទួលលិខិតបញ្ជាក់ពីគណៈកម្មការGuiness World Record ដែលជាការបញ្ជាក់អំពីកម្ពុជាទទួលការបំបែកឯកទត្តកម្ម ពិភពលោកនៃការផលិតនំអន្សមយក្ស*

មានទម្ងន់ដល់ទៅប្រមាណជាង ៤ តោនក្រោយពីបានចម្អិនអស់រយៈពេល៤៥ម៉ោង ។ នំអន្សមនេះត្រូវបានវេចខ្ចប់ដោយស្លឹកចេកទម្ងន់ ៣៣៣ គីឡូក្រាម និងខ្សែចេកចំនួន៣៧៥គីឡូក្រាម ដោយមានគ្រឿងផ្សំអង្ករដំណើប ១០០០ គីឡូក្រាម ខ្ទិះដូង ៣៩៩ គីឡូក្រាម អំបិល ១៥ គីឡូក្រាម សណ្តែកបាយ ៤៩៩ គីឡូក្រាម សាច់ជ្រូកបីជាន់ ៥០៧ គីឡូក្រាម ស្ករ ៤ គីឡូក្រាម ម្រេចកំពត៣គីឡូក្រាម ខ្ទឹមចិញ្ច្រាំ១៦គីឡូក្រាម ។ នំអន្សមនេះ ត្រូវបានចម្អិនតាមលក្ខណៈបច្ចេកទេសត្រឹមត្រូវ និងមានរសជាតិទាក់ទាញ ជាពិសេសនំអន្សមនេះត្រូវបានចម្អិនឡើងដោយក្រុមមេចុងភៅខ្មែរ និងកូនកាំបិតចំនួន ១០០ នាក់ ។

កម្មវិធីអង្គរសង្ក្រាន្តមានកម្មវិធីជាច្រើន ដូចជាការដាក់តាំងម្ហូកស្លឹកត្នោត អង្រុត កន្ទ្រងប្រហុក ក្រឡាអុកមានទំហំធំ ការចូលរួមរបស់យុវជនស្ម័គ្រចិត្តជាង ២.៩០០ នាក់ មកពីគ្រប់ទិសទី ។ ព្រ័ត្រមានប្រវែង ២៥០ ម៉ែត្រ ដែលមានអ្នកចូលរួមទាញចំនួន ១៥០០ នាក់ ការរាំចង្វាក់ម៉ាឌីហ្សុនជាក្រុមធំដែលមានអ្នកចូលរាំចំនួន ២០១៥ នាក់ និងមានច្រើនទម្រង់សិល្បៈដូចជាល្ខោនបាសាក់ទាំងល្បែងប្រជាប្រិយរហូតដល់ ២៤ ល្បែងនិងរបាំប្រពៃណីចំនួន ២១ របាំ ។

នៅក្នុងព្រឹត្តិការណ៍អង្គរសង្ក្រាន្តនេះដែរ ក្រុមយុវជនកម្ពុជាចំនួន ២.០១៥ នាក់ បានបំបែកឯកទត្តកម្មពិភពលោកក្នុងការរាំដ៏ល្អបំផុតតែម្តងគត់ ក្នុងលក្ខ-ខណ្ឌបីដងនៃការរាំចង្វាក់ម៉ាឌីហ្សុននេះ ដែលឯកទត្ត-កម្មមុននេះ បានទៅលើប្រទេស អូស្ត្រាលី ដែលមានអ្នករាំ ១១៥៥ នាក់ កាលពីឆ្នាំ២០១៤។ បន្ទាប់ពីការវាយតម្លៃ និងវិនិច្ឆ័យអស់រយៈពេលប្រមាណ២ម៉ោង ពីគណៈកម្មការ Guinness World Record នៅវេលាម៉ោង ១ និង ៥៣ នាទីរសៀលថ្ងៃទី ១៥ ខែមេសា ឆ្នាំ ២០១៥ លោកស្រី Seyda Subasi-Gemici ចៅក្រមនៃកំណត់ត្រាពិភពលោកបានប្រកាសថា ការរាំចង្វាក់ម៉ាឌីហ្សុននាទីលានជល់ដំរីរបស់យុវជនកម្ពុជា បានជាប់កំណត់ត្រាពិភពលោកហើយ។ ការររាំចង្វាក់ម៉ាឌីហ្សុនគឺជាកម្មវិធីមួយដែលសហភាព សហព័ន្ធយុវជនកម្ពុជា ខេត្តសៀមរាប (យុទ្ធនាការសៀមរាបផ្ទះខ្ញុំ)បានរៀបចំឡើង ហើយក៏ជាកម្មវិធីមួយ ក្នុងចំណោមកម្មវិធីជាច្រើនទៀត នៃព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំ ២០១៥ ដែលសហភាពសហព័ន្ធយុវជនកម្ពុជាបានរៀបចំឡើង ដោយមានកិច្ចសហការពីសំណាក់ស្ថាប័នរដ្ឋ និងឯកជននានាផងដែរ ។

ឯកឧត្តម **ហ៊ុន ម៉ានី** ប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា បានសម្តែងនូវអារម្មណ៍រំភើបរីករាយជាខ្លាំង ចំពោះភាពជោគជ័យរួមគ្នារបស់ប្រជាជនខ្មែរដែល អាចបំបែកនូវកំណត់ត្រានំអន្សមយក្សពិភព-លោក និងការរាំចង្វាក់ម៉ាឌីហ្សុនដែលបានបំបែកឯក-ទត្តកម្មប្រទេសអូស្ត្រាលីហើយជាប់នៅក្នុងកំណត់ត្រាពិភពលោក។លោកបានសរសើរដល់ស្មារតីរបស់យុវ-ជនដែលបានចូលរួមបង្កើតនៅព្រឹត្តិការណ៍មហាជួបជុំគ្រួសារខ្មែរនេះ ។

ព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំ ២០១៥ បានបញ្ចប់ទៅហើយ ជាមួយនឹងជោគជ័យយ៉ាងធំធេងលើសពីការរំពឹងទុក ក្នុងរយៈពេល៣ថ្ងៃនៃព្រឹត្តិការណ៍អង្គរ-



*ភ្ញៀវទេសចរជាតិ អន្តរជាតិយ៉ាងច្រើនកុះករទស្សនាប្រាសាទអង្គរវត្ត ក្នុងឱកាសនៃការប្រារព្ធព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំ២០១៥ នៅក្រុងសៀមរាបអង្គរ*

សង្ក្រាន្តឆ្នាំ ២០១៥ (នៃឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ) នៅខេត្តសៀមរាប-អង្គរ ទទួលបានភ្ញៀវទេសចរជាតិប្រមាណ ១ លាននាក់ និងទេសចរអន្តរជាតិប្រមាណ ២៧០០០ នាក់ បាននាំមកនូវប្រាក់ចំណូលសម្រាប់ខេត្តសៀមរាបប្រមាណជិត ៧០ លានដុល្លារអាមេរិក ។ នេះបើយោងតាមការអះអាងរបស់មន្ត្រីក្រសួងទេសចរណ៍ ។

ឯកឧត្តម **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ បានមានប្រសាសន៍ឲ្យដឹងនៅថ្ងៃទី ១៧ មេសា នេះថា ចំនួនភ្ញៀវទេសចរ ចូលទៅកាន់ខេត្តសៀមរាបនៅក្នុងឆ្នាំសង្ក្រាន្ត ២០១៥ នេះ កើនឡើងលើសឆ្នាំ ២០១៤ ចំនួន ២៣៣ %។ឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍ បានធ្វើការគិតជាតួលេខមធ្យមភាគ នៃការចំណាយរបស់ភ្ញៀវទេសចរណ៍ ដែលបានទៅកំសាន្តនៅថ្ងៃសង្ក្រាន្តរយៈពេល ៣ ថ្ងៃនេះគឺភ្ញៀវទេសចរជាតិម្នាក់អាចចំណាយអស់ ៥០ ដុល្លារអាមេរិក និងភ្ញៀវទេសចរបរទេសអាចចំណាយអស់ ៧០០ ដុល្លារអាមេរិក ។ សរុបចំណូលដែលបានមកពីសង្ក្រាន្តឆ្នាំ ២០១៥ សម្រាប់ខេត្តសៀមរាបមានប្រមាណ ៦៩ លានដុល្លារអាមេរិក ដែលក្នុងនោះចំណូលបានពីទេសចរជាតិប្រមាណ ៥០ លានដុល្លារអាមេរិក និងពីទេសចរអន្តរជាតិប្រមាណ ១៨៩០០០០០ ដុល្លារ ។

យោងតាមរបាយការណ៍ ពីក្រសួងទេសចរណ៍ កាលពីព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំ ២០១៣ ខេត្តសៀមរាបទទួលបានភ្ញៀវទេសចរជាតិ និងអន្តរជាតិជាង ១៧ ម៉ឺននាក់ ។ នៅឆ្នាំ ២០១៤ ខេត្តសៀមរាបទទួលហានភ្ញៀវទសេចរសរុបចំនួនជាង៣៨ម៉ឺននាក់ ដែលក្នុងនោះជាង ២ ម៉ឺននាក់ ជាភ្ញៀវអន្តរជាតិ ដោយទទួលបានចំណូលប្រមាណ ៣០ លានដុល្លារ។ចំពោះព្រឹត្តិការណ៍អង្គរសង្ក្រាន្តក្នុងឆ្នាំ ២០១៥ នេះ ក្រសួងរំពឹងថានឹងទាក់ទាញភ្ញៀវជាតិ និងអន្តរជាតិឲ្យចូលរួមដល់៥០ម៉ឺននាក់ ប៉ុន្តែលទ្ធផលជាក់ស្តែងគឺបានទទួលលើសពីការរំពឹងទុក ៕









*ទិដ្ឋភាពទូទៅនៃការសម្តែងសិល្បៈគ្រប់ទម្រង់ ក្នុងឱកាសនៃការប្រារព្ធព្រឹត្តិការណ៍អង្គរ សង្ក្រាន្តឆ្នាំ២០១៥ នៅក្រុងសៀមរាបអង្គរ*

# គោលនយោបាយ Abenomic កំពុងធ្វើឲ្យសេដ្ឋកិច្ចជប៉ុនងើបឡើងវិញ



*ទិដ្ឋភាពដ៏ទំនើបនៃទីក្រុងតូក្យូ ដែលឆ្លុះបញ្ចាំងឱ្យឃើញពីកំណើនសេដ្ឋកិច្ចខ្ពស់*

យោងតាមទិន្នន័យរបស់រាជរដ្ឋាភិបាលជប៉ុន ឲ្យដឹងថាសេដ្ឋកិច្ចប្រទេសជប៉ុនបានងើបចេញផុតពីភាពមិនទៅមុខតាំងពីចុង ឆ្នាំ ២០១៤ មកម្ល៉េះ តាមរយៈកំណើនដែលបានកើតមានជាលើកដំបូង ប៉ុន្តែមានកម្រិតទាបជាង ការព្យាករណ៍របស់សេដ្ឋកិច្ចវិទូនានានៅឡើយទេ ។

នៅក្នុងរបាយការណ៍ដំបូង គណៈរដ្ឋមន្ត្រីជប៉ុន បានឲ្យដឹងថាផលិតផលក្នុងស្រុកសរុបGDPបានកើនឡើង ២,២ % នៅត្រីមាសទីបីរហូតដល់ខែធ្នូ ឆ្នាំ ២០១៤ ។ ពោល គឺសេដ្ឋកិច្ចជប៉ុនបានរួញតូចនៅក្នុងត្រីមាសទីមួយ និងទីពីរនៃឆ្នាំ២០១៤ដែលការធ្លាក់ចុះនេះត្រូវបានគេបន្ទោសទៅលើអត្រាពន្ធក្នុងស្រុកខ្ពស់ពេក ។

ទោះជាយ៉ាងណាក៏ដោយ ការវិលត្រឡប់មកកាន់កំណើនវិញសម្រាប់សេដ្ឋកិច្ចប្រទេសជប៉ុន ក៏នៅតែទាបជាងការព្យាករណ៍របស់សេដ្ឋកិច្ចវិទូនានា ហើយអាចមិនសម្រេចបាន ចំពោះការលប់បំបាត់ចោលការព្រួយបារម្ភដែលថា សេដ្ឋកិច្ចជប៉ុន កំពុងស្ថិតនៅក្នុងស្ថានភាពមានការឈឺចាប់នោះ ។ យុទ្ធនាការជំរុញសេដ្ឋកិច្ចឲ្យទៅមុខមានរយៈពេលពីរឆ្នាំ ផ្តួចផ្តើមឡើងដោយលោកនាយករដ្ឋមន្ត្រី **ស៊ីនហ្សូ អាបេ** ដែលមានឈ្មោះថាគោលនយោបាយ Abenomic កំពុងតែទទួលបានផ្លែផ្កាគឺកំណើន២,២%។ប៉ុន្តែពួកសេដ្ឋកិច្ចបានព្យាករណ៍ថា កំណើននឹងទទួលបាន ៣,៧% ។

ចាប់តាំងពីវិលត្រឡប់មកកាន់អំណាច វិញនាចុងឆ្នាំ ២០១២ មក លោក **ស៊ីនហ្សូអាបេ**បានប្រឹងប្រែងគ្រប់បែបយ៉ាង ដើម្បីឲ្យសេដ្ឋកិច្ចប្រទេសជប៉ុនវិលមកកាន់កំណើនវិញ ដោយលោកបង្កើតគោលនយោ-បាយកំណើនមួយដែលមានឈ្មោះថា Abenomic ។ មានការងារជាច្រើនដើម្បីកំណើនកំពុងត្រូវបានអនុវត្តដោយធនាគារកណ្តាលរបស់ជប៉ុន ដែលកំពុងបង្កើនសាច់ប្រាក់ តាមរយៈការទិញប័ណ្ណធានារបស់រដ្ឋាភិ-បាល និងការទិញទ្រព្យសម្បត្តិផ្សេងទៀត ។

វិធានការរបស់ធនាគារគឺរក្សាឲ្យបាននូវតម្លៃប្រាក់កម្ចីឲ្យនៅកម្រិតទាប និងឲ្យមានការចំណាយច្រើន។ ធនាគារក៏កំពុងតែរក្សាឲ្យបានកម្រិតទាប នូវអត្រាប្តូរប្រាក់យេន ដែលនឹងជួយដល់ក្រុមហ៊ុនផលិតកម្មធំៗ ដូចជាក្រុមហ៊ុន Toyota និងក្រុមហ៊ុន Hitachi ដែលជាក្រុមហ៊ុនលក់ផលិតផលរបស់ខ្លួនមានចំនួនច្រើននៅក្នុងទីផ្សារក្រៅប្រទេស ។ ទីផ្សារភាគហ៊ុនក៏មានការកើនឡើង ឯប្រាក់ចំណេញសារជីវកម្មក៏មានកម្រិតខ្ពស់ដែរ ។

លោក Akira Amari រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចជប៉ុនថ្លែងថាជំនឿរបស់អ្នកប្រើប្រាស់មានភាពប្រសើរឡើង ហើយកំពុងឆ្ពោះទៅមុខ។ ខ្ញុំគិតថា យើងអាចមានក្តីសង្ឃឹមចំពោះសេដ្ឋកិច្ចរបស់ប្រទេស ។ ភាគហ៊ុននៅក្នុងក្រុមហ៊ុន The nikkei ជាមធ្យម កើនឡើង ០,៦៦%នៅក្នុងការធ្វើពាណិជ្ជកម្មបន្ទាប់ពីមានសេចក្តីរាយការណ៍អំពីកំណើនសេដ្ឋកិច្ច។ ប្រាក់យេនបានធ្លាក់ចុះសន្សឹមៗ បើប្រៀបជាមួយប្រាក់ដុល្លារ។

យោងតាមរបាយការណ៍ឲ្យដឹងថា សេដ្ឋកិច្ចប្រទេសជប៉ុនឆ្នាំ ២០១៤ មិនមានកំណើនទាល់តែសោះ ដោយពីរត្រីមាសដំបូងស្ទើរតែគ្មានការចំណាយជាដុំកំភួន។កំណើនសេដ្ឋកិច្ចក្នុងរយៈពេលពីរឆ្នាំចាប់តាំងពីលោក **ស៊ីនហ្សូ អាបេ** ចាប់ផ្តើមយុទ្ធនាការ Abenomic របស់លោកគឺមានកំណើនយឺតៗ ១,៦% គឺទាបជាងឆ្នាំ ២០១២ ដែលមាន១,៨% ជាឆ្នាំមុនពេលលោកចូលកាន់តំណែងនាយករដ្ឋមន្ត្រី ។ ប៉ុន្តែអ្នកសេដ្ឋកិច្ចបាននិយាយថាឆ្នាំ២០១៥នេះអាចជាឆ្នាំអនុគ្រោះដល់គោលនយោបាយ Abenomic របស់លោក**ស៊ីនហ្សូអាបេ**ពីព្រោះពីរឆ្នាំដំបូងរបស់លោកសេដ្ឋកិច្ចមិនងើបឡើងវិញ ដោយសារតែការដំឡើងពន្ធក្នុងស្រុក ។

ពេលប្រាក់យេនចុះខ្សោយ បានចាប់ផ្តើមឲ្យមានសន្ទុះដល់ផលិតកម្មក្នុងស្រុកតាមរយៈការបង្កើនតម្រូវការនាំចេញពីប្រទេសជប៉ុន។ វិស័យទេសចរណ៍ក៏ដូចគ្នាដែរកំពុងមានសន្ទុះ ដែលពីមុននេះអ្វីៗសុទ្ធតែថ្លៃនៅតាមទីក្រុងនានារបស់ជប៉ុន បង្កផលប៉ះពាល់ដល់អ្នកទេសចរ ។

លោក Naohiko Baba ប្រធានអ្នកសេដ្ឋកិច្ចជប៉ុននៅ Goldman Sachs បាននិយាយថា យើងកំពុងឆ្ពោះទៅមុខ សេដ្ឋកិច្ចរបស់ជប៉ុនកំពុងរកឃើញផ្លូវងើបឡើងវិញសមល្មម ។ តម្លៃប្រេងចុះថោកកំពុងបង្កើតភាពអនុគ្រោះដល់ប្រទេសជប៉ុន ។ តម្លៃប្រេងបានរអិលធ្លាក់ចុះ ចាប់តាំងពីពាក់កណ្តាលឆ្នាំ ២០១៤ មកកំពុងតែធ្វើឲ្យតម្លៃនានាធ្លាក់ចុះដែរ ដូចជាផ្ទះសម្បែងនិងធុរកិច្ចនៅក្នុងវិស័យសេដ្ឋកិច្ច ដែលភាគច្រើនពឹងផ្អែកទៅលើថាមពលនាំចូល ។ ប៉ុន្តែវាក៏កំពុងតែគំរាមកំហែងចំពោះគោលដៅមួយផ្សេងទៀត នៅក្នុងគោលនយោបាយ Abenomic ដែលលោកអាបេចង់រក្សាឲ្យបានតម្លៃប្រើប្រាស់មានការកើនឡើងសមល្មម ។

ការចំណាយរបស់អ្នកប្រើប្រាស់និងការវិនិយោគក្នុងវិស័យធុរកិច្ចមានការកើនឡើងចាប់តាំងពីត្រីមាសទីបីរហូតដល់ខែធ្នូឆ្នាំ២០១៤។ រីឯការនាំចេញក៏មានការកើនឡើងក្នុងល្បឿនមួយលឿនចាប់តាំងពីដើមឆ្នាំ ២០១៤ រហូតមកដល់បច្ចុប្បន្ននេះ ។ ប៉ុន្តែការវិនិ-យោគលើវិស័យសំណង់អចលនទ្រព្យ មានការធ្លាក់ចុះ បន្ទាប់ពីមានការបង្កើនពន្ធក្នុងស្រុកចាប់តាំងពីខែមេសា ឆ្នាំ ២០១៤ មក ។

ទោះជាយ៉ាងណាក៏ដោយ ក៏សេដ្ឋវិទូជាច្រើនបាននិយាយថា កំណើននឹងបន្តមានទៅតាមលំនាំវិជ្ជមាន ពោលគឺប្រហែល ១,៥ % ឬ ២ % ក្នុងឆ្នាំ ២០១៥ នេះ និងឆ្នាំបន្តទៀត ។ ប៉ុន្តែបញ្ហាសំខាន់ដែលអ្នកសេដ្ឋ-កិច្ចកំពុងតាមដាននៅត្រង់ថា តើការងើបឡើងវិញនៃសេដ្ឋកិច្ចរបស់ប្រទេសជប៉ុន នឹងបន្តមានរយៈពេលប៉ុន្មានឆ្នាំទៅមុខទៀត ហើយរយៈពេលដែលនៅសល់ក្នុងតំណែងនាយករដ្ឋមន្ត្រី តើលោក **ស៊ីន ហ្សូ អាបេ** អាចសម្រេចបានជោគជ័យឬទេ នូវគោលនយោបាយ Abenomicរបស់លោកនៅក្នុងប្រទេសដែលសេដ្ឋកិច្ចពឹងផ្អែកលើការនាំចេញនេះ ៕

# ស្វែងយល់អំពីគុណសម្បត្តិ និងគុណវិបត្តិ របស់បន្លែត្រកួន និងស្ពៃខ្មៅ



បន្លែត្រកួនដែលផ្ដល់ជីវជាតិខ្ពស់សម្រាប់សុខភាពមនុស្ស

ត្រកួនគឺជាប្រភេទបន្លែបៃតង ដែលមនុស្សចូលចិត្តបរិភោគទូទាំងពិភពលោក ។ សារជាតិនៅដើមត្រកួន បានផ្ដល់គុណប្រយោជន៍ដ៏ប្រសើរសម្រាប់សុខភាពរបស់មនុស្ស ប៉ុន្តែទន្ទឹមគ្នានឹងផលប្រយោជន៍ដ៏សម្បូរបែបនេះ ត្រកួនក៏បានផ្ដល់ផលអាក្រក់មួយចំនួន ដល់សុខភាពរបស់មនុស្សផងដែរ ដែលមនុស្សគ្រប់គ្នាគួរស្វែងយល់ឲ្យបានស៊ីជម្រៅ ។

***១.គុណសម្បត្តិរបស់ត្រកួន៖*** ត្រកួនជាបន្លែបៃតងដែលសម្បូរទៅដោយវីតាមីននិងសារជាតិរ៉ែ ដូចជាជាតិកាកសរសៃប្រូតេអ៊ីន កាល់ស្យូមវីតាមីន A វីតាមីន C និងជាតិដែកជាដើម។ សារជាតិដែកនៅក្នុងដើមត្រកួន គឺជាធនធានមួយដ៏ល្អសម្រាប់សារពាង្គកាយមនុស្ស ប្រឆាំងទៅនឹងភាពស្លេកស្លាំង ជាពិសេសចំពោះអ្នកជំងឺមានបញ្ហាបាត់បង់គ្រាប់ឈាមក្រហម និងស្ត្រីមានផ្ទៃពោះជាដើម ។ ជាមួយគ្នានេះដែរ ជាតិកាកសរសៃ និងវីតាមីនមួយចំនួនរបស់វាបានជួយសម្រួលដល់ចលនារបស់ប្រដាប់រំលាយអាហារ បញ្ចៀសពីបញ្ហាទល់លាមក និងជួយបញ្ចៀសពីហានិភ័យនៃជំងឺមហារីកពោះវៀនធំផងដែរ ។ សារជាតិអាមីណូអាស៊ីត ដែលមាននៅក្នុងត្រកួន ដែលបន្លែមួយចំនួនទៀតមិនមានដូចជា Lysine, Trytophan, Valine និង Leucine ជាដើម គឺសុទ្ធតែជាសារជាតិចាំបាច់សម្រាប់សារពាង្គកាយ ព្រមទាំងជួយបញ្ចៀស និងកាត់បន្ថយហានិភ័យនៃជំងឺទឹកនោមផ្អែមទៀតផង ។

***២. គុណវិបត្តិរបស់ត្រកួន ៖*** មនុស្សអាចនឹងមានជំងឺមួយចំនួនដូចជា រាករូសអាសន្នរោគ និងមានសត្វល្អិតជាដើម ប្រសិនបើទទួលទានត្រកួនឆៅ ឬត្រកួនដែលសម្អាតមិនបានស្អាតល្អ ព្រោះពពួកប៉ារ៉ាសិតជាច្រើន អាចនឹងតោងជាប់ដើម និងស្លឹករបស់ត្រកួន។ អង្គការសុខភាពជាច្រើន បានណែនាំឲ្យមនុស្សយកចិត្តទុកដាក់ខ្ពស់ទៅលើការលាងសម្អាតចំណីអាហារ មុនពេលចម្អិនជាពិសេសបន្លែស្រស់ត្រូវសម្អាតនឹងទឹកស្អាតឲ្យបានច្រើនដង ឬត្រាំជាមួយទឹកអំបិលឲ្យបានពី ១០ ទៅ ១៥ នាទីមុននឹងចម្អិន ដើម្បីថែរក្សាសុខភាព និងបញ្ចៀសពីហានិភ័យនៃជំងឺផ្សេងៗ។

## ស្ពៃខ្មៅ ផ្ដល់អត្ថប្រយោជន៍អ្វីខ្លះចំពោះសុខភាព

ស្ពៃខ្មៅជាបន្លែប្រភេទស្លឹកមួយប្រភេទដែលសម្បូរអាហារូបត្ថម្ភដ៏ច្រើន ដែលសារជាតិទាំងនោះសុទ្ធតែផ្ដល់គុណប្រយោជន៍ សម្រាប់សារពាង្គកាយក្នុងការការពារ និងទប់ទល់ទៅនឹងការបង្ករោគនៃជំងឺផ្សេងៗជាច្រើន មកលើសារពាង្គកាយរបស់មនុស្ស។ ស្ពៃខ្មៅក៏ផ្ទុកនូវពពួកវីតាមីនមួយចំនួនក្នុងកម្រិតច្រើនលើសលុប ដូចជាវីតាមីន A វីតាមីន K វីតាមីន C និងសារជាតិរ៉ែមួយចំនួនទៀតដូចជា ជាតិស័ង្កសីសេលេញ៉ូម កាល់ស្យូម ម៉ាញ៉េស្យូម និងជាតិដែកជាដើម។ សារជាតិដ៏សំខាន់ និងមានគុណប្រយោជន៍ខ្ពស់សម្រាប់សុខភាពទាំងអស់ដែលមានផ្ទុកនៅក្នុងស្ពៃខ្មៅនេះ មានផលប្រយោជន៍ខ្ពស់ទៅលើជំងឺមួយចំនួនដូចជា ជំងឺរលាកសន្លាក់ ជំងឺពុកឆ្អឹង ជំងឺស្លេកស្លាំង ដោយបាត់បង់គ្រាប់ឈាមក្រហមខ្ពស់ ជំងឺហឺត និងជំងឺស្ទះសរសៃឈាមបេះដូង ហើយ វាក៏បានផ្ដល់គុណប្រយោជន៍ដល់ប្រព័ន្ធខួរក្បាលរបស់មនុស្សប្រឆាំងទៅនឹងជំងឺបាត់បង់ការចងចាំ និងជំរុញឲ្យខួរក្បាលមនុស្សកាន់តែមានភាពឆ្លាតវៃទៀតផង ។លើសពីនេះទៅទៀត ស្ពៃខ្មៅសម្បូរទៅដោយសារធាតុម្យ៉ាងដែលមានឈ្មោះថា Dithiolthiones ដែលជាសារធាតុដ៏មានប្រយោជន៍បំផុត ក្នុងការប្រឆាំងនឹងការលូតលាស់ របស់កោសិកាជំងឺមហារីកដូចជាមហារីកសុដន មហារីកពោះវៀនធំ មហារីកក្រពេញប្រូស្តាត មហារីកសួត មហារីកផ្លោកនោម និងមហារីកដៃស្បូនជាដើម។ជាមួយគ្នានេះដែរ ស្ពៃខ្មៅក៏ជាប្រភេទឱសថធម្មជាតិមួយដែលមាននាទីប្រឆាំងនឹងការរលាកនៅក្នុងជាលិកា ឬកោសិកាផ្នែកខាងក្នុងសារពាង្គកាយ និងជួយជំរុញឲ្យមានកម្លាំងផងដែរ។ ស្ពៃខ្មៅក៏សម្បូរសារជាតិអង់ទីអុកស៊ីដង់ដែលជួយសម្អាតសារជាតិកខ្វក់ ឬសារជាតិពុលឲ្យចេញពីរាងកាយបានយ៉ាងប្រសើរ និងជួយថែរក្សាសុខភាពរបស់ថ្លើម ហើយស្ពៃខ្មៅក៏ជួយបំប៉នដល់សុខភាពរបស់ឆ្អឹង និងសាច់ដុំឲ្យមានភាពមាំមួន។ ស្ពៃខ្មៅជាប្រភេទបន្លែមួយប្រភេទ ដែលមនុស្សជាច្រើននិយមទទួលទាន ជាមួយមុខម្ហូបមួយចំនួន ដូចជាស៊ុប ស្ងោរ និងប្រភេទអាហារជាច្រើនផ្សេងទៀត ៕



បន្លែស្ពៃខ្មៅដែលផ្ដល់ជីវជាតិខ្ពស់សម្រាប់សុខភាពមនុស្ស

# សង្កាត់ព្រៃតាហ៊ូ និងការអភិវឌ្ឍតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល



ផ្លូវលំទើបកសាងថ្មីក្នុងសង្កាត់ព្រៃតាហ៊ូ ស្ថិតក្នុងក្រុងស្ទឹងសែន ទីរួមខេត្តកំពង់ធំ



លោក ផៃ ឈុនអេង ចៅសង្កាត់

នៅទូទាំងព្រះរាជាណាចក្រកម្ពុជា សមិទ្ធផលធំៗជាច្រើនបានបដិសន្ធិឡើង តាមរយៈកិច្ចខិតខំប្រឹងប្រែងអស់ទាំងកម្លាំងកាយ កម្លាំងចិត្តរបស់ប្រជាជនកម្ពុជាក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជា។ជីវភាពប្រជាជនកាន់តែត្រូវបានលើកកម្ពស់ ហេដ្ឋារចនាសម្ព័ន្ធរីកដុះដាលគ្រប់ច្រកល្ហកតភ្ជាប់ពីតំបន់មួយទៅតំបន់មួយ។គ្រប់ភូមិឃុំសង្កាត់ ខេត្ត រាជធានី មានការរីកចម្រើនលើគ្រប់វិស័យទាំងអស់ ដែលធ្វើឲ្យប្រជាជនយើងកាន់តែមានមោទនភាព និងមានក្តីសង្ឃឹមកាន់តែមុតមាំចំពោះអនាគតដ៏រុងរឿងរបស់ខ្លួន។

ដោយឡែក សង្កាត់ព្រៃតាហ៊ូ ស្ថិតក្នុងក្រុងស្ទឹងសែន ទីរួមខេត្តកំពង់ធំវិញក៏មានការអភិវឌ្ឍលើគ្រប់វិស័យគួរជាទីចាប់អារម្មណ៍ដែរ។ សមិទ្ធផលធំៗទាំងនោះមានដូចជា ស្ពាន ផ្លូវ សាលារៀន វត្តអារាម និងលំនៅស្ថានរបស់ប្រជាជន។ ជាមួយគ្នានេះប្រព័ន្ធធារាសាស្ត្របានកើតឡើងខ្វាត់ខ្វែងនៅក្នុងមូលដ្ឋាននេះ។ សង្កាត់ព្រៃតាហ៊ូមានផ្ទៃដីសរុបទំហំ ៩៩៨១ ហ.ត មានប្រជាជន ១៤៨៥ គ្រួសារ ដែលមានចំនួន មនុស្ស ៥៩៧៦ នាក់ ក្នុងនោះស្រីចំនួន ២៩៧៩ នាក់ ។ សរុបមានភូមិចំនួន៣ គឺភូមិព្រៃតាហ៊ូ ភូមិក្តី និងភូមិស្លាកែត។ ប្រជាជន ៨០% មានមុខរបរកសិកម្ម។

លោក *ផៃ ឈុនអេង* ចៅសង្កាត់ និងជាប្រធានគណៈកម្មាធិការគណបក្សប្រជាជនកម្ពុជាសង្កាត់ព្រៃតាហ៊ូបានឲ្យដឹងថា កាលពីដើមប្រជាជនធ្វើស្រែ ក្នុងមួយហិកតាបានត្រឹមតែ ១,៥ តោន ទៅ ២ តោនតែប៉ុណ្ណោះ។ ប៉ុន្តែតាំងពីឆ្នាំ ២០១៣ មកដល់ពេលនេះប្រជាកសិករយើងធ្វើបានផលពី ៥ តោន ទៅ ៦ តោន ក្នុងមួយហិកតា ដែលធ្វើឲ្យជីវភាពរបស់ពួកគាត់មានភាពធូរធារជាងមុន ម៉្យាងក៏ដោយសារពួកគាត់មានមុខរបរផ្សេងៗទៀតគួបផ្សំជាមួយផង។ មូលហេតុដែលធ្វើឲ្យប្រជាកសិករទទួលបានទិន្នផលស្រូវ ទាំងស្រែវស្សា ទាំងស្រែប្រាំង មានកំណើនខ្ពស់ជាងឆ្នាំមុនៗ គឺដោយសារពួកគាត់ជ្រើសរើសពូជ ជីបានត្រឹមត្រូវ ជាពិសេសនោះគឺមានទឹកសម្រាប់ស្រោចស្រពស្រែ ទាំងប្រាំងទាំងវស្សា ដោយសារយើងមានប្រព័ន្ធធារាសាស្ត្រដែលទើបតែកសាងឡើងថ្មីៗនេះ។ កសិករម្នាក់ឈ្មោះ *ឈាវ ឈួន* អាយុ៤៩ឆ្នាំ រស់នៅភូមិក្តីបានឲ្យដឹងថា គាត់មានដីស្រែនៅចំណុចថ្នល់តាម៉េង និងបឹងលៀស។ កន្លងមកគាត់ធ្វើបានផលតិចណាស់ក្នុងមួយហិកតាមិនលើសពី ២ តោនទេ ហើយចំណាយលុយលើពូជលើជីនិងការភ្ជួររាស់ក៏ច្រើនប៉ុន្តែចាប់ពីឆ្នាំ ២០១៣មកទិន្នផលមានការកើនឡើងខ្ពស់ពីព្រោះថាក្រៅពីត្រៀមបានល្អនូវពូជ និងជី គឺយើងមានទឹកគ្រប់គ្រាន់សម្រាប់ស្រោចស្រព ផ្ទុយពីពេលមុនមានពូជល្អហើយតែខ្វះទឹក។ចាប់ពីពេលនេះទៅប្រជាកសិករនៅភូមិក្តី ក៏ដូចជាក្នុងសង្កាត់ព្រៃតាហ៊ូទាំងមូល លែងខ្វល់ខ្វាយពីបញ្ហាទឹកធ្វើស្រែទៀតហើយ។ បច្ចុប្បន្ននេះគ្រួសាររបស់គាត់មានជីវភាពរីកចម្រើនជាងមុន។

សង្កាត់ព្រៃតាហ៊ូមានព្រំប្រទល់ខាងកើតជាប់នឹងសង្កាត់អាចារ្យលាក់ក្រុងស្ទឹងសែន ខាងលិចជាប់នឹងឃុំក្តីដូង ស្រុកកំពង់ស្វាយ ខាងជើងជាប់ឃុំត្រពាំងឬស្សីស្រុកកំពង់ស្វាយនិងខាងត្បូងជាប់សង្កាត់កំពង់ក្របៅ ក្រុងស្ទឹងសែន។ លោក *ផៃ ឈុនអេង* បានមានប្រសាសន៍ថា វិស័យអប់រំនៅសង្កាត់នេះក៏មានការរីកចម្រើនគួរឲ្យកត់សម្គាល់ដែរ។នៅក្នុងសង្កាត់មានសាលារៀន ៣ កន្លែង គឺក្នុងភូមិ ១ មានសាលារៀនមួយដែលបង្កលក្ខណៈងាយស្រួល ដល់អាណាព្យាបាលសិស្សបញ្ជូនកូនទៅសិក្សា។ មានសាលាបឋមសិក្សា និងអនុវិទ្យាល័យនៅភូមិព្រៃតាហ៊ូ សាលាបឋមសិក្សានៅភូមិស្លាកែត និងសាលាបឋមសិក្សានៅភូមិក្តី ដែលនៅក្នុងសាលានោះក៏មានថ្នាក់មត្តេយ្យផងដែរ ។ សិស្សានុសិស្ស បានចូលរៀនគ្រប់គ្នាទាំងប្រុសទាំងស្រី ហើយទទួលបានចំណាត់ថ្នាក់ល្អ បង្គួរ និងមធ្យម។ ឯចំណាត់ថ្នាក់ខ្សោយមានតិចណាស់។ លោកសង្ឃឹមថា អ្នកទាំងនេះនឹងក្លាយទៅជាធនធានមនុស្សដ៏



ដំណាំស្រូវរបស់ប្រជាកសិករសង្កាត់ព្រៃតាហ៊ូ ក្រុងស្ទឹងសែន ទីរួមខេត្តកំពង់ធំ



*ការដ្ឋានស្ថាបនាផ្លូវលំ ក្នុងសង្កាត់ព្រៃតាហ៊ូ ក្រុងស្ទឹងសែន ទីរួមខេត្តកំពង់ធំ*

សំខាន់សម្រាប់អភិវឌ្ឍភូមិ សង្កាត់ នាពេលអនាគត។ គ្រូបង្រៀនសរុបមាន៤៧នាក់ ស្រីមាន១៦នាក់ ចំណែកសិស្សានុសិស្សមាន ៥៧៦ នាក់។ចំណុចពិសេសមួយទៀតគឺ រៀងរាល់ខែ សង្កាត់បានបើកកិច្ចប្រជុំជាមួយលោកគ្រូអ្នកគ្រូ និងអាណាព្យាបាលសិស្សដើម្បីរួមគ្នាដោះស្រាយនូវរាល់បញ្ហាប្រឈមនានា ធ្វើយ៉ាងណាបង្កលក្ខណៈឲ្យសិស្ស ដែលមានអាយុត្រូវចូលរៀនបានចូលរៀនគ្រប់គ្នា។ ចំណែកសេវាសុខភាពក៏មានសកម្មភាពរីកចម្រើនដែរ។ ប្រជាជននៅសង្កាត់នេះពេលមានបញ្ហាសុខភាពតែងតែទៅរកសេវាព្យាបាលនៅមណ្ឌលសុខភាពពីរកន្លែងដែលនៅក្បែរមូលដ្ឋានរបស់គាត់គឺមណ្ឌលសុខភាពអាចារ្យលាក់និងមណ្ឌលសុខភាពកុកងួន។ ជាពិសេសស្ត្រីមានផ្ទៃពោះគឺត្រូវបានជំរុញឲ្យទៅពិនិត្យផ្ទៃពោះ និងទៅសម្រាលកូននៅមណ្ឌលសុខភាព ចៀសវាងដាច់ខាតការពឹងផ្អែកទៅលើអបិយជំនឿដែលមិនត្រឹមត្រូវ ។ លោកចៅសង្កាត់បានបន្តថា សង្កាត់ព្រៃតាហ៊ូបានកសាងផ្លូវថ្មីបន្ថែមស្របតាមលំនៅស្ថានប្រជាពលរដ្ឋ ដែលកាន់តែរីកដុះដាល ហើយក៏បានជួសជុលស្ថាបនាផ្លូវចាស់ ដែលទទួលរងការខូចខាតជារៀងរាល់ឆ្នាំនោះ។ នៅក្នុងឆ្នាំ២០១៤កន្លងមកនេះ សង្កាត់ព្រៃតាហ៊ូបានស្ថាបនាផ្លូវក្រាលក្រួសក្រហមប្រវែង ១០០៤ ម៉ែត្រ លូទោល ២ កន្លែងនៅភូមិស្លាកែត និងកសាងទំនប់ស្ទាក់ទឹក២ខ្សែសរុបប្រវែង១៦៥៤ម៉ែត្រ ទ្វាទឹក៣កន្លែងនិងលូទោល ២កន្លែងពីបឹងទន្លេសាប ដែលជាគម្រោងកាត់បន្ថយភាពក្រីក្រ។ នៅក្នុងគម្រោងនេះដែរ គឺបានជួយផ្ដល់សេវាកម្ចីលុយដល់ប្រជាពលរដ្ឋទៀតផង សម្រាប់ការងារចិញ្ចឹមសត្វ និងធ្វើដំណាំស្រូវ។ លោកចៅសង្កាត់បន្តថា ចំពោះសន្តិសុខសណ្ដាប់ធ្នាប់ គឺសង្កាត់ព្រៃតាហ៊ូមានសុវត្ថិភាពល្អស្ទើរតែទាំងស្រុង ហើយក្នុងនោះអាជ្ញាធរសង្កាត់បានបង្កើនការរៀបចំសណ្ដាប់ធ្នាប់នៅទីសាធារណៈ និងតាមចិញ្ចើមផ្លូវសាធារណៈ ដើម្បីកែលម្អរសោភ័ណភាពស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ពោលគឺរមណីដ្ឋានស្អាត ទីក្រុងស្អាត សេវាកម្មល្អ។

ពិតមែនហើយ ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះគេសង្កេតឃើញសង្កាត់ព្រៃតាហ៊ូ បានលេចចេញយ៉ាងច្រើននូវផ្លូវកៅស៊ូ ផ្លូវបេតុង ស្ពានលូ ផ្លូវក្រាលក្រួសក្រហមស្ថាបនាថ្មីជាច្រើនខ្សែនិងសំណង់ធំៗបានផុសឡើងព្រោងព្រាត ចំណែកឯភូមិឋានទៀតសោតក៏មានសោភ័ណភាពខុសប្លែកច្រើនណាស់ បើប្រៀបធៀបទៅនឹងអតីតកាលប៉ុន្តែទោះជាយ៉ាងនេះក្ដីមហិច្ឆតាអភិវឌ្ឍន៍ក៏នៅតែមិនគ្រប់គ្រាន់នោះឡើយ ។ ថ្វីត្បិតសង្កាត់ព្រៃតាហ៊ូស្ថិតនៅក្រុងក៏ពិតមែនប៉ុន្តែនៅកន្លែងខ្លះប្រជាពលរដ្ឋពុំមានអគ្គិសនី និងទឹកស្អាតប្រើប្រាស់នោះទេ ហើយកន្លែងខ្លះទៀតត្រូវបានប្រជាពលរដ្ឋទិញខ្សែសម្រាប់តភ្លើងដោយខ្លួនឯង ដែលធ្វើឲ្យពួកគាត់ចំណាយលុយអស់ច្រើន ទាំងថ្លៃទិញខ្សែភ្លើងនិងថ្លៃថាមពលភ្លើង ហើយបញ្ហាដែលប្រឈមជាងនេះទៀតនោះ គឺខ្សែភ្លើងដែលពួកគាត់តទាំងនោះធ្លាក់រប៉ាត់រប៉ាយ គ្មានបច្ចេកទេស ប្រឈមនឹងគ្រោះថ្នាក់ដល់មនុស្ស និងសត្វ ព្រមទាំងសោភ័ណភាពទីក្រុង។ លោកស្រី *អ៊ុន ឡៃហៀង* អាយុ៤៦ឆ្នាំ ប្រជាជនក្នុងភូមិព្រៃតាហ៊ូក៏ដូចជាអ្នកភូមិនៅទីនោះក៏បានសំណូមពរឲ្យលោកអភិបាលខេត្តកំពង់ធំ និងអាជ្ញាធរអគ្គិសនីកម្ពុជាជួយជំរុញក្រុមហ៊ុនអគ្គិសនីខេត្តកំពង់ធំផ្ដល់ការផ្គត់ផ្គង់ចរន្តអគ្គិសនីទៅភូមិរបស់ពួកគាត់ផង ដែលមានប្រវែងប្រមាណ២គីឡូម៉ែត្រពីបណ្ដាញខ្សែភ្លើងធំនោះ។

លោក *ផៃ ឈុនអេង* ក៏បានលើកឡើងថា ការអភិវឌ្ឍភូមិ សង្កាត់ឲ្យមានការរីកចម្រើននេះ អាស្រ័យដោយមានការដឹកនាំដ៏ត្រឹមត្រូវរបស់គណបក្សប្រជាជនកម្ពុជា ដែលមានសម្ដេចទាំង៣ជាប្រមុខ និងរាជរដ្ឋាភិបាលកម្ពុជាដែលមានសម្ដេចតេជោ**ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី។ ក្រៅពីនេះក៏មានការដឹកនាំចង្អុលបង្ហាញរបស់ ក្រុមការងារគណបក្សថ្នាក់កណ្ដាល ថ្នាក់ខេត្ត និងថ្នាក់ស្រុក ដែលតែងតែយកចិត្តទុកដាក់ជួយក្នុងការងារពង្រឹងទិសដៅនិងលើកកម្ពស់ការងារដឹកនាំរបស់សង្កាត់ឲ្យកាន់តែមានភាពប្រសើរឡើង។ កត្តាសំខាន់មួយទៀតដែរនោះ គឺគណបក្សសង្កាត់មានផ្លុងសាមគ្គីភាព ឯកភាពផ្ទៃក្នុងរឹងមាំ មានបទពិសោធន៍ការងារច្បាស់លាស់។ ពេលជួបបញ្ហាប្រឈមយើងជួបប្រជុំគ្នាភ្លាមដើម្បីដោះស្រាយ មិនទុកឲ្យវាក្លាយទៅជាជំងឺរ៉ាំរ៉ៃ បង្កជាបាតុភាពមិនល្អដល់ផ្ទៃក្នុង ហើយកៀកស្មាគ្នាអនុវត្តការងារបន្តទៅទៀត។ជាចុងក្រោយលោកចៅសង្កាត់បានសន្យាខិតខំបង្កើនការងារអភិបាលកិច្ចល្អ ពង្រឹងការអភិវឌ្ឍលើគ្រប់វិស័យដោយអនុវត្តឲ្យបានជោគជ័យនូវគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្របតាមសំណូមពរ និងបំណងប្រាថ្នារបស់ប្រជាជនក្នុងមូលដ្ឋាន ។



*អនុវិទ្យាល័យ និងសាលាបឋមសិក្សាព្រៃតាហ៊ូ ក្នុងសង្កាត់ព្រៃតាហ៊ូ ក្រុងស្ទឹងសែន ទីរួមខេត្តកំពង់ធំ*




# ស្ពានថ្មី អនុស្សាវរីយ៍ថ្មី

(បទពាក្យ ៧)



- ឆ្នាំមុនបងឆ្លងទៅត្រើយម្ខាង
បងជិះសាឡាងស្កាត់ជួបស្រី
លេងឈូងទាញព្រ័ត្រចូលឆ្នាំថ្មី
រាំវង់ស្គរដីនៅត្រើយកើត ។

- ក្រោយមកបងឲ្យម៉ែចូលស្ដី
ឆ្លងទឹកឆ្លងដីដែនកំណើត
ស្នោះស្ម័គ្រក្រមុំត្រើយខាងកើត
ព្រៃវែងល្អឆើតគាប់ចិន្ដា

- មិនយូរប៉ុន្មានខែកន្លង
ញាតិមិត្តប្អូនបងអ៊ំយាយតា
ឆ្លងទូកសាឡាងកាត់ជលសារ
ចូលរួមរៀបការយើងទាំងពីរ ។

- មកដល់ពេលនេះបងនិងស្រី
ឆ្នាំថ្មីសាងអនុស្សាវរីយ៍
យើងឆ្លងស្ពានថ្មីស្រស់សោភី
ឋានសួគ៌រមណីត្បិបាសា ។

- ស្ពានវែងស្ពានខ្ពស់ហួសនឹងស្មាន
អ្នកលឿងក្បែមក្សាន្តស្ងប់ចិន្ដា
ប្រៀបបានអំណោយពីទេវតា
ឆ្នាំថ្មីនេះណាជប់ប្រទាន ។

- ស្រណោះគ្រាមុនជិះសាឡាង
ឆ្លងទៅត្រើយម្ខាងស្ទើរមិនហ៊ាន
ត្រូវខ្យល់រលកបោកបំពាន
ព្រោះតែចង់ជួបមុខស្រីថ្លៃ ។

- ឥឡូវអស់ខ្វល់អស់ភ័យភិត
ស្ពានថ្មីប្រណិតឆ្លងយប់ថ្ងៃ
ទ្រព្យមហាសាលហួសកាត់ថ្លៃ
នេះដោយស្នាដៃរាជរដ្ឋាភិបាល។

- សម្ដេចតេជោផ្ដើមគំនិត
សាងថ្មែប្រឌិតពិតពិស្ដារ
អភិវឌ្ឍជាតិថ្កើងថ្លៃថ្លា
ប្រជាខេមរាបានរុងរឿង ។

*លោក សុខ សុធន*




## ជាក់ស្ដែង

អ្នកគ្រូសួរសិស្សម្នាក់:

- មើលប្អូនឆាំ ពាក្យថា " បានឮ១០០ដង មិនស្មើបានឃើញផ្ទាល់ភ្នែកម្ដង " តើបានន័យដូចម្ដេច ?

- បាទ ជម្រាបអ្នកគ្រូ ពាក្យហ្នឹងគេសំដៅលើវិទ្យុ និង ទូរទស្សន៍តើ។

- ម៉េចអីចឹងទៅវិញ ?

- បាទ ព្រោះវិទ្យុបានត្រឹមតែស្ដាប់ឮប៉ុណ្ណោះ។ ចំណែកទូរទស្សន៍ ឃើញរូបជាក់ស្ដែង។ ហេតុហ្នឹងហើយទើបទូរទស្សន៍មានតម្លៃថ្លៃជាងវិទ្យុរាប់រយដង។

## ថ្លើមធំ

ពិនិត្យជំងឺរួចរាល់ លោកវេជ្ជបណ្ឌិតសួរប្រពន្ធអ្នកជំងឺ

- កន្លងមក អ្នកស្រីមានដែលសម្គាល់ឃើញប្ដីរបស់អ្នកស្រី ចម្លែកចំណុចណាខ្លះទេ ?

សញ្ជឹងគិតបន្តិច ប្រពន្ធអ្នកជំងឺតប :

- ចាស៎មាន ថ្មីៗនេះ ខ្ញុំនិយាយអ្វីក៏គាត់តមាត់ដែរ។

លោកវេជ្ជបណ្ឌិតបើកភ្នែកធំៗ:

- អូហូស្លាប់ហើយ ប្ដីអ្នកស្រីមានជំងឺថ្លើមធំតើ។

## កាសែតថ្ងៃម្សិលមិញ

នាយជុច ផឹកកាហ្វេរួច ឃើញម្ចាស់ហាងដើរមកក្បែរក៏សួរ :

- លោកថៅកែ ជាថ្ងៃទីប៉ុន្មានហើយ ?

- ចុះកាសែតនៅលើដៃលោកស្រាប់ ម៉េចលោកមិនមើលកាសែតហ្នឹងទៅ!

- អត់កើតទេ នេះជាកាសែតថ្ងៃម្សិលមិញតើលោកថៅកែ។

## នៅតែអត់ដដែល

ព្រឹកមួយ នាងញ៉ានបានចូលគ្លីនិក និងត្អូញត្អែរប្រាប់លោកវេជ្ជបណ្ឌិត:

- ប្ដីខ្ញុំ យប់ណាក៏ដើរចោលផ្ទះទល់ភ្លឺ អត់រវីរវល់ជាមួយខ្ញុំសោះ។ លោកវេជ្ជបណ្ឌិតមានមធ្យោបាយអីជួយគាត់ឲ្យនៅផ្ទះបានទេ ?

លោកវេជ្ជបណ្ឌិតយកថ្នាំមួយគ្រាប់ហុចឲ្យ ហើយប្រាប់ :

- ណេះ ល្ងាចឡើងអ្នកស្រីឲ្យគាត់លេបថ្នាំនេះទៅ ធានាថាគាត់នឹងដេកលក់ទល់ភ្លឺ លែងដើរចោលផ្ទះទៀតហើយ។

នាងញ៉ាន ញញឹមអឹមអៀនបន្តិចទើបសួរ ៖

- ចុះបើអោយគាត់លេបត្រឹមកន្លះគ្រាប់បានទេ ?

- ម៉េចបានជាចង់អោយគាត់លេបត្រឹមកន្លះគ្រាប់ ?

- ចាំះព្រោះថាពីមុនគាត់ដើរចោលផ្ទះអត់រវីរវល់ជាមួយខ្ញុំ។

បើឲ្យគាត់លេបមួយគ្រាប់ គាត់នឹងដេកលក់ទល់ភ្លឺ អត់រវីរវល់នឹងខ្ញុំដដែល ។ ខ្ញុំចង់អោយគាត់លេបត្រឹមកន្លះគ្រាប់ ដើម្បីអោយលង់លក់ត្រឹមម៉ោងមួយយប់ ភ្ញាក់ដឹងខ្លួនវិញចាំះ ។

## ផ្នែកផលិត

បានជួបគ្នាតាមផ្លូវ ចែម សួរចឹក :

- នែ..ឥឡូវនេះឯងធ្វើអ្វីដែរ ?

- គ្នាធ្វើការនៅរោងចក្រផលិតប្រដាប់ក្មេងលេង! ចុះឯងវិញ ?

- គ្នាក៏ធ្វើការនៅរោងចក្រផលិតដែរ។

- អើល្អតើ! ចុះឯងធ្វើការនៅខាងផ្នែកណា បានជាគ្នាមិនដែលឃើញ ?

- ឃើញយ៉ាងម៉េច ? បើគ្នានៅខាងផលិតប្រដាប់មនុស្សចាស់ មិនមែនប្រដាប់ក្មេងលេងឯណា " គឺស្រោមអនាម័យណាសំឡាញ់ " ។

## មិនជឿ

នារាត្រីមួយ នាងច្រិប ខ្សិបសួរ នាយរ៉ូច ជាសង្សារ ៖

- បងសម្លាញ់! តើបងមានកើតអេដស៍ទេ ?

- អូហ៍ សុំអូនទុកចិត្តចុះ បងមិនដែលខិលខូចជាមួយនារីណាម្នាក់ផង ធ្វើម៉េចមានអេដស៍ ទៅកើត ? អូនច្រិប គឺជានារីដំបូងបំផុតហើយដែលបងបានរួមដំណេកជាមួយ ។

- អូនមិនជឿទេ!

- អេហ៍ បងសូមស្បថ បើបងមានអេដស៍ឱ្យរូឡូកិនថ្មល់ កិនបងស្លាប់ទៅចុះ។

- បាន បានអូនជឿបងហើយ អូនសួរនេះព្រោះអូនមិនចង់ឆ្លងអេដស៍ពីអ្នកទីពីរប៉ុណ្ណោះ។

- ថាម៉េច! អូនឯងមានអេដស៍ហើយ ? ពុទ្ធោ !។

បោះពុម្ពដោយ រោងពុម្ព **អរិយធម៌** ផ្ទះលេខ ៩២, ផ្លូវលេខ ៥៩៤, សង្កាត់បឹងកក់ II ខណ្ឌទួលគោក-ភ្នំពេញ
H/P : 012 990 935 / Tel : 023 885 188 / Fax : 023 885 189 E-mail : ariyathoar@yahoo.com

# អ្នកឧបត្ថម្ភ ទស្សនាវដ្ដី ប្រជាជន លេខ ១៦៧

| | | | | |
|---|---|---|---|---|
| ១- | លោកជំទាវ | **ម៉ែន សំអន** | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល ប្រធានគណៈកម្មាធិការគណបក្សក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច . | ៤០០.០០០៛ |
| ២- | ឯ.ឧ | **កែ គឹមយ៉ាន** | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល ប្រធានក្រុមការងារចុះខេត្តបន្ទាយមានជ័យ | ១០០ ដុល្លារ |
| ៣- | ឯ.ឧ | **អ៊ុក រ៉ាប៊ុន** | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល ប្រធានគណៈកម្មាធិការគណបក្សក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ. | ១០០ ដុល្លារ |
| ៤- | ឯ.ឧ | **ហ៊ុន ណេង** | ប្រធានគណៈកម្មការទី ៤ នៃរដ្ឋសភា | ១០០ ដុល្លារ |
| ៥- | ឯ.ឧ | **មិន ឃិន** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងធម្មការ និងសាសនា និងលោកជំទាវ **ខួន ឆួន** | ១០០ ដុល្លារ |
| ៦- | ឯ.ឧ | **ត្រាំ អ៊ីវតឹក** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងសាធារណការ និងដឹកជញ្ជូន | ១០០ ដុល្លារ |
| ៧- | ឯ.ឧ | **ថោង ខុន** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងទេសចរណ៍ | ១០០ ដុល្លារ |
| ៨- | ឯ.ឧ | **ប្រាក់ ចំរើន** | សមាជិកព្រឹទ្ធសភា | ១០០ ដុល្លារ |
| ៩- | ឯ.ឧ | **គង់ វិបុល** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកដ្ឋាន នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១០០ ដុល្លារ |
| ១០- | ឯ.ឧ | **លន់ លឹមថៃ** | ប្រធានគណៈកម្មាធិការគណបក្សខេត្តកំពង់ចាម | ១០០ ដុល្លារ |
| ១១- | ឯ.ឧ | **ជៀង អំ** | ប្រធានគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង | ១០០ ដុល្លារ |
| ១២- | ឯ.ឧ | **អូស្មាន ហាស្សាន់** | ប្រធានគណៈចលនាសាសនិកឥស្លាមនៃគណបក្សប្រជាជនកម្ពុជា | ១០០ ដុល្លារ |
| ១៣- | ឯ.ឧ | **សរ ចំរ៉ុង** | ប្រធានគណៈកម្មាធិការគណបក្សខេត្តក្រចេះ | ១០០ ដុល្លារ |
| ១៤- | ឯ.ឧ | **ប៉ា សុជាតិវង្ស** | ប្រធានគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ | ១០០ ដុល្លារ |
| ១៥- | ឯ.ឧ | **ឈិត សុខុន** | អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ | ១០០ ដុល្លារ |
| ១៦- | ឯ.ឧ | **ម៉ម ប៊ុននាង** | អនុប្រធានគណៈកម្មការទី ១០នៃព្រឹទ្ធសភា | ១០០ ដុល្លារ |
| ១៧- | ឯ.ឧ | **យុ តំរេង** | សមាជិកក្រុមការងារចុះខេត្តកំពង់ស្ពឺ ប្រធានក្រុមការងារចុះស្រុកឱរ៉ាល់ | ១០០ ដុល្លារ |
| ១៨- | គណៈកម្មាធិការគណបក្សខេត្តបាត់ដំបង | | | ១០០ ដុល្លារ |
| ១៩- | គណៈកម្មាធិការគណបក្សខេត្តសៀមរាប | | | ១០០ ដុល្លារ |
| ២០- | គណៈកម្មាធិការគណបក្សខេត្តបន្ទាយមានជ័យ | | | ៥០ ដុល្លារ |
| ២១- | គណៈកម្មាធិការគណបក្សក្រសួងកិច្ចការនារី | | | ៥០ ដុល្លារ |
| ២២- | ឯ.ឧ | **លឹម គានហោ** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក | ២០០.០០០ ៛ |
| ២៣- | ឯ.ឧ | **ម៉ម ប៊ុនហេង** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងសុខាភិបាល | ៥០ ដុល្លារ |
| ២៤- | ឯ.ឧ | **ថា យ៉ាវ** | អនុប្រធានគណៈកម្មាធិការគណបក្សធនាគារជាតិនៃកម្ពុជា | ២១៣.៤៧០៛ |
| ២៥- | ឯ.ឧ | **ជូ យិនស៊ីម** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | ៥០ ដុល្លារ |
| ២៦- | ឯ.ឧ | **អ៊ុក ប្រាថ្នា** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | ២០០.០០០ ៛ |
| ២៧- | ឯ.ឧ | **ឃឹម សារិទ្ធ** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ៥០ ដុល្លារ |
| ២៨- | ឯ.ឧ | **ប៉ាវ ហមផាន** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ៥០ ដុល្លារ |
| ២៩- | ឯ.ឧ | **សូ ជុងហួរ** | ប្រធានក្រុមប្រឹក្សាខេត្តព្រះសីហនុ | ៥០ ដុល្លារ |
| ៣០- | ឯ.ឧ | **ចាយ បូរិន** | អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម | ៥០ ដុល្លារ |
| ៣១- | ឯ.ឧ | **សួស យ៉ារ៉ា** | អ្នកតំណាងរាស្ត្រមណ្ឌលព្រះវិហារ | ៥០ ដុល្លារ |
| ៣២- | ឯ.ឧ | **នរៈ រតនៈវឌ្ឍនោ** | រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | ២០០.០០០ ៛ |
| ៣៣- | ឯ.ឧ | **ឃួន រ៉ានីន** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៥០ ដុល្លារ |
| ៣៤- | ឯ.ឧ | **កៅ ខុនដារ៉ា** | អនុប្រធានក្រុមការងារថ្នាក់កណ្ដាលចុះជួយខេត្តកោះកុង | ៥០ ដុល្លារ |
| ៣៥- | ឯ.ឧ.ឧ.សេនីយឯក | **មាស វីរិទ្ធ** | អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រឆាំងគ្រឿងញៀន | ៥០ ដុល្លារ |
| ៣៦- | ឯ.ឧ. | **បុន លឹមហេង** | អនុរដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | ២០០.០០០៛ |
| ៣៧- | ឯ.ឧ | **សេង ទៀង** | ជំនួយការផ្ទាល់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** | ២០០.០០០៛ |
| ៣៨- | ឯ.ឧ | **គីម ជាតិ** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ៥០ ដុល្លារ |
| ៣៩- | ឯ.ឧ | **ម៉ៅ ប៊ុនណារិន** | សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា | ១០០.០០០៛ |
| ៤០- | ឯ.ឧ | **ម៉ែន ស៊ុំផាន់** | សមាជិកព្រឹទ្ធសភា | ១០០.០០០៛ |
| ៤១- | ឯ.ឧ | **ប៉ាន ប៊ុនធឿន** | រដ្ឋលេខាធិការក្រសួងផែនការ | ១០០.០០០៛ |
| ៤២- | លោកជំទាវ | **ស៊ឹង ស៊ីយុត** | | ១០០.០០០៛ |
| ៤៣- | ឯ.ឧ | **គឹម ឆា** | ប្រធានក្រុមប្រឹក្សាខេត្តស្វាយរៀង | ១០០.០០០៛ |
| ៤៤- | ឯ.ឧបណ្ឌិត | **មាស ប៉ូ** | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ១០០.០០០៛ |
| ៤៥- | លោកជំទាវ | **និត្យ ច័ន្ទតារីន** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១០០.០០០៛ |
| ៤៦- | ឯ.ឧ | **ឆា ច័ន្ទលីដា** | ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** | ១០០.០០០៛ |
| ៤៧- | ឯ.ឧ | **ម៉ែន វិបុល** | ប្រធានគណៈហិរញ្ញវត្ថុនៃគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង | ១០០.០០០៛ |
| ៤៨- | ឯ.ឧ | **ជួន ថេរ៉ាវ៉ាត** | ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** | ១០០.០០០៛ |
| ៤៩- | ឯ.ឧ | **ម៉ៅ ឡាំង** | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | ១០០.០០០៛ |
| ៥០- | ឯ.ឧ | **ឆាយ ឫទ្ធិសែន** | អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | ១០០.០០០៛ |
| ៥១- | ឯ.ឧ | **អ៊ុន ឆាលី** | សមាជិកក្រុមប្រឹក្សាខេត្តកោះកុង | ១០០.០០០៛ |
| ៥២- | លោក | **អោម ចន** | ប្រធាននាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិនៃអគ្គនាយកដ្ឋានពន្ធដារ | ១០០.០០០៛ |
| ៥៣- | លោក | **សុខ វិសាលសម្បត្តិ** | អនុប្រធានក្រុមការងារចុះជួយឃុំព្រៃដើមថ្នឹង និងឃុំត្នោត១ ស្រុកស៊ីធរកណ្ដាល ប្រធានក្រុមហ៊ុនសម្បត្តិវិសាល | ១០០.០០០៛ |
| ៥៤- | ឧកញ៉ា | **សន កុសល** | អនុប្រធានគណបក្សស្រុកកំពង់សិលា | ២០ ដុល្លារ |
| ៥៥- | លោក | **សារូ រដ្ឋជាតិ** | មន្ត្រីសាលាខេត្តប៉ៃលិន | ៧០.០០០៛ |
| ៥៦- | លោក | **សារូ រដ្ឋបញ្ញា** | មន្ត្រីសាលាខេត្តប៉ៃលិន | ៧០.០០០៛ |
| ៥៧- | លោក | **សារូ រតនា** | មន្ត្រីខណ្ឌរដ្ឋបាលព្រៃឈើ ខេត្តមណ្ឌលគិរី | ៧០.០០០៛ |
| ៥៨- | ឯ.ឧ | **ហ៊ូ តាំងអេង** | រដ្ឋលេខាធិការក្រសួងផែនការ | ៥០.០០០៛ |
| ៥៩- | លោកជំទាវ | **ខេង សំវ៉ាដា** | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | ៥០.០០០៛ |
| ៦០- | ឯ.ឧ | **សាយ បូរិន** | ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** | ៥០.០០០៛ |
| ៦១- | ឯ.ឧ | **ពត ចាន់នី** | សមាជិកក្រុមការងារចុះជួយខេត្តកំពង់ចាម | ៥០.០០០៛ |
| ៦២- | ឯ.ឧ | **ហេង វណ្ណា** | សមាជិកក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៦៣- | លោក | **ស៊ាង ចាន់** | សមាជិកក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៦៤- | លោក | **ឃួន សំបូរ** | សមាជិកក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |

# អ្នកឧបត្ថម្ភ ទស្សនាវដ្ដី ប្រជាជន លេខ ១៦៧

| | | | | | |
|---|---|---|---|---|---|
| ៦៥- | លោកជំទាវ | ស៊ើ | ចំនួថា | ........................................ | ៥០.០០០៛ |
| ៦៦- | លោក | ជា | វុទ្ធី | សមាជិកក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្តព្រះសីហនុ ........ | ៥០.០០០៛ |
| ៦៧- | កញ្ញា | ផាង | នំតហ្វៀរ | មន្ត្រីក្រសួងទេសចរណ៍ ........ | ៥០.០០០៛ |
| ៦៨- | លោក | ទៅ | ម៉េងជួន | អភិបាលក្រុងប៉ោយប៉ែត ........ | ៥០.០០០៛ |
| ៦៩- | លោក | អ៊ុំ | រាត្រី | ប្រធានគណៈកម្មាធិការគណបក្សក្រុងសេរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ ........ | ៥០.០០០៛ |
| ៧០- | លោក | សួន | សុធី | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តបន្ទាយមានជ័យ ........ | ៥០.០០០៛ |
| ៧១- | លោក | គីម | ប៊ុណ្ណា | សមាជិកគណៈកម្មាធិការគណបក្សខេត្តសៀមរាបប្រធានសាខាគណបក្សមន្ទីរសាធារណការ និងដឹកជញ្ជូន ........ | ៥០.០០០៛ |
| ៧២- | លោក | គាត | ហ៊ុល | ប្រធានគណៈកម្មាធិការគណបក្សសង្កាត់ផ្សារកណ្ដាល ខេត្តបន្ទាយមានជ័យ ........ | ៥០.០០០៛ |
| ៧៣- | លោក | ចាប | ឌីណា | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ខណ្ឌដូនពេញ ប្រធានគណៈកម្មការផ្សារកណ្ដាល ........ | ៥០.០០០៛ |
| ៧៤- | លោក | ហង់ | ប៊ូ | ប្រធានក្រុមការងារចុះ ឃុំរវៀង ស្រុកសំរោង ខេត្តតាកែវ ........ | ៥០.០០០៛ |
| ៧៥- | គណៈកម្មាធិការគណបក្សប្រជាជនកម្ពុជាប្រចាំគណៈកម្មាធិការសម្របសម្រួលខ្មែរកម្ពុជាក្រោម | | | ........ | ៤០.០០០៛ |
| ៧៦- | ឯ.ឧ | ទេង | សាខុន | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម ........ | ៤០.០០០៛ |
| ៧៧- | លោក | លី | សារី | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ប្រធានមន្ទីររៀបចំដែនដី ខេត្តបន្ទាយមានជ័យ ........ | ៤០.០០០៛ |
| ៧៨- | លោក | គីម | សុវណ្ណ | ប្រធានមន្ទីរសាធារណការ ខេត្តបន្ទាយមានជ័យ ........ | ៤០.០០០៛ |
| ៧៩- | ឯ.ឧ | ស៊ិន | វុទ្ធី | សមាជិកអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធនធានទឹក ........ | ៣០.០០០៛ |
| ៨០- | ឯ.ឧ | ឈុំ | វណ្ណារិទ្ធ | អភិបាលរងខេត្តបន្ទាយមានជ័យ ........ | ៣០.០០០៛ |
| ៨១- | លោក | ម៉ៅ | សុខលីម | អនុប្រធានមជ្ឈមណ្ឌលជាតិវេជ្ជសាស្ត្របូរាណក្រសួងសុខាភិបាល សមាជិកក្រុមការងារចុះខេត្តតាកែវ ........ | ៣០.០០០៛ |
| ៨២- | លោក | ចាន់ | ស៊ុំណាត | សមាជិកគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក ........ | ៣០.០០០៛ |
| ៨៣- | លោក | ឃុ | ពៅ | អភិបាលស្រុកស្វាយចេក........ | ៣០.០០០៛ |
| ៨៤- | លោក | ទេព | វិសិដ្ឋ | អនុប្រធានគណៈត្រួតពិនិត្យគណបក្សខេត្តព្រះសីហនុ ........ | ៣០.០០០៛ |
| ៨៥- | កញ្ញា | កែវ | សុជាតា | អនុប្រធានលេខាធិការដ្ឋានអមគណៈកម្មការទី ៤ នៃព្រឹទ្ធសភា សមាជិកាក្រុមការងារចុះខេត្តរតនគីរី ........ | ៣០.០០០៛ |
| ៨៦- | ឯ.ឧ | ចុង | ផែត | អភិបាលរងខេត្តបន្ទាយមានជ័យ ........ | ២០.០០០៛ |
| ៨៧- | លោក | ឈា | ប៊ុនរិទ្ធ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ២០.០០០៛ |
| ៨៨- | លោក | ម៉ៅ | ហាក់ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ២០.០០០៛ |
| ៨៩- | លោក | លឹម | វីរក្ស | សមាជិកគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក និងឧតុនិយម ........ | ២០.០០០៛ |
| ៩០- | លោក | លឹម | ថេង | សមាជិកក្រុមការងារចុះខេត្តកណ្ដាល........ | ២០.០០០៛ |
| ៩១- | លោក | ឃ្លោក | សំអាង | សមាជិកក្រុមការងារចុះខេត្តកំពង់ចាម ........ | ២០.០០០៛ |
| ៩២- | លោក | ជា | គឹមលីន | ប្រធានលេខាធិការដ្ឋានអមគណៈកម្មការទី ៤ នៃព្រឹទ្ធសភា ........ | ២០.០០០៛ |
| ៩៣- | លោក | ហ៊ុង | ជ្រិន | ប្រធានគណៈហិរញ្ញវត្ថុនៃគណៈកម្មាធិការគណបក្សខេត្តបាត់ដំបង ........ | ២០.០០០៛ |
| ៩៤- | លោក | ម៉ី | វុធ្ធា | មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង ........ | ២០.០០០៛ |
| ៩៥- | លោក | អ៊ុត | សំអាន | អធិការរងនៃអធិការដ្ឋានក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ........ | ២០.០០០៛ |
| ៩៦- | លោក | គួច | ចាន់និត្យ | អាជីវករ ខេត្តបន្ទាយមានជ័យ ........ | ២០.០០០៛ |
| ៩៧- | លោក | លី | សារុន | មន្ត្រីក្រសួងហិរញ្ញវត្ថុ ........ | ១៥.០០០៛ |
| ៩៨- | លោក | អ៊ុច | សាវ៉ន | អនុប្រធានមន្ទីរកសិកម្ម ខេត្តបន្ទាយមានជ័យ ........ | ១៥.០០០៛ |
| ៩៩- | ឯ.ឧ | សេង | សុមុនី | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធម្មការ និងសាសនា ........ | ១០.០០០៛ |
| ១០០- | ឯ.ឧ | ប៉ុញ | សច្ចៈ | អគ្គនាយកកិច្ចការបច្ចេកទេសនៃក្រសួងធនធានទឹក និងឧតុនិយម ........ | ១០.០០០៛ |
| ១០១- | លោក | ម៉ី | លីហួត | សមាជិកក្រុមការងារចុះខេត្តកំពង់ចាម ........ | ១០.០០០៛ |
| ១០២- | លោក | ជួន | វណ្ណរិទ្ធ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ១០.០០០៛ |
| ១០៣- | លោក | ខួន | ពេជ្រ | ប្រធាននាយកដ្ឋានទឹកស្អាត ក្រសួងធនធានទឹក និងឧតុនិយម ........ | ១០.០០០៛ |
| ១០៤- | លោក | មឹម | ឬទ្ធស | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងធនធានមនុស្សនៃក្រសួងធានធានទឹក និងឧតុនិយម ........ | ១០.០០០៛ |
| ១០៥- | លោក | សៅ | សម្ផស្ស | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងនៃក្រសួងធានធានទឹក និងឧតុនិយម ........ | ១០.០០០៛ |
| ១០៦- | លោក | ឈុន | ប៊ុនឈឿន | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ១០.០០០៛ |
| ១០៧- | លោក | ថេង | ប៊ុនតេង | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ១០.០០០៛ |
| ១០៨- | លោក | ស្វាយ | សុគន្ធី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ១០.០០០៛ |
| ១០៩- | លោក | សុខ | ចំណាន | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ១០.០០០៛ |
| ១១០- | លោក | សៅ | សម្ភារ | ប្រធានការិយាល័យបណ្ដុះបណ្ដាលនៃនាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស នៃក្រសួងធានធានទឹក និងឧតុនិយម ..... | ១០.០០០៛ |
| ១១១- | លោក | ទិត | ចរិយា | ប្រធានការិយាល័យគណនេយ្យនាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងធានធានទឹក និងឧតុនិយម ........ | ១០.០០០៛ |
| ១១២- | លោក | សែម | សំណាង | ប្រធានការិយាល័យគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រនាយកដ្ឋានធារាសាស្ត្រ កសិកម្ម នៃក្រសួងធានធានទឹក និងឧតុនិយម . | ១០.០០០៛ |
| ១១៣- | លោក | សុខ | តារា | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ១០.០០០៛ |
| ១១៤- | លោក | សូ | ផល្លី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ១០.០០០៛ |
| ១១៥- | លោក | ហួត | ធាន | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ១០.០០០៛ |
| ១១៦- | លោក | ទឹម | វុដ្ឋារី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ១០.០០០៛ |
| ១១៧- | លោក | ណុប | វៀមណី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ១០.០០០៛ |
| ១១៨- | លោក | សារុន | សម្បត្តិ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ១០.០០០៛ |
| ១១៩- | លោក | សរ | វិចិត្រ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ១០.០០០៛ |
| ១២០- | លោក | ទូច | សុផល្លា | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ១០.០០០៛ |
| ១២១- | លោក | ជុំ | ឧត្តរ៉ា | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ១០.០០០៛ |
| ១២២- | លោក | ឈ្លាង | ប៊ុយ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ១០.០០០៛ |
| ១២៣- | កញ្ញា | ម៉ាក់ | គីចហៀក | មន្ត្រីក្រុមហ៊ុន JC សាខាបាត់ដំបង ........ | ១០.០០០៛ |
| ១២៤- | លោក | យស់ | ធុល | សមាជិកក្រុមការងារចុះស្រុកកំពង់លាវ ខេត្តព្រៃវែង ........ | ១០.០០០៛ |
| ១២៥- | លោក | ឡុង | ចន្ថា | សមាជិកក្រុមការងារចុះស្រុកកំពង់លាវ ខេត្តព្រៃវែង ........ | ១០.០០០៛ |
| ១២៦- | លោក | ឡាច | គីរ៉ាត់ | សមាជិកក្រុមការងារចុះស្រុកបាភ្នំ ខេត្តព្រៃវែង ........ | ១០.០០០៛ |
| ១២៧- | លោក | ឈាង | សុវណ្ណារ៉ា | មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង ........ | ១០.០០០៛ |





រដ្ឋសភា បោះឆ្នោតជ្រើសតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតថ្មី ដែលមាន ៩ រូប

៦



ស្ពានមេគង្គស្ទឹងត្រែង ផ្លូវជាតិលេខ ៩ និងស្ពានត្បែបាសា ជាសម្បត្តិមហាសាលរបស់ប្រជាជនកម្ពុជា ត្រូវបានសម្ពោធដាក់ឲ្យប្រើប្រាស់ក្នុងខែមេសានេះ

៧



សម្តេចតេជោ **ហ៊ុន សែន** អញ្ជើញចូលរួមវេទិកាសេដ្ឋកិច្ចពិភពលោកស្តីពីអាស៊ីបូព៌ា លើកទី ២៤ កិច្ចប្រជុំកំពូលអាស៊ីអាហ្វ្រិក ពិធីរំលឹកខួបអនុស្សាវរីយ៍លើកទី ៦០ នៃសន្និសីទទីក្រុង ........

១០

**និពន្ធនាយក :**
**លោក តាក ស៊ុនអ៊ី**
**គណៈកម្មការនិពន្ធ**
១. លោក ខៀវ ណារី
២. លោក អ៊ឹម សុន្ទរៈ
៣. លោក វង្ស សារុំធ
៤. លោក ទាវ សារៈមុនី
៥. លោក សុខ សុធន
**លេខានិពន្ធ**
១. លោក ជុំ សម្បត្តិ
២. លោក ម៉ក់ ឈិន
**អ្នកបកប្រែភាសា**
១. លោកស្រី ម៉ែន នារីសោភ័គ
**អ្នកថតរូប**
១. លោក សុផាត វីរៈមុនី
**វិចិត្រករ**
១. លោក ធា សារុំធ
អាស័យដ្ឋាន :
លេខ ២០៣
មហាវិថី ព្រះនរោត្តម
ភ្នំពេញ-កម្ពុជា
ទូរស័ព្ទលេខ :
០២៣ ២១៩ ០៦៥
**Address :**
**No 203 Preah**
**Norodom Bld.**
**Phnom Penh Cambodia**
**Tel : 023 219 065**

## ក្របមុខ

## ទិដ្ឋភាពទូទៅនៃព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំ២០១៥ នៅក្រុងសៀមរាបអង្គរ

# មាតិកា

# Contents


*វិចារណកថា* : កម្ពុជាកំពុងឈានទៅមុខយ៉ាងរឹងមាំលើមាគ៌ាអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច .................. ៣

*Editorial* : Cambodian's Steadfast Steps on the Path of Socio-economic Development...........

⇨ កម្ពុជាបានចេញផុតពីភាពតានតឹងខាងនយោបាយហើយ............................................ ៥

⇨ សកម្មភាពសមាជិក រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស ................................ ១៤

⇨ សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស ..................................................... ១៦

⇨ វិស័យកសិកម្មនៅកម្ពុជាឆ្នាំ ២០១៤ បង្ហាញពីវឌ្ឍនភាពដ៏រឹងមាំ............................................១៨

⇨ សមិទ្ធផលវិស័យសុខាភិបាលឆ្នាំ ២០១៤ និងទិសដៅឆ្នាំ ២០១៥......................................... ២១

⇨ ព្រៃកទ័ល នឹងក្លាយជាតំបន់គំរូ ផ្នែកអភិរក្សបរិស្ថាន និងទេសចរណ៍ធម្មជាតិប្រកប...................... ២៣

⇨ *វប្បធម៌* : ព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំ ២០១៥ នៅខេត្តសៀមរាបទទួលបានជោគជ័យ................. ២៥

⇨ *ចំណេះដឹងទូទៅ* : គោលនយោបាយ Abenomic កំពុងធ្វើឲ្យសេដ្ឋកិច្ចជប៉ុនងើបឡើងវិញ............. ២៧

⇨ *វិទ្យាសាស្ត្រ សុខភាព* : ស្វែងយល់អំពីគុណសម្បត្តិ និងគុណវិបត្តិរបស់បន្លែត្រកួន និងស្ពៃខ្មៅ........ ២៨

⇨ *ទឹកដីមាតុភូមិ* : សង្កាត់ព្រៃតាហ៊ូ និងការអភិវឌ្ឍតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល............២៩

⇨ *កំណាព្យ* : ស្ពានថ្មី អនុស្សាវរីយ៍ថ្មី.......................សំណើច ............................................... ៣១

ទស្សនាវដ្ដី

# ប្រជាជន

THE PRACHEACHUN MAGAZINE





ឆ្នាំទី១៨ លេខ ១៦៧ ខែមេសា ឆ្នាំ ២០១៥



«ស្ពានមិត្តភាព កម្ពុជា-ចិន មេគង្គស្ទឹងត្រែង» បណ្តោយប្រវែង ១ ៧៣១ ម៉ែត្រ ទទឹង ១៣,៥ ម៉ែត្រ
និងផ្លូវជាតិលេខ ៩ តភ្ជាប់ពីខេត្តស្ទឹងត្រែង ទៅខេត្តព្រះវិហារ
សម្ពោធដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី ០១ មេសា ឆ្នាំ ២០១៥



ចែកជូនដោយឥតគិតថ្លៃ